OLD VERSION

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Mar-2015, 13:20
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៥២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្សី
*(Ms. Maddalena Ghezzi)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡេ្បា ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

លោកស្រី សួ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក វ៉ាន់ សឿន ហៅ ស៊ាន់ (2-TCW 847) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ទ៉ាន់ សឿន ហៅ ស៊ាន់** (2-TCW 847)

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ....................ទំព័រ ៤

សួរដោយលោកស្រី ជេត វណ្ណលី ផ្តើមពី....................ទំព័រ ២៨

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................ទំព័រ ៣៤

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៣៦

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:៣៥]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី វ៉ាន់ សឿន បន្ត។

ក្រឡាបញ្ជីតុលាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលិកដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក អាកទួរ វែកគែន មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមាន ដោយលោកមានបញ្ហាសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិ មានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក វ៉ាន់ សឿន។ លោក និងមេធាវីប្រឹក្សាលោក ម៉ម រិទ្ធា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយមានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥។

មេធាវីការពារក្ដីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការបង្ហាញ ឬក៏ដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៧:១០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥។ បានកត់សម្គាល់ឃើញថា សុខភាពជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះ ពេលអង្គុយយូរ និងវិលមុខ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទ្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៨:២៩]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមកំណត់ពន្យល់ស្ដីអំពីការបកប្រែភាសាផ្ទាល់មាត់នៅក្នុងបន្ទប់សវនាការ។ មុនពេលចាប់ផ្ដើមកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា គ្រប់ពេលដែលបុគ្គលនិយាយតាមក្បាលមីក្រូហ្វូន ឬក្នុង -- នៅក្នុងបន្ទប់សវនាការនេះ ការបកប្រែទៅជាភាសាពីរផ្សេងទៀត នឹងត្រូវបានធ្វើឡើង។ ដើម្បីបង្កើតបាននូវកំណត់ត្រាតុលាការមួយត្រឹមត្រូវ និងដើម្បីអនុញ្ញាតឲ្យអ្នកបកប្រែផ្ទាល់មាត់ អាជីពបំពេញការងាររបស់ខ្លួនបានសមស្រប ភាគីទាំងអស់ត្រូវនិយាយឲ្យបានយឺតៗនិងច្បាស់។ មួយវិញទៀត ការសួរសំណួរដែលមានលក្ខណៈវែងអន្លាយ ឬ

មានឃ្លាសាំញ៉ាំច្រើន អាចនាំឲ្យមានការភាន់ច្រឡំដល់បុគ្គលដែលកំពុងផ្តល់សក្ខីកម្ម និងការលំបាកក្នុងការបកប្រែភាសាឲ្យមានសុក្រិត។ ហេតុដូច្នេះ ភាគីទាំងអស់គួរតែព្យាយាមប្រើប្រាស់ភាសាសាមញ្ញ ហើយគួរជៀសវាងកុំចោទសំណួរច្រើនក្នុងពេលតែមួយដល់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ។

ការនិយាយលឿន ការតាំងសំណួរច្រើនក្នុងពេលតែមួយ ឬការសួរសំណួរដែលមានលក្ខណៈវែងអន្លាយ ឬមានឃ្លាប្រយោគសាំញ៉ាំច្រើន មិននាំឲ្យចំណេញពេលវេលានោះទេ។ តែផ្ទុយទៅវិញ វាបង្កើតនូវភាពច្របូកច្របល់បន្ថែមទៀត ដែលជាឧបសគ្គដល់ការអនុវត្តកិច្ចដំណើរការនីតិវិធីសវនាការឲ្យបានត្រឹមត្រូវនិងឆាប់រហ័ស។

[០៩:១០:២២]

អង្គជំនុំជម្រះស្នើឲ្យអង្គភាពបកប្រែភាសាផ្តល់ព័ត៌មានមកអង្គជំនុំជម្រះ នៅពេលដែលល្បឿននៃការនិយាយមិនអាចនាំទៅដល់ការបកប្រែឲ្យបានត្រឹមត្រូវទេនោះ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះក៏ណែនាំដល់ភាគីឲ្យរៀបចំសំណួរដែលងាយយល់ ប្រសិនបើសំណួរនោះមានលក្ខណៈវែងអន្លាយ ឬមានលក្ខណៈសាំញ៉ាំច្រើន។ ម្យ៉ាងទៀត អង្គជំនុំជម្រះសូមរំឭកដល់ភាគីជាតិនៃភាគីនីមួយៗបន្ថែមទៀតថា ក្នុងអំឡុងពេលដែលដៃគូភាគីអន្តរជាតិឡើងនិយាយ ឬសួរទៅកាន់គោលដៅដែលត្រូវសួរ សូមជួយ៖ ១) រំឭកដល់ដៃគូដែលនិយាយភាសាបរទេសនោះឲ្យបន្ថយល្បឿនក្នុងការ -- ករណីដែលគាត់និយាយលឿនពេក តាមរយៈស្តាប់ភាសាបកប្រែ។ ២) គប្បីឆ្លៀតពេលក្រឡេកមើលមកប្រធានសវនាការផង ដើម្បីអាចទទួលនូវសញ្ញាសុំឲ្យបន្ថយល្បឿននិយាយពីប្រធានសវនាការក្នុងករណីចាំបាច់សមស្របណាមួយ។

បាទ នេះជាការជម្រាបបញ្ជាក់ឡើងវិញ ពីព្រោះបញ្ហាកន្លងមកនេះអង្គជំនុំជម្រះកត់សម្គាល់ឃើញថាមានបញ្ហាមួយចំនួនដែលមានភាពច្បាស់លាស់រហូតដល់ប្រតិចារឹកប្រចាំថ្ងៃឃើញថាករណីប៉ុន្មានថ្ងៃ ឃើញថាយើងមានបញ្ហាច្រើននៅលើប្រតិចារឹក បើប្រៀបធៀបរវាងភាសាទាំងបី ឃើញថាវាមានបញ្ហានៅក្នុងការដោះស្រាយ។ ហើយបញ្ហានេះមានឥទ្ធិពលច្រើនទៅថ្ងៃអនាគត ជាពិសេសក្នុងការរៀបចំនូវសាលដីការបស់យើងនាពេលៗខាងមុខ ប្រសិនបើមិនប្រិតព្រៀងធ្វើការឲ្យបានហ្មត់ចត់ទេនោះ គឺលទ្ធផលនៃកិច្ចដំណើរការសវនាការយើង ក៏ទទួលបានលទ្ធផលមិនល្អដូចអ្វីដែលយើងបណ្តែតបណ្តោយឲ្យសភាពការណ៍នៃការបកប្រែភាសាហ្នឹងមិនបានពេញលេញ មិនបានច្បាស់លាស់ដដែល។

បាទ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញ

ដោលចំពោះសាក្សី។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

ជម្រាបសួរលោកសាក្សី វ៉ាន់ សឿន។ កាលពីម្សិលមិញ ខ្ញុំបានសួរជាច្រើនរួចមកហើយ ហើយឥឡូវនេះ ខ្ញុំបន្តប្រហែលជាទៅដល់ម៉ោងដប់មួយ។ កាលពីម្សិលមិញ លោកបានប្រាប់អង្គជំនុំជម្រះថា លោកជាអ្នកយាម ហើយជានីរសារនៅក្រាំងតាចាន់ចាប់ពីឆ្នាំ១៩៧៥មក។ ហើយនៅពេលដែលលោកយកសំបុត្រទៅឲ្យស្រុក លោកត្រូវកាន់ស្រោមសំបុត្រ ហើយលោកពន្យល់ថា តាអាន់ ដែលជាប្រធានមន្ទីរសន្តិសុខសរសេរដោយដៃនៅលើស្រោមសំបុត្រទាំងអស់នោះ។ ហើយលោកបានប្រាប់ផងដែរថា នៅសម័យនោះ លោកអាចស្គាល់អក្សរដៃរបស់ តាអាន់។

លោកប្រធានខ្ញុំសូមអនុញ្ញាតប្រគល់ជូនសាក្សីនូវឯកសារមួយ ហើយនិងសុំការអនុញ្ញាតបង្ហាញនៅលើអេក្រង់កុំព្យូទ័រ គឺឯកសារលេខ D232/73.2 ឯកសារនោះ មានតែមួយទំព័រទេទាំងបីភាសាតែម្តង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:១៤:០៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** លោកសាក្សីសូមលោកមើលនៅខាងក្រោមទំព័រ គឺខ្ញុំបានគូសជាចតុកោណកែង។ ក្នុងនេះគេនិយាយថា មន្ទីរអប់រំ១០៥ ចាប់ពី -- "ថ្ងៃនេះយើងកម្ទេចពួកអាខ្មាំងមកទល់ថ្ងៃនេះគឺអស់១៥០០នាក់ សូមបក្សជ្រាប ម.អប់រំស្រុក ហត្ថលេខាអាន់"។ ដូច្នេះ នៅថ្ងៃនេះ តើលោកអាចកំណត់យថាភាពនៃឯកសារបានទេ? ហើយលោកស្គាល់ទេថាអក្សរសរសេរដៃនេះ ជាអក្សររបស់តាអាន់ ឬក៏មិនមែនទេ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា អក្សរនេះ ខ្ញុំក៏មិនបានចាំច្បាស់ដែរ ពីព្រោះយូរឆ្នាំហើយ ៤០ឆ្នាំ

ហើយ បាទ មិនពិតប្រាកដទេ ពីព្រោះអក្សរនេះដឹងអក្សរនៅត្រង់ណា ខ្ញុំអត់ដឹងបាទ។

**ស៖** ចុះហត្ថលេខានៅខាងក្រោមហ្នឹង នៅពេលដែលលោកនៅក្រាំងតាចាន់ហ្នឹង ធ្លាប់ឃើញហត្ថលេខារបស់ តាអាន់ ទេហើយបើសិនជាធ្លាប់ឃើញ តើលោកមើលទៅហត្ថលេខាហ្នឹងលោកស្គាល់ទេ ពិតជារបស់តាអាន់ ទេ?

**ឆ៖** បាទ អត់ស្គាល់ទេបាទ។

**ស៖** ចំពោះចំនួនអ្នកចូល ហើយនិងរបៀបរបបនៃការចូលទៅមន្ទីរក្រាំងតាចាន់ លោកបានផ្ដល់តួលេខមួយចំនួន ជាពិសេសលោកបានប្រាប់ថា ខ្ញុំសូមដកស្រង់នៅក្នុងកំណត់ហេតុទី១របស់លោក គឺលេខ D40/23, ជាភាសាខ្មែរ គឺ ERN លេខ 00223211, ជាភាសាបារាំងគឺ 00490910។ អម្បាញ់មិញ ខ្ញុំច្រឡំហើយលេខទី១អំមិញ គឺជាភាសាអង់គ្លេសទេ គឺ00223211, ជាភាសាខ្មែរគឺ 00165355 ទេ។ ខ្ញុំគិតថា មេធាវីប្រឹក្សារបស់លោក គាត់មានឯកសារនេះហើយ អ៊ីចឹងគាត់អាចចង្អុលបង្ហាញជូនលោកបាន។ ដូច្នេះខ្ញុំនឹងអានចម្លើយរបស់លោក ពេលនោះគេសួរថា "អ្នកទោសដែលគេនាំមកមន្ទីរក្រាំងតាចាន់ នេះជាទូទៅម្ដងៗមានប៉ុន្មាននាក់? នាំមកនៅពេលណា ដោយមធ្យោបាយអ្វី?" លោកបានឆ្លើយដូចតទៅ៖ "ម្ដងៗ ដែលគេនាំអ្នកទោសមក មានប្រហែលពីរទៅបីនាក់។ ក្នុងមួយខែមានអ្នកទោសប្រហែលជា២០ ទៅ២៥នាក់ ដែលគេបណ្ដើរយកមកនៅពេលយប់ ប្រហែលជានៅម៉ោងប្រាំពីរ ឬប្រាំបីយប់"។ "សំណួរ៖ អ្នកទោសដែលនាំមកនោះមានជាប់ខ្នោះ ឬចំណងអ្វីទេ?" លោកឆ្លើយថា "ជាទូទៅអ្នកទោស គេចងដៃទៅក្រោយពីរចំណង ត្រង់កដៃមួយចំណង និងត្រង់កំភួនដៃមួយចំណងទៀត ហើយដាក់ខ្សែដឹកតភ្ជាប់ពីអ្នកទោសមួយទៅអ្នកទោសមួយទៀត"។

[០៩:១៧:៥៧]

នៅទំព័រដដែលនោះ លោកនិយាយថា នៅក្នុងអគារមួយៗនោះ មានអ្នកទោសប្រហែលជា២០ ទៅ២៥នាក់ ហើយនៅទំព័របន្ទាប់មកទៀត លោកថាមានអគារបីសម្រាប់ឃុំអ្នកទោស នៅមន្ទីរក្រាំងតាចាន់ ហើយអគារមួយនោះគឺចាស់ពេកគេមិនសូវប្រើទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ដូច្នេះខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញរបាយការណ៍មួយជូនលោក គឺឯកសារ E3/2109 គឺធ្វើរបាយការណ៍ជូនបក្ស នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ គឺខ្ញុំចង់បង្ហាញតែទំព័រទី១ទេនៅលើកុំព្យូទ័រ ហើយសូមការអនុញ្ញាតពីលោកប្រធានដើម្បីប្រគល់ឯកសារនេះជូនទៅសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[០៩:១៩:០៩]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នេះ របាយការណ៍នេះត្រូវបានផ្ដល់យថាភាពដោយសាក្សីផ្សេងទៀតរួចមកហើយ។ ខ្ញុំសូមអាន "មួយ. បញ្ជាអ្នកទោសក្នុងខែវិច្ឆិកានេះ ចូល៧៥នាក់ រួមទាំងអស់១៨៤នាក់។ បោសសម្អាត ៩២នាក់ ឈឺស្លាប់អស់ប្រាំមួយនាក់។ អង្គការដកទៅតំបន់ម្នាក់ពាក់ស័ក្តិបួនកន្លះ។ សព្វថ្ងៃនៅសល់ទាំងអស់៨៥នាក់"។ សូមបញ្ឈប់ការដកស្រង់។ ក្នុងរបាយការណ៍របស់មន្ទីរក្រាំងតាចាន់នេះគឺមានបញ្ជាក់ថា ក្នុងរយៈពេលមួយខែ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ នោះគឺមានអ្នកទោស៧៥នាក់ចូលមក ហើយធ្វើឱ្យមានសរុបទាំងអស់ គឺ១៨៤នាក់។ ហើយ៩២ ត្រូវបានបោសសម្អាត និងប្រាំមួយនាក់ស្លាប់ដោយជំងឺ។ អ៊ីចឹង តើលោកមានការចងចាំទេថា តើនៅខែមួយចំនួននោះ គឺថាមានអ្នកចូល អ្នកទោសចូលនុំងគឺមានចំនួនច្រើនណាស់ដូចដែលលោកបានឆ្លើយជូនទៅអ្នកស៊ើបអង្កេតអ៊ីចឹង គឺថាមាននៅខែមួយនោះគឺថាមានអ្នកទោសចូលមកច្រើនជាងគេ។ តើលោកអាចឆ្លើយបញ្ជាក់អំពីចំណុចនេះបានទេ?

**ឆ៖** បាទ ចំណុចត្រង់ហ្នឹង ខ្ញុំគ្រាន់ថា ខ្ញុំមិនបានសរុបស្ថិតិទេ ព្រោះវាអត់ដឹងគោលដៅបាទ។ បើអ្នកទោសចូល គឺច្រើនតែម្ដងបាទ តាមខែនីមួយៗបាទ។

**ស៖** ក្នុងរបាយការណ៍នេះ មានការសរសេរថា ៩២នាក់ត្រូវបានបោសសម្អាត។ អ៊ីចឹងពាក្យនៅសម័យនោះ ពាក្យថា "បោសសម្អាត"នេះ តើមានន័យថាដូចម្ដេចដែរ?

**ឆ៖** ពាក្យថា "បោសសម្អាត" គេវាយកម្ទេចចោលតែម្ដង បាទ។

**ស៖** តើមានឆ្នាំណា ឬក៏រយៈពេលណាដែលលោកមើលឃើញថា មានអ្នកទោសចូលច្រើន ហើយមានការសម្លាប់អ្នកទោសច្រើនបំផុតជាងឆ្នាំណាៗផ្សេងទៀតនោះ?

[០៩:២១:៥១]

**ឆ៖** ក្នុងចំណុចហ្នឹង ខ្ញុំអត់បានសួរនៅកន្លែងដែរបាទ អត់សួរទំនាក់ទំនងខាងក្នុងខាងក្រៅដែរ ពីព្រោះខ្ញុំក្មេងបាទ ប្រាប់ត្រង់តែម្ដងបាទ។

**ស៖** នៅពេលដែលលោកថា លោកនៅទីនោះមិនទៀតទាត់ហ្នឹង គឺមានន័យថាលោកនៅខាងក្រៅ ហើយលោកជាអ្នក -- ជានីរសារ លោកត្រូវយកសំបុត្រទៅក្រៅមន្ទីរ។ អ៊ីចឹងមែនទេ ចម្លើយ

របស់លោកអម្បាញ់មិញហ្នឹង?

**ឆ៖** បាទ។

**ស៖** ខ្ញុំសូមអានចម្លើយរបស់ ស៊ីម ដែលជាមិត្តរួមក្រុមអ្នកយាមរបស់លោកនៅក្រាំងតាចាន់ គាត់និយាយពាក់ព័ន្ធទៅនឹងចំនួនអ្នកទោសចូលថ្មី គឺនៅឯកសារលេខ D20 -- D40/20 សុំទោសជាភាសាខ្មែរគឺ 00165333, ជាភាសាបារាំងគឺ 00524321, ជាភាសាអង់គ្លេស 00433572។ គេសួរសំណួរទៅកាន់គាត់ថា ខ្ញុំសូមដកស្រង់៖ "ជាទូទៅតើអ្នកទោសប៉ុន្មាននាក់ដែលត្រូវគេនាំមកម្តងៗ? តើអ្នកទោសមកមានលក្ខណៈផ្សេងៗគ្នាទេ?" ស៊ីម គាត់បានឆ្លើយថា៖ "ជួនកាលទៅមានអ្នកទោស១០នាក់ ជួនកាលមានប្រាំនាក់ ជួនកាលមានតែម្នាក់។ អ្នកទោសថ្មី គឺមកដល់ស្ទើរតែជារៀងរាល់ថ្ងៃ"។

[០៩:២៣:៥៥]

នៅក្នុងសវនាការកាលពីថ្ងៃទី១៩ ខែកុម្ភៈ កន្លងទៅនេះ ស្រី ថន ហៅ ឌុច នៅចន្លោះម៉ោង ១២:១០ នាទី និងម៉ោង១១: ១៥ នាទី គាត់បានឆ្លើយជូនសវនាការថា ចំនួនអ្នកទោសដែលចូលមកក្រាំងតាចាន់ហ្នឹង គឺមានចន្លោះពីបី បួន ឬក៏២០នាក់ទៅតាមថ្ងៃនីមួយៗ"។ តើចម្លើយរបស់ ស៊ីម ហើយនិង ស្រី ថន ហៅ ឌុច នេះធ្វើឲ្យលោកចងចាំឡើងវិញទេ ពាក់ព័ន្ធទៅនឹងចំនួនអ្នកទោសដែលចូលមកថ្មីជារៀងរាល់ថ្ងៃ ឬក៏ជារៀងរាល់ខែ ហើយនិងចំនួនដែលគេនាំអ្នកទោសមកហ្នឹង គឺ ស៊ីម គាត់បានឆ្លើយថា គឺស្ទើរតែជារៀងរាល់ថ្ងៃទៅហើយ គឺមានអ្នកទោសថ្មីមក។ អ៊ីចឹង តើចំណុចនេះ ធ្វើឲ្យលោកនឹកឃើញទេៗពីចំនួនអ្នកទោសដែលចូលមកនៃសម័យនោះនុ៎ះ?

**ឆ៖** បាទ ចំនួនអ្នកទោសវា តាមថ្ងៃនីមួយៗហ្នឹង វាពិតជាមែនបាទ។

**ស៖** លោកបានឆ្លើយថាមានអ្នកទោសប្រហែលជា ២០ ទៅ២៥ នាក់នៅក្នុងអគារនីមួយៗគឺមានអគារអ្នកទោសបី នេះជាចម្លើយរបស់ ស្រី ថន ហៅ ឌុច ដែលជាអតីតអ្នកវាយអង្គុលីលេខនៅក្រាំងតាចាន់ គាត់បានឆ្លើយនៅសវនាការថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ នៅចន្លោះម៉ោង ១១:១៤នាទី និង ១១:១៦ នាទី គឺឯកសារលេខ E1/266.1។ គាត់បានឆ្លើយថា៖ "មានអគារពីរនៅក្រាំងតាចាន់។ ហើយអគារនីមួយៗហ្នឹងអាចទទួលអ្នកទោសបាន ៥០ ទៅ ៦០នាក់"។ សូមបញ្ចប់ការដកស្រង់។ តើដូចដែលឌុចតូចបាននិយាយអ៊ីចឹង គឺថាមានអ្នកទោស -- គឺអគារអ្នកទោសហ្នឹងអាចដាក់រហូតដល់ ៥០ ទៅ ៦០ នាក់ឯណោះ។ អ៊ីចឹងលោកអាចឆ្លើយបញ្ជាក់បានទេ?

**ឆ៖** បាទ អគារបីហ្នឹង មួយទ្រុឌទ្រោម។ ដល់ទ្រុឌទ្រោមគេដាក់បានតិច។ ដល់អគារពីរធ្វើថ្មី

ហ្នឹងបាន ពិតជា ពិតមែន បាទ។

**ស៖** តើលោកមាននៅចាំទេថា នៅមាន នៅពេលណាមួយនោះ គឺថាវាខុសពីធម្មតាតែម្ដង គឺថា មានអ្នកទោសច្រើនណាស់ គឺអាចទៅដល់ថា ប្រហែលជា ១០០នាក់ត្រូវបានគេនាំយកមកក្រាំងតាចាន់ នៅក្នុងពេលតែមួយ។ តើអាចមានរឿងអ៊ីចឹងកើតឡើងទេ លោកនៅចាំទេ?

**ឆ៖** បាទ រឿងនេះ ខ្ញុំអត់ដែលជួបទេ ដែលថាចូលច្រើនតែម្ដង ខ្ញុំអត់ដែលជួបទេបាទ។

[០៩:២៧:២៥]

**ស៖** ខ្ញុំដឹងហើយថាលោកមិននៅទីនុ៎ង ក៏ប៉ុន្តែតើលោកមាននៅចាំទេ ថាតើមានអ្នកខ្លះនោះ គេនាំមកដល់ក្រាំងតាចាន់ហើយ ត្រូវបានសម្លាប់ចោលភ្លាមតែម្ដងនៅពេលមកដល់ ដោយមិនត្រូវបាន គេឃុំ ឬក៏សួរចម្លើយអីទេ គឺមកដល់ភ្លាមសម្លាប់ចោលភ្លាមតែម្ដង។ តើលោកមាននៅចាំថាមានអ៊ីចឹង ទេ?

**ឆ៖** ហ្នឹងគ្រាន់ថា សូមបញ្ជាក់ថាគ្រួសារ យាយញ៉ ហ្នឹង លោកតាគុន ហើយបឿន ហ្នឹងឃើញ គេចាប់មកដល់ គេសួរចម្លើយវាយសម្លាប់តែម្ដងបាទ។

**ស៖** បាទ ខ្ញុំយល់ពាក់ព័ន្ធនឹងបញ្ហារបស់យាយ -- គ្រួសាររបស់យាយញ៉ ក៏ប៉ុន្តែខ្ញុំចង់សំដៅទៅ លើក្រុមអ្នកទោសផ្សេងទៀត តើលោកមានបានទទួលព័ត៌មានទេថា ក្រុមអ្នកទោសខ្លះនោះត្រូវបាន នាំ មកក្រាំងតាចាន់ហ្នឹង គឺមក -- នាំមកសម្លាប់ចោលតែម្ដង មិនមានចាំបាច់ឃុំឃាំងអីទេ?

**ឆ៖** កាលខ្ញុំនៅហ្នឹង ខ្ញុំអត់ដែលជួបដែលបាទ។ ថ្ងៃដែលគេនាំមកដល់ភ្លាមៗ ខ្ញុំអត់ដែលជួប ប្រទះដែលបាទ។

**ស៖** តើលោកអាចប្រាប់បានទេ ថាអ្នកណាជាអ្នកនាំអ្នកទោសថ្មីមកក្រាំងតាចាន់នោះ? អ្នកណា ជាអ្នកនាំពួកគេមក?

**ឆ៖** អ្នកនាំមកពីផ្សារ -- មកពីគុកសម្រាលទោសនៅផ្សារ -- នៅខាងលិចផ្សារអង្គរកាបាទ។ មិនដឹងជាយកពីខាងណាមកខាងណា ខ្ញុំអត់ដឹងពីព្រោះ គេបញ្ជូនដល់នោះបានឃើញ បាទ។

**ស៖** ដូច្នេះលោកមិនដែលធ្លាប់ឃើញ ឈ្លបនាំអ្នកទោសមកដល់ក្លោងទ្វារ គឺមកដល់បរិវេណ ខាងក្រៅក្រាំងតាចាន់ ដើម្បីឲ្យគេយកទៅចូលក្នុងមន្ទីរក្រាំងតាចាន់ទេ មែនទេ?

**ឆ៖** បាទ។

[០៩:៣០:០៨]

**ស៖** តើមានការរៀបចំប្រព័ន្ធថានៅពេលដែលអ្នកទោសថ្មីមកដល់ខាងក្រៅបរិវេណ អ្នកនាំមកហ្នឹង អ្នកនាំអ្នកទោសហ្នឹងអាចចូលទៅដល់ក្នុងបរិវេណតែម្តង ឬក៏គាត់នាំមកហ្នឹង មកតែត្រឹមបរិវេណខាងក្រៅទេ ហើយប្រគល់អ្នកទោសទាំងនោះទៅឲ្យអ្នកយាម?

**ឆ៖** បាទ គេនាំមកហ្នឹង ប្រគល់ឆ្ងាយ ខាងក្រៅប្រហែលជាដី១គីឡូហើយបាទ។

**ស៖** អ៊ីចឹងបុគ្គលិកក្រាំងតាចាន់ ហើយនិងអ្នកយាមហ្នឹង គាត់ដឹងថាអ្នកទោសថ្មីមកដល់ដោយរបៀបណា? គេមានវិធីអ្វីដើម្បីប្រាប់អ្នកនៅខាងក្នុងនោះ ប្រាប់បុគ្គលិកមន្ទីរក្រាំងតាចាន់ថា ហ៎! ឥឡូវអ្នកទោសថ្មីមកដល់ហើយ ព្រោះថាលោកថាអំមិញថា នៅចម្ងាយ១គីឡូឯណោះ។ អ៊ីចឹងគេប្រាប់យ៉ាងម៉េចទៅៗដល់អ្នកខាងក្នុងនុ៎ង?

**ឆ៖** សំខាន់នាំមកដល់កន្លែងគោលដៅ នាំមកផ្ទាល់តែម្តងបាទ ពីព្រោះសម័យនោះគ្មានទូរស័ព្ទក៏គ្មានអាយហ្វូនដែរ មានតែដើរផ្ទាល់តែម្តងបាទ។

**ស៖** ប្រសិនបើអត់មានអាយហ្វូន អត់មានទូរស័ព្ទអីទេ តើមានជួងទេ ដើម្បីវាយថា "ហ៎! អ្នកទោសថ្មីមកដល់ហើយ"?

**ឆ៖** ដើរផ្ទាល់តែម្តងបាទ។

[០៩:៣២:២០]

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ តើអ្នកដែលនាំអ្នកទោសមកហ្នឹង មកប្រគល់ឲ្យអ្នកយាមនៅក្រាំងតាចាន់ហ្នឹង គាត់មានវាយជួង វាយអីទេ ដើម្បីប្រាប់ថា "ហ៎! អ្នកទោសថ្មីដល់ហើយ" អ៊ីចឹង?

**ឆ៖** បាទ ខាងកូនសោនៅខាងក្រៅមួយ នៅខាងក្នុងមួយបាទ។ បើមកដល់ហ្នឹង យើងចាក់ចូលតែម្តងបាទ។ ចាក់ឲ្យគេនាំចូលតែម្តង។ ចាក់ប្រគល់ឲ្យគេ។

**ស៖** បាទ ខ្ញុំទុកប្រធានបទនេះចោលមួយឡែកសិន។ ឥឡូវនេះខ្ញុំចូលទៅពាក់ព័ន្ធទៅនឹងការងារលោកជានីរសារ ហើយនិងការទំនាក់ទំនងរវាងមន្ទីរក្រាំងតាចាន់ និងមន្ទីរស្រុក។ នៅក្នុងកំណត់ហេតុទី២របស់លោក គឺឯកសារលេខ E319.1.33 នៅពេលដែលលោកឆ្លើយទៅនឹងសំណួរ២៣០ គេសួរថា "តើលោកធ្លាប់យកសំបុត្រពីសាលាស្រុកមកក្រាំងតាចាន់វិញដែរឬទេ?" ចម្លើយលោកឆ្លើយថា៖ "អត់ទេជាទូទៅ ខ្ញុំយកសំបុត្រទៅឲ្យស្រុកហើយ ទើប៥ទៅ៦ថ្ងៃក្រោយមក គេយកសំបុត្រមកឲ្យវិញ"។ សូមបញ្ចប់ការដកស្រង់។ ហើយនៅក្នុងកំណត់ហេតុដដែលនោះ នៅចម្លើយទី២៩នោះ លោក គេសួរថា "តើលោកមានស្គាល់នីរសារដែលរត់សំបុត្រពីសាលាស្រុកត្រាំកក់មកក្រាំងតាចាន់ដែរឬទេ?" លោក

ឆ្លើយថា "បាទ មាននីរសារម្នាក់ដែលរត់សំបុត្រពីសាលាស្រុកមកក្រាំងតាចាន់។ គាត់ឈ្មោះ ហ៊ល– ហ-ិ-ល។ នៅស្រុកគឺមាននីរសារច្រើន ប៉ុន្តែខ្ញុំឃើញតែឈ្មោះ ហ៊ល ម្នាក់ប៉ុណ្ណោះជាអ្នករត់សំបុត្រ មកពីស្រុកមកក្រាំតាចាន់"។ កាលពីម្សិលមិញ លោកឆ្លើយថាលោកទៅសាលាស្រុកជារៀងរាល់ថ្ងៃ ឬក៏៣ថ្ងៃម្តង។ តើឈ្មោះ ហ៊ល ដែលជានីរសារស្រុកនេះ មកមន្ទីរក្រាំងតាចាន់ញឹកញាប់ ដូចដែល លោកទៅសាលាស្រុកទេ?

[០៩:៣៥:១០]

**ឆ៖** ហ៊ល ហ្នឹង ដើរជាមួយថៅហ្វាយស្រុក បាទ ហើយគេមិនសូវបានទៅកន្លែងហ្នឹងទេ គេ ប្រគល់ឲ្យកន្លែងស្នាក់ការខាងក្រៅ បាទ។

**ស៖** អ៊ីចឹងខ្ញុំចង់ដឹងថា គាត់មកមន្ទីរក្រាំងតាចាន់ញឹកញាប់ទេ ដើម្បីនាំសំបុត្រមកនោះ។ លោក លោកថាលោកនាំសំបុត្រទៅមន្ទីរស្រុក ហើយបួនប្រាំថ្ងៃមក មានគេនាំសំបុត្រមកមន្ទីរក្រាំង តាចាន់វិញ។ អ៊ីចឹង គាត់មកក្រាំងតាចាន់ហ្នឹងញឹកញាប់ទេ ដើម្បីនាំសំបុត្រមកនោះ គឺដូចគ្នាទៅនឹង លោក ដែលលោកទៅសាលាស្រុកញឹកញាប់ដើម្បីប្រគល់សំបុត្រនោះ?

**ឆ៖** ខ្ញុំមិនបានកំណត់ដែរ ពីព្រោះថ្ងៃហ្នឹង ជួនកាលយកទៅអ៊ីចឹងទៅ ជួនកាលក៏គេផ្ញើត្រឡប់ មកវិញក៏មាន ជួនកាលក៏អត់ទៅ ជួនកាលទម្លាក់ពីរបីថ្ងៃបានសំបុត្រហ្នឹងមកដល់ស្នាក់ការខាងក្រៅ។

**ស៖** នៅពេលដែលលោកធ្វើជានីរសារនៅក្រាំងតាចាន់ តើលោកធ្លាប់ដើរជួបនីរសារដែលធ្វើ នៅស្រុក១០៥ ធ្វើជានីរសារឲ្យ តាជឹម និងតាគិត ដែលឈ្មោះ ហ៊ី ទឹម ៗ។ គាត់ប្រហែលជា អាយុ១២ឆ្នាំ នៅពេលនោះ ហើយគាត់មកពីឃុំជាងទង។ លោកស្គាល់ទេ ធ្លាប់ដើរជ្រួសផ្លូវគ្នា ឬក៏ដើរ ជួប ហ៊ី ទឹម នេះទេ នៅពេលដែលលោកនាំសំបុត្រទៅសាលាស្រុកនោះ?

**ឆ៖** បាទ នីរសារនៅសាលាស្រុក ខ្ញុំស្គាល់តែមួយហ្នឹងបាទ។ ក្មេងៗ ខ្ញុំអត់សូវស្គាល់ វាតូចៗ ដូចគ្នាមែន ប៉ុនការទំនាក់ទំនងគ្នាដូចអត់មានអធ្យាស្រ័យគ្នាទៅវិញទៅមក ក៏មិនសូវមាត់សូវកអី ក៏ គ្រាន់តែមកប្រគល់ហើយ ខ្ញុំត្រឡប់ទៅវិញបាទ។

[០៩:៣៧:៥៥]

**ស៖** ខ្ញុំដឹងហើយ ថាគាត់ -- លោកមិនចាំឈ្មោះពេញរបស់នីរសារ ហ៊ល ទេ ក៏ប៉ុន្តែតើលោក អាចប្រាប់បានទេ ថាគាត់ហ្នឹងយ៉ាងម៉េចដែរ ហ៊ល ហ្នឹង?

**ឆ៖** ខ្ញុំអត់ស្គាល់ស្រុកកំណើត ហ៊ល ហ្នឹងដែរ ពីព្រោះកាលណោះ ខ្ញុំក៏នៅក្មេង គេក៏ក្មេង

ហើយអត់បានមានទំនាក់ទំនងស្រុកកំណើតអីដែរ។ ហើយម្យ៉ាងទៀត ហ៊ល នោះ ទាបទ្រនាប់សបាទ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់អានចម្លើយរបស់ ស៊ីម ដែលជាមិត្តរួមក្រុមរបស់លោក។ គាត់ឆ្លើយជូនចៅក្រមស៊ើបអង្កេត គឺឯកសារលេខ D40/20 ជាភាសាខ្មែរគឺ 00165332, ជាភាសាបារាំងគឺ 00524320, ជាភាសាអង់គ្លេសគឺ 00433571។ គេសួរសំណួរទៅកាន់គាត់ថា៖ “នៅពេលដែលគេប្រាប់នៅក្នុងប្រជុំថាគឺជាថ្ងៃដែលត្រូវសម្លាប់អ្នកទោសនោះ តើអ្នកសម្លាប់នោះ គឺមកពីតំបន់ណា?” ស៊ីម គាត់ឆ្លើយ -- សូមអភ័យទោស ខ្ញុំសូមនិយាយជាភាសាអង់គ្លេសវិញ ពីព្រោះថាអង់គ្លេសគឺបកប្រែទៅ ដូចជាត្រូវជាង។

(អានភាសាអង់គ្លេស៖) “បន្ទាប់ពីការប្រជុំ ពួកគេមានបញ្ជីមួយដែលត្រូវទៅ ដែលត្រូវបញ្ជូនទៅស្រុក។ នៅពេលដែលបញ្ជីនេះ ត្រូវបានបញ្ជូនត្រឡប់មកវិញ ខ្ញុំមើល ហើយឃើញថាឈ្មោះហ្នឹងគឺសរសេរជាប៊ិកពណ៌ក្រហម គឺជាឈ្មោះរបស់អ្នកដែលត្រូវបានយកទៅសម្លាប់ចោល”។ សូមបញ្ចប់ការដកស្រង់។ (បញ្ចប់ការអានភាសាអង់គ្លេស)

ឥឡូវនេះ ខ្ញុំនិយាយជាភាសាបារាំងវិញ គាត់បន្តទៀតថា ប៉ុន្តែដោយសារតែគេនិយាយបែប -- ប្រាប់ខ្ញុំហើយ ហើយឈ្មោះហ្នឹង គេ -- នៅពេលដែលគេគូសប៊ិកក្រហមហ្នឹងគឺថាត្រូវតែកម្ទេចចោល។ “សួរ៖ តើឈ្មោះអ្នកដែលប្រាប់ហ្នឹងគឺឈ្មោះអ្វីដែរ? ឆ្លើយ៖ ឌុច ជាអ្នកវាយអង្គុលីលេខ គាត់ដឹង គាត់ជាអ្នកនិយាយប្រាប់ខ្ញុំបែបនេះ”។ បាទ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើលោកៗមានបានឃើញបញ្ជី ឬឯកសារដែលមានការចំណារសរសេរដៃ ឬក៏មានសរសេរជាឈ្មោះជាប៊ិចកក្រហម អ៊ីចឹងទេ?

[០៩:៤១:២៤]

**ឆ៖** ត្រង់ចំណុចហ្នឹងមួយ ខ្ញុំអត់បានឃើញទេបាទ។

**ស៖** នៅក្នុងកំណត់របស់លោក គឺលេខ E319.1.33 នៅចម្លើយ -- នៅសំណួរទី៥៤ ខ្ញុំសូមដកស្រង់៖ “តើលោកមានឃើញអ្វីចម្លែកបន្ទាប់ពីលោកប្រគល់សំបុត្រពីមន្ទីរសន្តិសុខក្រាំងតាចាន់ទៅឲ្យស្រុកទេ? ចម្លើយទី៥៤៖ ប្លែកគឺត្រង់ថា មានការសម្លាប់មនុស្ស។ សំណួរ៖ ពេលដែលគេសម្លាប់ម្ដងៗ តើកើតក្រោយពេល ឬក៏មុនពេលដែលលោកយកសំបុត្រទៅឲ្យស្រុក? ចម្លើយទី៥៥៖ ក្រោយពេលដែលខ្ញុំយកសំបុត្រទៅឲ្យស្រុក ហើយបន្ទាប់មកស្រុកយកសំបុត្រមកឲ្យក្រាំងតាចាន់វិញ ទើបមានការសម្លាប់មនុស្ស។ សំណួរទី៥៦៖ មានន័យថា សំបុត្រនោះអាចជារបាយការណ៍អ្នកទោស ឬក៏

ចម្លើយសារភាព តើត្រឹមត្រូវដែរឬទេ? ចម្លើយទី៥៦៖ បាទ ត្រឹមត្រូវ។ សំណួរទី៥៧៖ អ៊ីចឹង ដំបូងមន្ទីរសន្តិសុខក្រាំងតាចាន់ជាអ្នកផ្ញើសំបុត្រទៅស្រុក ហើយបន្ទាប់មកស្រុកផ្ញើសំបុត្រត្រឡប់មកមន្ទីរក្រាំងតាចាន់វិញ ក្រោយពេលដែលស្រុកផ្ញើសំបុត្រមកក្រាំងតាចាន់វិញ ទើបមានការសម្លាប់មនុស្ស។ តើត្រឹមត្រូវ ដែរឬទេ? លោកឆ្លើយចម្លើយទី៥៧ថា៖ បាទ ត្រឹមត្រូវ។ សំណួរ៖ ដូច្នេះ មានន័យថាស្រុកជាអ្នកសម្រេចឲ្យមានការសម្លាប់មនុស្ស។ តើត្រឹមត្រូវដែរឬទេ? ចម្លើយ៖ បាទ ស្រុកជាអ្នកសម្រេចឲ្យសម្លាប់មនុស្ស"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ តាមការកត់សម្គាល់របស់លោក--

[០៩:៤៣:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានសូមជម្រាបសួរ! ហើយខ្ញុំសូមជំទាស់ទៅនឹងសំណួរមួយនេះ។ មិនមែនដោយសារការអាននោះទេ ប៉ុន្តែដោយសារតែបញ្ហានៅក្នុងៗ បញ្ហានៅក្នុង 319.1.11នោះ គឺថាវាជាការទាយស្មានព្រោះថាសាក្សីក៏គាត់បាននិយាយរួចហើយថាគាត់មិនបានឃើញអត្ថបទហ្នឹង ក៏ដូចជាខ្លឹមសារនៃសំបុត្រនោះ។ ដូច្នេះ ការនិយាយឡើងវិញនូវសំណួរនៅក្នុងឯកសារ E319.1.33ហ្នឹង គឺជាការស្នើសុំឲ្យមានការទាយស្មាន ព្រោះគាត់គ្រាន់តែទាយស្មាននោះទេ ហើយវាមិនមានទំនាក់ទំនងរវាងខ្លឹមសារនៃសំបុត្រហ្នឹងជាមួយនឹងការសម្លាប់ ឬក៏ហោចណាស់ ក៏សាក្សីក៏មិនអាចឆ្លើយបានទៅលើចំណុចនេះ។

**លោក វាំងសង់ វ៉ាយអ៍ ដេស្មាឯល៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ សំណួរដែលសួរដោយសហចៅក្រមស៊ើបអង្កេត ឬក៏អ្នកស៊ើបអង្កេតនោះ គឺផ្អែកទៅលើចម្លើយមុនៗរបស់សាក្សីនេះ។ គឺជាការសង្ខេបនូវចម្លើយរបស់សាក្សីទេ។ ហើយខ្ញុំមិនទាន់បានសួរសំណួរផង ខ្ញុំត្រូវ -- ខ្ញុំទើបតែអានតែប៉ុណ្ណោះ ខ្ញុំត្រៀមនឹងសួរសំណួរទៅហើយ ហើយគាត់ជំទាស់។ ឥឡូវនេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបន្តទៅទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តទៀតបាទ!

**សួរដោយលោក វាំងសង់ វ៉ាយអ៍ ដេស្មាឯល៖**

**ស៖** តាមការកត់សម្គាល់របស់លោកនោះ នៅពេលដែលមានសំបុត្រនាំមកពីមន្ទីរស្រុក១០៥ មកដល់ក្រាំងតាចាន់ហ្នឹង បន្ទាប់ពីមានការនាំសំបុត្រហ្នឹងហើយ គឺមានការសម្លាប់មនុស្ស។ តើមែនទេ?

[០៩:៤៥:៤០]

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ។

**ស៖** អ៊ីចឹងតើមានធ្លាប់ តាអាន់ ប្រាប់លោកនៅពេលប្រជុំនោះថា មានការសម្លាប់មនុស្ស ដោយថាមិនចាំបាច់មាននីវសារមកពីក្រាំងតាចាន់ -- មកដល់ក្រាំងតាចាន់ទេ គឺថាវាបញ្ច្រាសទៅវិញ។ មានអ៊ីចឹងទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងមន្ទីរឃុំឃាំងនៅអង្គរកា ព្រោះថានៅក្នុងកំណត់ហេតុទី២របស់លោក គឺលេខឯកសារ E319.1.33 លោកបានឆ្លើយ ហើយខ្ញុំនឹងអាន ហើយបន្ទាប់មកខ្ញុំនឹងសួរសំណួរលោក។ ចម្លើយទី៦០ លោកថា៖ "ដំបូងគេចាប់ខ្លួនមនុស្សពីឃុំទៅដាក់នៅស្រុកជាមុនសិនដើម្បីសួរចម្លើយ បន្ទាប់មកទើបគេបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សំណួរ៖ តាមដែលលោកដឹង តើអ្នកណាមានសិទ្ធិចេញបញ្ជាឲ្យចាប់ខ្លួនមនុស្ស? ចម្លើយ៦១៖ នៅពេលដែលមានទំនាស់នៅក្នុងសហករណ៍ គេបញ្ជូនទាំងនោះមកស្រុក ហើយក្រោយពេលដែលស្រុកសួរចម្លើយរួចហើយ គេបញ្ជូនមកក្រាំងតាចាន់។ សំណួរ៦២ តើកន្លែងសួរចម្លើយនៅមន្ទីរស្រុកមានឈ្មោះអ្វី? ចម្លើយ ៦២៖ ខ្ញុំមិនចាំឈ្មោះនោះទេ។ កន្លែងនោះស្ថិតនៅប្រហែលជា៣០០ ទៅ៤០០ម៉ែត្រខាងលិចផ្សារអង្គរកា។ សំណួរ៦៣៖ តើលោកធ្លាប់ទៅកន្លែងនោះដែរឬទេ? ចម្លើយ៦៣៖ ខ្ញុំធ្លាប់នាំសំបុត្រទៅកន្លែងនោះដែរ។ សំណួរ៦៤៖ តើលោកធ្លាប់ឃើញមានការសួរចម្លើយ ឬចាប់ចងមនុស្សនៅកន្លែងនោះដែរឬទេ? ចម្លើយ៦៤៖ ខ្ញុំឃើញគេឃុំឃាំងមនុស្សដោយដាក់ខ្នោះ។ សំណួរ៦៥៖ តើកន្លែងឃុំឃាំងមនុស្សនេះជាគុកមែនទេ? ចម្លើយ៖ កន្លែងនោះគឺជាគុក ប៉ុន្តែជាកន្លែងសម្រាប់អ្នកទោសស្រាល ហើយអ្នកទោសធ្ងន់គេបញ្ជូនទៅមន្ទីរសន្តិសុខក្រាំងតាចាន់។ សំណួរ៦៦៖ តើអ្នកណាជាអ្នកទទួលបន្ទុកសួរចម្លើយនៅគុកក្បែរអង្គរកានេះ? ចម្លើយ៖ ឈ្មោះម៉េង ជាអ្នកសួរចម្លើយ ហើយក៏ជាអ្នកគ្រប់គ្រងនៅកន្លែងនេះផងដែរ។ សំណួរ៦៧៖ តើមាន ម៉េង មានតួនាទីជាអ្វី? ចម្លើយ៖ ម៉េង ធ្វើការនៅសាលាស្រុក ប៉ុន្តែគាត់គ្មានតួនាទីអ្វីទេ គាត់គ្រាន់តែជាអ្នកគ្រប់គ្រងនៅគុកប៉ុណ្ណោះ។ ចម្លើយ៦៩៖ លោកថា ព្រោះកន្លែងនេះ គឺជាកន្លែងសម្រាលទោស ហើយមានអ្នកទោសខ្លះមកពីក្រាំងតាចាន់ ត្រូវបានបញ្ជូនមកដាក់នៅអង្គរកានេះ។ សំណួរ៧០៖ តើគុកនៅអង្គរកាមានទំហំប្រហែលប៉ុន្មាន? ចម្លើយ៖ ប្រហែលជា៦ ទៅ៧ម៉ែត្រ សង់អំពីឈើទាំងអស់។ សំណួរ៧១៖ តាមលោកដឹង តើអ្នកណាមានសិទ្ធិបញ្ជាឲ្យចាប់ខ្លួន

មនុស្សនៅក្នុងស្រុកត្រាំកក់ទាំងមូល? ចម្លើយ៖ តាមគំនិតខ្ញុំ គឺថ្នាក់ឃុំ ជាអ្នកចេញបញ្ជាឲ្យចាប់មនុស្ស ហើយកសាងសំណុំរឿង រួចបញ្ជូនមកថ្នាក់ស្រុក។ សំណួរ៧៥៖ តើលោកដឹង ហេតុអ្វីបានជាលោកដឹងថាថ្នាក់ឃុំមានសិទ្ធិចាប់ខ្លួនមនុស្ស។ ចម្លើយ៖ ដំបូង គឺខាងសហករណ៍រាយការណ៍មកខាងឃុំ ហើយឈ្លបជាអ្នកទៅចាប់មនុស្សបញ្ជូនមកគុកក្បែរអង្គរកា។ ហើយប្រសិនបើអ្នកទោសធ្ងន់ គេនឹងបញ្ជូនទៅក្រាំងតាចាន់ ប៉ុន្តែប្រសិនបើស្រាល គេនឹងដាក់នៅអង្គរកា។ ខ្ញុំដឹងរឿងនេះ ដោយសារថ្នាក់ឃុំ គេនិយាយប្រាប់ខ្ញុំ"។ សូមបញ្ចប់ការដកស្រង់។

តើលោកដឹងទេថា គុកអង្គរកា គុកដែលនៅជិតអង្គរកានេះ គឺនៅស្ថិតនៅក្រោមបញ្ជាផ្ទាល់ពីប្រធាន ជាប្រធានសន្តិសុខស្រុក១០៥ ឬក៏ស្ថិតនៅក្រោមបញ្ជារបស់មន្ទីរសន្តិសុខក្រាំងតាចាន់ ឬក៏ទាំងពីរតែម្តង? គឺមានន័យថា ជួនកាលទៅ អាន់ គាត់ចេញបញ្ជាផ្ទាល់ទៅឲ្យ ម៉េង តែម្តង ជាប្រធានគុកនៅអង្គរកានោះ។

**ឆ៖** បាទត្រង់ចំណុចហ្នឹង ខ្ញុំអត់ដឹងទេបាទ។

[០៩:៥១:៤៨]

**ស៖** អម្បាញ់មិញនេះ ខ្ញុំៗគ្រាន់តែអានចម្លើយរបស់លោកទេ លោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់ដឹងថាតើលោកនាំសំបុត្រទៅមន្ទីរទៅគុកអង្គរកាសម្រាប់ដាក់អ្នកទោសស្រាលនេះ ប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំគ្រាន់បានទៅកន្លែងហ្នឹងបានពីរដងបាទ។

**ស៖** លោកបានឆ្លើយថាឃើញអ្នកទោសត្រូវបានគេឃុំ និង ដាក់គេដាក់ខ្នោះ។ អ៊ីចឹងតើលោកមានឃើញទេថា អ្នកទោសនៅពេលនុង គឺប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** អ្នកទោសដាក់កន្លែងហ្នឹង ដូចជាបញ្ហាសង្គមអី ដូចជាចាប់រំលោភ ឬមួយក៏ចាប់ក្មេងរំលោភ មួយទៀតលួចមាន់ លួចដកដំឡូង បាទ។

**ស៖** នៅពេលដែលលោកទៅកន្លែងនោះបានពីរដងនុង លោកមានបានឃើញ ម៉េង សួរចម្លើយអ្នកទោសទេ?

**ឆ៖** បាទ ម៉េង ខ្ញុំមិន -- គ្រាន់តែបានស្គាល់ទេ ប៉ុនមិនដែលបានជួបមុខទេបាទ។ ទៅពីរដងហ្នឹង អត់ជួបទាំងពីរដងបាទ។

**ស៖** លោកធ្វើការបែងចែកមានជាអ្នកទោសស្រាលដែលគេឃុំនៅអង្គរកា ហើយអ្នកទោសធ្ងន់គឺគេបញ្ជូនមកក្រាំងតាចាន់។ ចុះអ្នកថ្មី ឬក៏អ្នក១៧ មេសា ហើយមន្ត្រីរដ្ឋការនិងទាហាន លន់ នល់ នោះ

គេស្ថិតនៅក្នុងចំណោមអ្នកទោសធ្ងន់ដែរឬទេដែលត្រូវគេបញ្ជូនទៅមន្ទីរក្រាំងតាចាន់នុង បើតាមការកត់សម្គាល់របស់លោកនោះ?

[០៩:៥៤:១៤]

**ឆ៖** កាលសម័យនុងគេនិយាយថា មិនថា១៧, ១៨ ទេ គេថាក្បាលអ្នកណា សក់អ្នកហ្នឹង។ ប៉ុណ្ណឹងបាទ។

**ស៖** ដូច្នេះគឺអត់មានការបែងចែករវាងអ្នកមូលដ្ឋានដែលនៅស្រុកត្រាំកក់ ហើយនិងអ្នកដែលគេជម្លៀសចេញពីទីក្រុង ដូចជាទីក្រុងភ្នំពេញ ឬក្រុងតាកែវទេ។ មែនទេអ៊ីចឹង អត់មានការបែងចែកអ៊ីចឹងទេឬ?

**ឆ៖** កាលនោះ គេបែង មុនដំបូងគេបែងចែក១៧, ១៨ ដល់ពេលមានបញ្ហា គេអត់មានបែងចែក គេថាក្បាលអាណាសក់អាហ្នឹង បាទ។

**ស៖** តើលោកដឹងទេថា អ្នកទោសស្រាលដែលបានរំលោភ ឬក៏បានបង្កបញ្ហាសង្គម ត្រូវបានគេឃុំនៅអង្គរកាហ្នឹង ហើយពេលឃុំហើយហ្នឹង គេធ្វើយ៉ាងម៉េចដែរ ចំពោះអ្នកទោសស្រាលទាំងអស់ហ្នឹង?

**ឆ៖** បាទ គេប្រជុំអប់រំហើយ ឲ្យមកសហករណ៍វិញបាទ។

**ស៖** ដូច្នេះតាមចម្លើយលោកហ្នឹង គឺថា អ្នកទោសនៅអង្គរកាហ្នឹងមិនត្រូវបានគេសម្លាប់ចោលទេ។ លោកមានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

លោកប្រធាន មុននឹងសម្រាកនេះ ខ្ញុំសូមអនុញ្ញាត ឯកសារមួយទៅសាក្សី ហើយនិងសុំបញ្ចាំងនៅអេក្រង់ផងដែរលោកប្រធាន។ គឺឯកសារដែលទាក់ទងទៅនឹងមន្ទីរអង្គរកា គឺឯកសារ E3/4093 អង់គ្លេសគឺ 00831486, ជាភាសាបារាំងគឺ 00729674, ជាភាសាខ្មែរគឺ 00-- មានពីរទំព័រ គឺ 00270786 ទៅដល់ 87។ លោកប្រធាន ខ្ញុំសូមប្រគល់ឯកសារនេះទៅសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៥៧:៥៩]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ គឺជាសំបុត្រមួយដែលផ្ញើដោយ សាន់ ជាភាសាបារាំងគេមើលទៅឃើញថា អានមិនច្បាស់ទេ ប៉ុន្តែភាសាអង់គ្លេស គេអានដាច់ថា ឈ្មោះសាន–សានផ្ញើទៅបង ឈឿន (ឈ ស្រះ ឿ និង ន)។ ជាទីស្នេហា ចុះថ្ងៃទី៧ សីហា (អត់មានឆ្នាំទេ)។ ខ្ញុំសូមអានសារនេះ "បងឈឿន ជាទីស្នេហា! ចំពោះមនុស្សអ្នកទោសដែលផ្ញើមកពីជាងទង សូម ខ្ញុំសូម -- កូនក្មេងដែលនៅជាប់ហ្នឹងម្ដាយរបស់ពួកគេ បើសិនជាកូននោះធំៗ ត្រូវបញ្ជូនទៅកងចល័ត ហើយនិងទៅកងកុមារ។ រួចហើយត្រូវឲ្យពួកក្មេងៗទាំងអស់នោះចាំនៅទីនោះ យើងយកតែម្ដាយទៅបានហើយ។ ហើយបើសិនជាក្មេងៗទាំងអស់នោះមិនព្រមផ្ដាច់ខ្លួនពីម្ដាយពួកវាទេ ទៅយកវាទៅដែរទៅ កុំបាច់រវីរវល់ច្រើន។ ហើយនៅពេលដែលសួរចម្លើយចប់ហើយ ត្រូវបោសសម្អាតទាំងអស់។ ចំពោះស្ត្រីមេម៉ាយដែលមកពីត្រពាំងធំខាងជើង សព្វថ្ងៃនេះ ឥឡូវពួកគេនៅ -- ពួកគាត់នៅផ្ទះសមមិត្ត ម៉េង នៅ ម៉េង ហើយអ៊ីចឹងសូមឲ្យបោសសម្អាតទាំងអស់ ហើយបោសសម្អាតទាំងអស់ចុះ។ ហត្ថលេខា សាន មួយពាន់ប្រាំបួនរយ -- ថ្ងៃទី៧ ខែ៨"។ បើអ៊ីចឹងឈ្មោះ សាន នេះសូមឲ្យបោសសម្អាតម្ដាយ ហើយនិងកូនក្មេងនេះ គាត់ហ្នឹងគឺជាប្រធានចៅហ្វាយស្រុកត្រាំកក់មែនទេ? គឺជាមនុស្សតែមួយ សាន ហ្នឹង ហើយនិងយើងខ្ញុំអានហ្នឹង ហើយនិងចៅហ្វាយស្រុកហ្នឹងមនុស្សតែមួយឬយ៉ាងម៉េច?

**ឆ៖** បាទ ចៅហ្វាយស្រុកហ្នឹងឈ្មោះតែមួយបាទ។

**ស៖** តើលោកស្គាល់ បងឈឿន ហ្នឹងទេ ដែល សាន គាត់ផ្ញើសំបុត្រនេះទៅឲ្យនេះ?

**ឆ៖** បាទស្គាល់។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថាគាត់ហ្នឹងជាអ្នកណា? ហើយមានមុខងារអីដែរនៅសម័យនោះ?

[១០:០១:០៩]

**ឆ៖** ឈឿន ហ្នឹងនៅក្រាំងតាចាន់ដែរ តែផ្នែកបក្សៗទាំងប្រាំមួយរូបហ្នឹងបាទ។

**ស៖** បាទ នៅសំបុត្រនេះ សាន ផ្ញើជូនទៅបក្ខជនទាំងប្រាំមួយនាក់ថា "ត្រូវបោសសម្អាតមេម៉ាយដែលមកពីត្រពាំងធំខាងជើងដែលនៅនឹង ម៉េង"។ តើបើតាមចៅហ្វាយស្រុកនោះ អ្នកដែលត្រូវបោសសម្អាតទាំងអស់នោះ អ្នកទាំងអស់នោះត្រូវបានគេសម្លាប់នៅមន្ទីរអង្គរកា ឬក៏នៅមន្ទីរក្រាំងតាចាន់?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាមានការបកប្រែខុសអ្វីក៏មិនដឹងដែរ ប៉ុន្តែខ្ញុំមិនដឹងថាតើព្រះរាជអាជ្ញាគាត់និយាយអ្វីអំពីភាពមិនអាចអានបាននៃភាសាខ្មែរនុ៎ង? ខ្ញុំគិតថាប្រហែលជាគាត់និយាយថាគាត់មិនអាចអានឈ្មោះ សាន ជាភាសាអង់គ្លេស ប៉ុន្តែអានេះមិនមែនជាចំណុចយោងនោះទេ អ្វីដែលសំខាន់គឺថា តើឯកសារដើម ឬក៏ឯកសារថតចម្លងច្បាប់ដើមនោះ វាមានលក្ខណៈយ៉ាងដូចម្តេច។ ខ្ញុំមិនច្បាស់ថាតើព្រះរាជអាជ្ញាគាត់និយាយយ៉ាងដូចម្តេច? ថាតើគាត់មិនអាចអានឈ្មោះ សាន ជាភាសាខ្មែរ ឬមួយក៏យ៉ាងម៉េចដែរ?

[១០:០២:៥២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ លោកប្រធាន អ្វីដែលខ្ញុំនិយាយអម្បាញ់មិញនេះ ខុសពីនេះ។ ខ្ញុំនិយាយថា មានឯកសារដើមជាភាសាខ្មែរ ហើយការអ្នកបកប្រែទៅជាភាសាបារាំងនោះ គាត់ថាមិនច្បាស់ទេ អក្សរនេះអានមិនច្បាស់ទេ អ្នកដែលចុះហត្ថលេខានេះ។ ក៏ប៉ុន្តែអ្នកបកប្រែទៅភាសាអង់គ្លេស គាត់អានដាច់ គាត់បកប្រែថាឈ្មោះ សាន។ អ៊ីចឹងបើនៅជាភាសាខ្មែរនេះ ដូចមិនមានមន្ទិលសង្ស័យអ្វីទេ តាមពិតមានមន្ទិលសង្ស័យក្នុងការបកប្រែទៅភាសាបារាំង និងភាសាអង់គ្លេស។ អ៊ីចឹងខ្ញុំគិតថា ដូចជាមិនមានបញ្ហាអីទេ។ ខ្ញុំអាចបន្តចោទសំណួរទៀតបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញទៅមុខទៀតចុះ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទសូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** អ៊ីចឹងយើងមានសំបុត្រមួយរបស់ សាន ដែលផ្ញើជូនទៅនឹងសមាជិកនៃក្រុមនៅក្រាំងតាចាន់ ហើយមានការចារថា ទាក់ទងទៅនឹងមេម៉ាយនៅៗត្រពាំងធំខាងជើង ដែលនៅផ្ទះ ម៉េង។ ទាក់ទងនារីអស់នេះ មេម៉ាយទាំងអស់នេះ គឺថា សាន សុំឲ្យ ម៉េង បោសសម្អាតឲ្យស្អាត។ អ៊ីចឹងខ្ញុំសួរលោកថាតើ

ការកាប់សម្លាប់មេម៉ាយទាំងអស់នេះ ធ្វើត្រូវបានធ្វើនៅមន្ទីរអង្គរកា ឬក៏នៅមន្ទីរក្រាំងតាចាន់?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ត្រង់ចំណុចនេះ ខ្ញុំអត់ដឹងទេបាទ។

[១០:០៥:៤១]

**ស៖** ពាក្យ "បោសសម្អាត" ដែលប្រើនៅទីនេះ គឺថាសួរថាពាក្យ បោសហ្នឹង បោសសម្អាតនេះ ដូចគ្នា ឬយ៉ាងម៉េច? ព្រោះអម្បាញ់មិញ ពេលដែលខ្ញុំសួរលោក លោកឆ្លើយថាបោសសម្អាតនេះ គឺស្មើនឹងកម្ទេច។ មានន័យយ៉ាងម៉េចដែរ ពាក្យ "បោសសម្អាត" ដែលសរសេរនៅក្នុងសំបុត្រនេះ?

**ឆ៖** បាទ ពាក្យ "បោសសម្អាត" នេះ គេសម្លាប់ចោលតែម្តង ប៉ុនខ្ញុំអត់ជួបប្រទះទេនារីមានកូន ពោះម៉ាយហ្នឹង បាទ។

**ស៖** សូមអរគុណ។ ខ្ញុំមានឯកសារមួយទៀត ដើម្បីដាក់ជូនដល់លោក គឺឯកសារ E3/4099។ គឺជាសេចក្តី កំណត់ហេតុប្រជុំដែល ម៉េង ផ្ញើទៅអង្គការ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់ ហើយផ្តល់ឯកសារនេះទៅសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១០:០៥:១៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទ ជាភាសាខ្មែរគឺ ERN00220976 បន្តទៅដល់ 77 ហើយភាសាបារាំងគឺ 0085 8037, ជាភាសាអង់គ្លេសគឺ 00322122។ បាទ នេះគឺជាកំណត់ហេតុរបាយការណ៍ដែល ម៉េង ផ្ញើ "នៅថ្ងៃទី១០ មករា ឆ្នាំ១៩៧៧ ដែលគាត់សុំឲ្យអង្គការពិនិត្យករណីទាំងបួននាក់ដែលផ្ញើមកពីឃុំ ហើយឲ្យសួរចម្លើយ ហើយនិងតាមដានមើល។ ក្នុងចំណោមមនុស្សទាំងបួននាក់នេះ មនុស្សទី១ ឈ្មោះ ថាច់ អង់ មានសរសេរថាពួកគាត់នេះ ជាខ្មែរកម្ពុជាក្រោម ហើយជាទាហានឋាន:ព្រឹន្ទបាល ដែលបានលួចដំឡូង។ ម្នាក់ទៀតឈ្មោះ សៅ ផាន -- សៅ ផន (បាទ សូមទោស) ដែលជាព្រឹន្ទបាលដូចគ្នា ដែលបានអួតថាមានលុយ១.០០០រៀល ហើយនិងមានលិខិតធ្វើដំណើរ -- ១០.០០០រៀល បាទ សូម

ទោស"។ អ៊ីចឹងខ្ញុំសួរថា ម៉េង តើ ម៉េង ដែលជាអ្នកសរសេរឯកសារហ្នឹងគឺជា ម៉េង ដែលប្រធានគុកអង្គរកាហ្នឹង ឬមិនមែនទេ?

**លោក វ៉ាន់ សឿន៖**

**ផ៖** បាទ ត្រង់ចំណុចហ្នឹង ខ្ញុំអត់ដឹងទេបាទ។

**ស៖** នៅក្នុងរបាយការណ៍នេះ គេនិយាយអំពីអតីតទាហាន លន់ នល់ ម្នាក់។ អ៊ីចឹងខ្ញុំសួរលោកថានៅក្រាំងតាចាន់ហ្នឹង លោកមានដឹងថាមានអតីតមន្ត្រីរដ្ឋការរបបលន់ នល់ ឬក៏ទាហានលន់ នល់ ដែលជាអ្នកទោសដែរឬទេ?

[១០:០៨:៤៨]

**ផ៖** ត្រង់ចំណុចហ្នឹងខ្ញុំគ្រាន់ថា រយៈពេលកន្លងមក ខ្ញុំផ្នែកការពារមិនបានដឹងថាអ្នកនេះមកពីនេះ អ្នកនោះមកពីនោះទេបាទ។

**ស៖** ខ្ញុំសូមសំណួរចូលប្រធានបទមួយទៀតមុននឹងសម្រាក។ ទាក់ទងទៅនឹងការពិពណ៌នាអគារ និងទីតាំងនៅមន្ទីរក្រាំងតាចាន់ លោកបាននិយាយថាមានកាំភ្លើងធំ ខ្ញុំដកស្រង់ឯកសារគឺ E319.1.33 សំណួរលេខ១៧២៖ "តើលោកមានទាហានដែរឬទេនៅពេលដែលលោកយាមអ្នកទោស?" លោកឆ្លើយថា "ទេ ខ្ញុំយាមអ្នកទោស ក៏ប៉ុន្តែខ្ញុំមិនមានកាំភ្លើងទេ ពីព្រោះកាំភ្លើងត្រូវស្ថិតនៅក្នុងឃ្លាំងកាំភ្លើង នៅពេលថ្ងៃ ឃ្លាំងគ្រាប់"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំមិនដឹងថាជាភាសាខ្មែរគេបកប្រែយ៉ាងម៉េចទេ ក៏ប៉ុន្តែជាធម្មតាជាកន្លែងដែលគេដាក់អាវុធ។ អ៊ីចឹង ខ្ញុំសូមសួរថាតើឃ្លាំងគ្រាប់នេះ ឬក៏កាំភ្លើងនៃមន្ទីរក្រាំងតាចាន់នេះនៅកន្លែងណា បើធៀបទៅនឹងការិយាល័យរបស់ តាអាន់ ឬមន្ទីររបស់ តាអាន់ ឬក៏ធៀបទៅនឹងអគារដាក់អ្នកទោសនោះ?

[១០:១០:៣២]

**ផ៖** បាទ ពាក្យថាកាំភ្លើងដាក់នៅក្នុងឃ្លាំងនេះ ពាក្យថាកាំភ្លើងគេ យប់ឡើងគេចែកគ្រប់ដៃបាទ។ គេចែកគ្រប់ដៃ ព្រលឹមឡើងដាក់ចូលក្នុង គេទុកក្នុងឃ្លាំងចាក់សោរវិញបាទ។

**ស៖** ចុះពេលយប់នោះ គេឲ្យកាំភ្លើងលោកកាំភ្លើងអីគេ គេឲ្យលោកមានកាំភ្លើងយើងបាញ់ផ្ទុះហ្នឹង ឬគ្រាន់តែជាកាំបិតពូថៅអីទេ?

**ផ៖** បាទ កាំភ្លើងនោះគឺកាំភ្លើងអាកា និង អឹមសី បាទ។

**ស៖** បាទ នៅក្នុងកំណត់ស្តាប់ចម្លើយលោកដដែល លោកបានឆ្លើយនៅចម្លើយ១៧៧។ អ៊ីចឹង

“សំណួរគឺសួរថាតើលោកមានឮសំឡេងអ្វីទេ ពេលសម្លាប់ម្ដងៗ តើលោកធ្លាប់ឮសំឡេងអ្វីទេ? ខ្ញុំឮសំឡេងគេវាយមនុស្ស ប៉ុន្តែខ្ញុំមិនឮសំឡេងមនុស្សស្រែកនោះទេ ពីព្រោះអ្នកទោសពុំមានកម្លាំងស្រែកនោះទេ។ គេសម្លាប់មនុស្សដោយវាយនឹងត្បូងចប ហើយនិងគល់ឫស្សី”។ តើគល់ឫៗស្សីនេះដែលគេប្រើសម្រាប់ ឬត្បូងចបវាយហ្នឹង គេដាក់វានៅក្នុងឃ្លាំងដាក់កាំភ្លើងដែរឬទេ?

**ឆ៖** បាទ អត់ទេបាទ គេដាក់ខាងក្រៅបាទ។

[១០:១២:៣៥]

**ស៖** តើលោកឃើញត្បូងចប ហើយនិងឫស្សីដែលៗគេប្រើនៅពេលសម្លាប់មនុស្សដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលឃើញទេបាទ។ ខ្ញុំនៅខាងក្រៅបាទ។

**ស៖** ក៏ប៉ុន្តែ លោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតថា គេៗវាយសម្លាប់មនុស្សនឹងត្បូងចប ហើយនិងគល់ឫស្សី។ តើមានដាវដែលគេរក្សាទុកនៅក្នុងឃ្លាំងអាវុធ ឬក៏នៅខាងក្រៅដែរឬទេ ដែលគេប្រើសម្រាប់សម្លាប់មនុស្សនោះ?

**ឆ៖** បាទ អត់មានទេបាទ អត់ដែលឃើញទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ លោកសហព្រះរាជអាជ្ញា។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីផងមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭកបញ្ជាក់ឡើងវិញថា ការសេចក្តីណែនាំអនុវត្តស្តីពីការតាំងសំណួរខ្លី ចៀសវាងសំណួរវែងអន្លាយសាំញ៉ាំ គឺហាក់ដូចនៅតែមាននៅឡើយទេ។ បាទ គប្បីរៀបចំពិនិត្យលទ្ធភាពនេះវិញឲ្យបានល្អ ដើម្បីឲ្យគោលដៅនៃការឆ្លើយតបនឹងសំណួរក្តាប់សំណួរឲ្យបានច្បាស់ ហើយនិងគាត់អាចឆ្លើយតបបានច្បាស់លាស់ ងាយយល់ ហើយនិងអាចឆ្លើយតបបាន មានប្រយោជន៍ក្នុងការស្វែងរកការពិត។

បាទ សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន ខ្ញុំនឹងគោរពតាមការណែនាំ លោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី មុននឹងពេលសម្រាកហ្នឹង យើងនិយាយអំពីឃ្លាំងដាក់អាវុធនៅពេលថ្ងៃ។ បើសិនជាខ្ញុំមិនច្រឡំទេ លោកមិនទាន់បានឆ្លើយបានច្បាស់លាស់ទេថា ឃ្លាំងដាក់អាវុធនោះនៅកន្លែងណា? តើបើធៀបទៅនឹងមន្ទីររបស់ តាអាន់ ហ្នឹងឃ្លាំងហ្នឹងនៅឆ្ងាយពីមន្ទីរ តាអាន់ ឬក៏យ៉ាងណា?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ សូមបញ្ជាក់ថា ឃ្លាំងដាក់អាវុធនេះមិនមែនឃ្លាំងអាវុធធំដុំ កាំភ្លើងតូច កាំភ្លើងធំទេ គឺឃ្លាំង គេធ្វើដូចជាឡាំងអ៊ីចឹង។ ព្រលឹមឡើង យកទៅដាក់ក្នុងហ្នឹង គេចាក់សោតែម្តងបាទ។

**ស៖** តើកេះឈើដាក់គ្រាប់ហ្នឹងនៅកន្លែងណាដែរ? នៅក្នុងមន្ទីរណាដែរ នៅឆ្ងាយពីមន្ទីរតាអាន់ ឬក៏ម៉េច?

**ឆ៖** បាទ នៅក្នុងបរិវេណហ្នឹងតែម្តង។

**ស៖** បាទ ក៏ប៉ុន្តែមិនសូវច្បាស់។ តើ តាអាន់ហ្នឹង គាត់អ្នកដែលថែរក្សាអាវុធទាំងហ្នឹង ឬក៏អ្នកផ្សេង?

[១០:៣៦:៣២]

**ឆ៖** គាត់នៅគ្រប់គ្រងទាំងអស់ក្នុងហ្នឹង បាទ។

**ស៖** បាទ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ឯកសារ D40/23 នៅERN ជាភាសាខ្មែរគឺ 00165354 ដល់ 55, ជាភាសាបារាំងគឺ 00490909, អង់គ្លេសគឺ 00223210។ បាទ ខ្ញុំសូមដកស្រង់៖ “ខ្ញុំឃើញគេចងអ្នកទោស ហើយគេវៃពេលសួរចម្លើយ ដើម្បីបង្ខំឲ្យគេឆ្លើយ ហើយក្រោយមកទៀត លោកនិយាយថា គេវៃអ្នកនៅពេលសួរចម្លើយ ដោយប្រើដំបង ហើយនិងខ្សែតី ឬក៏រំពាត់ផ្តៅ។” តើខ្សែតី ឬក៏រំពាត់ផ្តៅ ហើយនិងដំបងដែលគេប្រើវៃសួរចម្លើយអ្នកទោសនោះ គេរក្សាទុកនៅកន្លែងណា? នៅក្នុងឡាំងដាក់អាវុធហ្នឹង ឬក៏នៅកន្លែងផ្សេង?

**ឆ៖** បាទ មិនមែនដាក់ជាមួយគ្នាទេ។ អាវុធ ដាក់ដោយកន្លែងអាវុធ គឺកន្លែងដំបងវៃសួរចម្លើយហ្នឹងនៅកន្លែងសួរចម្លើយតែម្តងបាទ។

**ស៖** ហើយនៅកន្លែងហ្នឹង តើសួរថាកន្លែងសួរចម្លើយនៅកន្លែងណាដែរ បើធៀបទៅនឹងមន្ទីរតាអាន់ ហើយនិងអគារដាក់អ្នកទោស តើកន្លែងដាក់អាវុធហ្នឹងនៅខាងណាធៀបនឹងមន្ទីរតាអាន់ហ្នឹង នៅខាងលិច នៅខាងកើតមន្ទីរតាអាន់ ឬក៏យ៉ាងណា?

[១០:៣៩:០៣]

**ឆ៖** បាទ នៅក្នុងបរិវេណហ្នឹងចម្ងាយ៣០ម៉ែត្រពីគ្នាបាទ។

**ស៖** អ៊ីចឹង ខ្ញុំសួរថានៅខាងណា ខាងកើត ខាងលិច ខាងជើង ត្បូង?

**ឆ៖** បាទ នៅខាងត្បូង។

**ស៖** តើមានចង្ក្រានបាយនៅក្បែរកន្លែងសួរចម្លើយទេ?

**ឆ៖** បាទ ចង្ក្រានបាយនៅខាងកើត សួរចម្លើយ បាទ។

**ស៖** តើកន្លែងសួរចម្លើយនេះជាអគារមួយមានជញ្ជាំងបិទជិត ឬក៏មានជញ្ជាំងដែលគេអាចមើលឃើញបានពីខាងក្រៅ?

**ឆ៖** បាទជញ្ជាំងកន្លែងសួរចម្លើយហ្នឹង មានជញ្ជាំងមួយកំណាត់ អត់មួយកំណាត់ គេបិទជិតមួយកំណាត់។

**ស៖** បាទឥឡូវ ខ្ញុំសូមដកស្រង់ពាក្យសម្តីរបស់ ស៊ីម ដែលជាអ្នកធ្វើការជាមួយលោកពីមុននុងគឺនៅក្នុងឯកសារ D40/20, ERN ជាភាសាខ្មែរគឺ 00165334, ERN ជាភាសាបារាំងគឺ 00524322 ហើយជាភាសាអង់គ្លេសគឺ 004433 -- ខ្ញុំមើលទៅឃើញលេខ ERN របស់ខ្ញុំដូចលើសអ៊ីចឹង ប្រហែល

ជា00443357។ សំណួរគឺសួរទៅ ស៊ឹម៖ "តើលោកដឹងថាគេសួរចម្លើយអ្នកទោសយ៉ាងម៉េចដែរ? ចម្លើយ៖ ពេលដែលខ្ញុំដាំបាយនៅជិតកន្លែងគេសួរចម្លើយនុ៎ង ខ្ញុំតែងតែលួចមើលគេសួរចម្លើយនុ៎ង។ អ៊ីចឹង ខ្ញុំបានឃើញគេសួរចម្លើយដែលមានវ៉ៃ ហើយជួនកាលគេច្រកថង់ស្បោង។ ហើយគេសួរចម្លើយដោយវ៉ៃ។ អ្នកទោសខ្លះ គឺត្រូវបានគេវ៉ៃរហូតដល់ស្លាប់នៅនឹងកន្លែងសួរចម្លើយតែម្តង"។ សូមបញ្ចប់ការដកស្រង់។ តើលោកយល់ស្របជាមួយ ស៊ឹម ដែរឬទេ? ហើយតើលោកខ្លួនឯងផ្ទាល់ហ្នឹងបានសង្កេតឃើញដែរថា នៅក្នុងពេលសួរចម្លើយនោះមានការប្រើថង់ប្លាស្ទិក ដោយគ្របបន្លប់ដង្ហើមអ្នកទោស។

[១០:៤២:៣៨]

**ឆ៖** បាទ ខ្ញុំធ្លាប់ចូលដាំបាយបីបួនដងដែរបាទ ធ្លាប់ឃើញអ៊ីចឹងដែរបាទ។

**ស៖** តើលោកមានធ្លាប់ឮថ្នាក់ដឹកនាំនៅមន្ទីរក្រាំងតាចាន់និយាយអំពីថាវិធីសាស្ត្រត្រជាក់ ក្តៅ ដែលពេលគេប្រើនៅពេលសួរចម្លើយដែរឬទេ គឺវិធីសាស្ត្រត្រជាក់ ហើយនិងក្តៅ?

**ឆ៖** បាទអត់ទេ។

**ស៖** បាទខ្ញុំដឹងថាលោកធ្លាប់បាននិយាយថាលោកមិនដែលមានវត្តមាននៅពេលដែលការសម្លាប់មនុស្សទេ ពីព្រោះគេឲ្យលោកយាមនៅបរិវេណខាងក្រៅមន្ទីរក្រាំងតាចាន់ នៅពេលដែលគេសម្លាប់មនុស្ស។ ក៏ប៉ុន្តែតើលោកដឹង ទោះយ៉ាងណាក៏លោកដឹងដែរថា គេសម្លាប់អ្នកទោសនោះនៅកន្លែងណា? ហើយបន្ទាប់មក គេយកទៅកប់នៅកន្លែងណាដែរ? ឧទាហរណ៍ដូចជា នៅៗ -- បើធៀបទៅនឹងកន្លែងសួរចម្លើយនោះ តើគេសម្លាប់មនុស្សនៅខាងណា ខាងកើត ខាងជើង ខាងត្បូង នៃសម្លាប់ ហើយ យកទៅកប់នោះ តើសម្លាប់នៅកន្លែងណា? កប់នៅកន្លែងណា?

**ឆ៖** បាទ ក្នុងរង្វង់ៗបរិវេណមន្ទីរហ្នឹងតែម្តងបាទ។

**ស៖** បាទសូមអរគុណ។ តើមានកន្លែងច្រើន ហើយតើតាមពេលវេលាដូរកន្លែងតាមពេលវេលា តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា សាកសពអ្នកទោសទាំងអស់នោះត្រូវបានគេកប់នៅទិសខាងណា ខាងលិច កើត ជើង ត្បូង នៃបរិវេណអគារហ្នឹង គុកហ្នឹងបាទ សុំទោស?

**ឆ៖** ខាងត្បូងចង្ក្រានបាយតែម្តង បាទ ជួរខាងត្បូង។

**ស៖** បាទ សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកមួយទៀតគឺឯកសារ D40/20 នៅទំព័រជាភាសាខ្មែរ គឺERN 00165353, ជាភាសាបារាំងគឺ 00490907, ជាភាសាអង់គ្លេសគឺ 00223209 គេចោទសំណួរលោកដូចតទៅនេះ សូមដកស្រង់៖ "ក្រៅពីការងារដែលលោកបានលើកឡើងទាំងអស់

នេះ តើលោកមានចាំថាគេបានឲ្យលោកធ្វើការងារអីផ្សេងទៀតទេ? ចម្លើយ៖ ខ្ញុំយាមនៅខាងក្រៅ។ នៅពេលដែលគេសម្លាប់អ្នកទោសនៅក្នុងមន្ទីរនេះ។ សំណួរ៖ យ៉ាងម៉េចបានជាលោកដឹងថា នៅពេលដែលគេឲ្យទៅយាមនៅខាងក្រៅលោកដឹងថាមានគេសម្លាប់អ្នកទោសនៅខាងក្នុង? ចម្លើយ៖ ដឹងដោយសារគេប្រជុំ"។ សូមបញ្ចប់ការដកស្រង់។ តើអ្នកណាកោះប្រជុំ ហើយអ្នកណាជាអ្នកដឹកនាំប្រជុំនៅពេលដែលមានការកាប់សម្លាប់មនុស្ស?

[១០:៤៦:៥០]

**ឆ៖** បាទ តាអាន់ តែម្តងបាទ។

**ស៖** តើនៅក្នុងកិច្ចប្រជុំទាំងអស់នោះ តាអាន់ បាននិយាយអ្វីខ្លះទាក់ទងទៅនឹងការសម្លាប់មនុស្សនេះ?

**ឆ៖** គេប្រជុំបក្ខជនហើយ បានគេមកជម្រាបដល់អ្នកការពារខាងក្រៅថា យាមកាមឲ្យស្រួលបួល បាទ។ កុំឲ្យមានការផ្តោះផ្តោយឲ្យសោះ បាទ។

**ស៖** បើលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកមួយទៀត គឺឯកសារ E319.1.33 "ចម្លើយ២១២ សំណួរសួរថា តើក្មេងៗត្រូវបានសម្លាប់ដែរ ឬក៏យ៉ាងណា? ចម្លើយ៖ ជួនគេសម្លាប់ដែរ ជួនគេដោះលែងជាមួយម្តាយពួកគេវិញ"។ សូមបញ្ចប់ការដកស្រង់។ ពេលដែលលោកនិយាយថា ជួនកាលគេសម្លាប់ ជួនកាលគេដោះលែងជាមួយម្តាយខ្លួនវិញនោះតើ មានម្តាយ ហើយនិងក្មេងៗត្រូវគេដោះលែង ត្រូវសម្លាប់ច្រើនជាងម្តាយៗ និងក្មេងៗដែលត្រូវគេដោះលែងនៅមន្ទីរក្រាំងតាចាន់ ឬក៏យ៉ាងណា? ដោះលែងច្រើនជាង ឬក៏សម្លាប់ច្រើនជាង?

**ឆ៖** ក្នុងហ្នឹងខ្ញុំមិនបានចាំច្បាស់ដែរ បាទ។

**ស៖** នៅពេលដែលលោកនិយាយពីក្មេងៗដែលត្រូវបានគេដោះលែងជាមួយម្តាយរបស់ពួកគេនោះ តើលោកមានឧទាហរណ៍អីច្បាស់លាស់ទេ? ឧទាហរណ៍ដូចឈ្មោះ អ្នកទោសដែលត្រូវបានគេដោះលែងនោះ លោកអាចផ្តល់ឈ្មោះជូនតុលាការបានខ្លះទេ?

**ឆ៖** បាទ ដូចឈ្មោះ យាយញ៉ ហ្នឹង ហើយនិង យាយវ៉ាត់ ហើយកូនយាយញ៉ ហ្នឹង ឈ្មោះ ខា ឈ្មោះ ខុម បាទ។ ហើយក្រោយមកទៀតមក ឃើញឈ្មោះកូនយាយវ៉ាត់ហ្នឹង ឈ្មោះ បេ បាទមានតែប៉ុណ្ណឹងទេ។

[១០:៤៩:៤១]

**ស៖** អ៊ីចឹងបើសិនជាខ្ញុំសង្ខេបទៅ អ្នកដែលគេត្រូវបានដោះលែង ក្មេងៗដែលគេដោះលែងជាមួយម្ដាយនោះ សរុបទៅមានតែពីរបីនាក់តែប៉ុណ្ណោះទេ បើយ៉ាងច្រើនបំផុតនោះ ១០នាក់អស់ហើយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** អ្នកធ្វើការជាមួយលោក ស្រី ថន ហៅ ឌុច ហៅ សារ៉ាត់។ គាត់បានឆ្លើយនៅក្នុងចម្លើយរបស់គាត់ D232/93 សំណួរគេសួរទៅគាត់កាលនោះ គឺសំណួរលេខ៥៣៖ "តើអ្នកទោសដែលត្រូវបានគេដោះលែងដែរឬទេ? ចម្លើយ៖ មានខ្លះដែរ គឺគេដោះលែងឲ្យទៅផ្ទះវិញ។ អ្នកទោស៩៩ភាគរយត្រូវបានគេកម្ទេច"។ សូមបញ្ចប់ការដកស្រង់។ តើលោកយល់ស្របជាមួយនឹង ឌុច ដែរឬទេថាអ្នកទោសភាគច្រើននោះ ច្រើនលើសលប់ត្រូវបានគេសម្លាប់តែម្ដងនៅនឹងកន្លែង?

**ឆ៖** បាទ យល់ស្រប។

**ស៖** ទាក់ទងទៅនឹងភាគរយតិចបំផុតដែលនៅសល់នៅសេសសល់ តើអ្នកដែល អ្នកទោសដែលនៅសេសសល់នេះត្រូវបានគេដោះលែង ឬក៏ត្រូវបានបញ្ជូនទៅកន្លែងផ្សេងទៀត? ឧទាហរណ៍ដូចជាបញ្ជូនទៅមន្ទីររបស់ ម៉េង ជាដើម គុករបស់ ម៉េង ជាដើម។ តើមានករណីអ៊ីចឹងទេ?

**ឆ៖** បាទ គេដោះលែងជូនទៅដល់ស្រុកកំណើត និងភូមិរបស់គេវិញបាទ។

**ស៖** តើលោកដឹងដែរឬទេ ថាតើ សែន ដែលលោក -- សែន – សយ សែន ដែលលោកស្គាល់នៅក្រាំងតាចាន់ហ្នឹង ហើយនិងអ្នកផ្សេងៗទៀត ដែលគេឲ្យធ្វើទឹកត្នោតជូរមានអ្នកផ្សេងទៀតដែលគេឲ្យធ្វើទឹកត្នោតជូរទេ? ហើយនិងមានស្គាល់ សយ សែន ហ្នឹងទេ?

[១០:៥២:៤២]

**ឆ៖** បាទ ស្គាល់។

**ស៖** ខ្ញុំមិនសូវយល់ច្បាស់ទេ ចម្លើយរបស់លោកនេះ សួរថាតើមានគេធ្វើទឹកត្នោតជូរនៅក្នុងអំឡុងរបបខ្មែរក្រហមសម្រាប់បុគ្គលិកនៅមន្ទីរក្រាំងតាចាន់នេះដែរឬទេ?

**ឆ៖** គេធ្វើមួយបំពង់ៗដែរបាទ ប៉ុនខ្ញុំមិនដែលបានហូបនឹងគេ ព្រោះក្មេងទៅហូបទឹកត្នោតជូរណាកើត។

**ស៖** បាទ សូមអរគុណ។ តើបក្ខជនទាំងប្រាំមួយនាក់នៃគណៈគ្រប់គ្រងនៅក្រាំងតាចាន់នេះផឹកទឹកត្នោតជូរហ្នឹងជាប្រចាំដែរឬទេ?

**ឆ៖** គិតទៅហូបតែ ឃើញហូបហ្នឹងឃើញតែបីនាក់ទេបាទ តាសៀង និង មឿន ហើយនិង ចេង នេះបាទ។

**ស៖** តើលោកដឹងដែរឬទេថាគ្រឿងក្នុងត្រូវបានគេយកចេញដើម្បីទៅត្រាំស្រា ឬក៏ដូចជាប្រមាត់ជាថ្នាំមអីជាដើមនេះ? មានគេយកទៅដាក់សម្រាប់ក្លែមស្រាដែរឬទេ? ឬក៏ត្រាំស្រា?

**ឆ៖** បាទ ត្រង់ហ្នឹងមួយ អត់ដឹងទេបាទ។

**ស៖** បាទ ឥឡូវខ្ញុំនឹងចូលទៅនិយាយអំពីលក្ខខណ្ឌឃុំឃាំងនៅក្រាំងតាចាន់ចន្លោះឆ្នាំ១៩៧៥ និង១៩៧៦និង៧៩។ លោកបានពិពណ៌នាអំពីលក្ខខណ្ឌឃុំឃាំងនៅគុកក្រាំងតាចាន់ គឺឯកសារ D40/23 ជាភាសាខ្មែរគឺ ERN 00665355 ទៅដល់ 57, ជាភាសាបារាំងគឺ 00490910 ទៅដល់ 11, ជាភាសាអង់គ្លេស 00223211 ទៅដល់ 12។ លោកបានឆ្លើយថា៖ "នៅពេលដែលអ្នកទោសត្រូវបានគេនាំមកដល់មន្ទីរ គេដាក់អ្នកទោសទាំងអស់នោះនៅក្នុងអគារឃុំឃាំងដោយដាក់ខ្នោះជើងទាំងពីរ ហើយបន្ទាប់មកទៀតគេដាក់រនុកដែកមួយដាក់ចូលទៅខ្នោះជើង។ មួយជួរមានអ្នកទោស បួន -- ជាង១០នាក់ ដែលចងភ្ជាប់គ្នា ហើយមានពីរជួរ មានអ្នកទោសពីរជួរនៅក្នុងអគារនោះ"។ បន្ទាប់មកទៀត មានគេសួរថា៖ "តើអ្នកទោសនោះត្រូវបានគេដាក់ខ្នោះដៃទេ? ហើយនៅៗសម័យនោះ ខ្នោះនោះខ្នោះលេខ៨នោះមានខ្នោះលេខ៨និងខ្នោះអូតូម៉ាទិក។ ខ្នោះលេខ៨គេប្រើសម្រាប់ដាក់ៗដៃ ហើយខ្នោះស្វ័យប្រវត្តិនោះគេៗប្រើដាក់អ្នកទោសពីរនាក់ជាប់គ្នា ដាក់ខ្នោះដៃអ្នកទោសពីរនាក់ជាប់គ្នា"។ ហើយចម្លើយបន្ទាប់មកទៀត លោកឆ្លើយថា៖ "នៅពេលដែលអ្នកទោសនោះចង់បត់ដៃបត់ជើង គេហៅអ្នកយាម ហើយយើងជាអ្នកយាមហ្នឹងទៅដោះខ្នោះដៃ ខ្នោះហ្នឹងចេញ ហើយខ្នោះមួយទៀតគឺដាក់ជាប់ហ្នឹងដៃអ្នកទោសមួយទៀត"។ សំណួរបន្ទាប់មកទៀត "តើបន្ទាប់ពីបត់ដៃបត់ជើងហើយ អ្នកទោសនោះមានបានងូតទឹកអីទេ? ចម្លើយ៖ អត់ទេ អ្នកទោសមិនបានមុជទឹកសម្អាតខ្លួនទេ"។ បួនសំណួរក្រោយមក "នៅក្នុងអគារឃុំឃាំងនោះមានអ្នកទោសស្លាប់ដែរឬទេ? (សំណួរគេសួរយ៉ាងដូច្នេះ) ហើយបើស្លាប់ ស្លាប់ដោយសារអី?" ចម្លើយលោកឆ្លើយថា៖ "មានស្លាប់ដោយសារឃ្លាន ហើយនិងការធ្វើទារុណកម្មដើម្បីយកចម្លើយ។ នៅពេលដែលអ្នកទោសនោះត្រូវបានគេវាយធ្វើបាបខ្លាំងពេកស្លាប់នៅក្នុងអគារ ហើយអ្នកខ្លះក៏ស្លាប់ដោយសារសង្កើចខាំដែរ ហើយក៏ប៉ុន្តែជាពិសេសនោះ ស្លាប់ដោយសារអត់អាហារ"។

[១០:៥៨:១៨]

ហើយនៅសំណួរមួយទៀត គេសួរថា "តើនៅពេលអ្នកទោសនោះឈឺ តើគេធ្វើយ៉ាងម៉េចដែរ?

ចម្លើយលោកឆ្លើយថា៖ នៅទីនោះមិនមានបុគ្គលិកពេទ្យអីទេ អ្នកទោសឈឺនោះបានត្រឹមតែដេកថ្ងូរ ហើយស្លាប់តែប៉ុណ្ណោះ"។ បាទសូមបញ្ចប់ការដកស្រង់។ តើលោកដឹងដែរឬទេថា ហេតុអ្វីបានជាអ្នកទោសត្រូវបានគេប្រព្រឹត្តបែបនេះ ប្រព្រឹត្តទៅលើបែបនេះព្រោះៗថាខ្វះទឹក ខ្វះអាហារ ខ្វះការថែទាំជាដើម។ តើហេតុអ្វីក៏គេប្រព្រឹត្តទៅលើអ្នកទោសក្នុងលក្ខខណ្ឌបែបនេះ?

**ឆ៖** បាទ ក្នុងទិសដៅនេះ ខ្ញុំមិនបានដឹងដែរបាទ ដឹងផែនការគេយ៉ាងម៉េច ខ្ញុំអត់ដឹងដែរបាទ។

**ស៖** នៅពេលដែលអ្នកទោសស្លាប់នៅក្នុងផ្ទះដោយឈឺ ឬក៏ដោយការៗវាយដំច្រើនពេលសួរចម្លើយ។ តើអ្នកណាដែលជាអ្នកយកអ្នកទោសដែលស្លាប់នោះចេញ? តើអ្នកយាមឬអ្នកទោសផ្សេងទៀត ដែលយកអ្នកទោសដែលគេវាយស្លាប់នេះចេញ?

**ឆ៖** បាទ ហ្នឹងនៅផ្នែកខាងៗក្នុង គេចាត់ចែងបាទ។

**ស៖** ពេលដែលលោកនិយាយថាអ្នកដែលធ្វើការនៅក្នុងអគារខាងបរិវេណគុកនោះ តើលោកចង់និយាយថា បុគ្គលិករបស់ក្រាំងតាចាន់ ឬក៏អ្នកទោសដែលត្រូវយកអ្នកដែលគេវាយស្លាប់នេះចេញ?

**ឆ៖** គេចាត់ចែងដូចជាលោក សែន ដែលលោកនិយាយអំមិញហ្នឹងបាទ។ ចាត់ចែងកម្លាំងក្នុងហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ ចុះក្រៅពីសែនហ្នឹង តើមានម្នាក់ទៀតឈ្មោះ ចិន ហ្នឹងដែរទេ? ដែលគេប្រើគាត់ហ្នឹងឲ្យយកសាកសពហ្នឹងទៅកប់ចោល។ បាទអ៊ីចឹងឈ្មោះ តាចិន។ តើក្រៅពី សែន ហ្នឹងមានឈ្មោះតាចិនទេ ដែលគេឲ្យយកខ្មោចទៅកប់នោះ?

[១១:០១:១៩]

**ឆ៖** បាទ មានឈ្មោះ តាចិន ហ្នឹងមួយ ប៉ុនឥឡូវគាត់ស្លាប់ដែរហើយបាទ។

**ស៖** បាទ លោកសាក្សី សំណួរចុងក្រោយមុននឹងផ្តល់វេទិកាទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ តើពេលក្រោយៗមកហើយនេះ ការចងចាំរបស់លោកដែលអំពីរបប គឺថារយៈពេលដែលលោកធ្វើការនៅមន្ទីរក្រាំងតាចាន់នេះ អនុស្សាវរីយ៍ទាំងអស់ហ្នឹងគឺជាអនុស្សាវរីយ៍ដែលធ្វើឲ្យលោកឈឺចាប់ដែរឬទេ ហើយបើសិនជាលោកឈឺចាប់ហ្នឹង សូមលោកជួយពន្យល់តុលាការថាហេតុអ្វីក៏លោកឈឺចាប់?

**ឆ៖** បាទ បានជាខ្ញុំឈឺចាប់ មកពីឪពុកមាខ្ញុំជាប់ដល់បួននាក់ បាទ ហើយស្លាប់ទាំងបួន។ ហើយម្តាយមីងខ្ញុំមួយ បាទ ទល់សព្វថ្ងៃហ្នឹងបាទ។

**ស៖** តើគាត់ ពួកគាត់ទាំងអស់នោះស្លាប់ ពេលមុនពេលដែលលោកចូលទៅធ្វើការនៅមន្ទីរ

ក្រាំងតាចាន់ហ្នឹង ឬក៏លោកចូលទៅធ្វើការនៅមន្ទីរក្រាំងតាចាន់ហ្នឹងហើយ បានពួកគាត់ទាំងអស់នោះស្លាប់។

**ឆ៖** បានស្លាប់មុនពេលដែលខ្ញុំទៅបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទសូមអរគុណលោកសាក្សីដែលលោកបានអត់ធ្មត់។ ហើយលោកប្រធាន ឥឡូវខ្ញុំសួរចប់ ហើយសូមផ្តល់វេទិកាទៅខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូម -- អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញបាទ!

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។ នាងខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

[១១:០៣:៣៤]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** សូមជម្រាបសួរលោកសាក្សី វ៉ាន់ សឿន។ ក្នុងពីម្សិលមិញ ហើយនិងមួយព្រឹកនេះ លោកបានឆ្លើយបំភ្លឺតុលាការនូវចំណុចមួយចំនួនធំ ដែលជាពន្លឺផ្តល់យុត្តធម៌ដល់តុលាការ។ ដូច្នេះជាបន្តទៀតនេះ ខ្ញុំសូមឲ្យលោកជួយបំភ្លឺបន្ថែមនូវចំណុចមួយចំនួនទៀតដើម្បីជាចំណុចបន្ថែមអ្វីដែលពុំទាន់ លោកពុំទាន់បានបំភ្លឺ។ ដូច្នេះ ដោយពេលវេលាមានកំណត់ យើងខ្ញុំសូមចាប់ផ្តើមនូវសំណួររបស់ខ្ញុំផ្ទាល់។ ខ្ញុំបានឃើញនូវចម្លើយរបស់លោកនៅក្នុងឯកសារ D4023 ដែលមាន ERN ជាភាសាខ្មែរលេខ 0016 5353 ហើយនិង ERN ជាភាសាអង់គ្លេស 00223209 និង ERN ជាភាសាបារាំង 00490907 លោកបញ្ជាក់ -- លោកបានបញ្ជាក់ថាគេដាក់កផែនការឲ្យលោកយាម ហើយគេប្រាប់ថាបើរួចគេនៅយើង។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ពីចំណុចហ្នឹង តើមានន័យយ៉ាងម៉េចដែរលោក?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ សូមបញ្ជាក់ចំណុចនេះបន្តិច ពាក្យថា “រួចគេ នៅយើង” រួចអ្នកទោស យើងចូលគុក

បាទ យើងចូលគុកម្ដង អត់មានខាងណាមកកាត់ ចាប់យើងចូលគុក យើងចូលគុកដោយខ្លួនឯងបាទ។ ពាក្យគេនិយាយតែប៉ុណ្ណឹងបាទ។

**ស៖** អរគុណលោក។ ដូច្នេះ លោកមានភារកិច្ចធ្ងន់ធ្ងរណាស់ក្នុងការទទួលខុសត្រូវ ក្នុងការយាមកាមនៅមន្ទីរសន្តិសុខហ្នឹង។ តើត្រូវទេលោក?

**ឆ៖** ផ្នែកយាមខាងក្រៅ បើរួចគេ នៅយើងហ្នឹង ពិតជាត្រឹមត្រូវបាទ។ មិនបាច់អ្នកណាបង្គំ គឺថាចូលគុកដោយខ្លួនឯងបាទ គេនិយាយតែប៉ុណ្ណឹង។

**ស៖** អរគុណលោក។ ក្នុងភារកិច្ចលោកជាអ្នកយាមកាម ជាមួយនិងសមាជិកប្រាំនាក់ទៀត ដែលលោកបានបញ្ជាក់នៅមុខតុលាការពីម្សិលមិញ លោកមានភារកិច្ចធ្ងន់ធ្ងរក្នុងការយាមកាមខាងក្រៅ ប៉ុន្តែខ្ញុំចង់ឲ្យលោកបញ្ជាក់ផងដែរថា តើភារកិច្ចចាត់តាំងកន្លងមកក្នុងការចាត់តាំងឲ្យយាមកាមហ្នឹង តើគេឲ្យលោកធ្វើអីខ្លះ? គេណែនាំយ៉ាងម៉េចខ្លះលោក?

[១១:០៦:៣០]

**ឆ៖** គេណែនាំថា យើងយកចិត្តទុកដាក់ជាមួយអ្នកទោស ធ្វើម៉េចឲ្យគាត់ឆ្លើយចម្លើយបាទ។ ពេលធ្វើការ សាកសួរគាត់ឲ្យបានត្រឹមត្រូវ។ ហើយខ្ញុំក៏មិនបានសាកសួរពេលធ្វើការហ្នឹង រែកដីដំបូក និងដកស្មូង។ ខែវស្សាដកស្មូង ខែប្រាំងរែកដីដំបូក រែកភក់ត្រពាំងដាក់ក្នុងស្រែ។ តែប៉ុណ្ណឹងទេ។

**ស៖** អរគុណលោក។ ប៉ុន្តែខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើនៅក្នុងសមាជិកប្រាំមួយនាក់ ដែលជាក្រុមរបស់លោកហ្នឹង តើអ្នកណាអ្វីខ្លះ លោកអាចប្រាប់បានទេ?

**ឆ៖** បាទ មានផ្នែកខុសគ្នា។ ផ្នែក ដល់តែពេលគេចាត់ចែងកម្លាំង ខ្ញុំអត់បានដឹងទេ ខ្ញុំនៅក្មេង គេប្រើចេញវាលមុនបាទ។

**ស៖** អរគុណលោក។ នៅមានចំណុចមួយទៀត នៅក្នុងចម្លើយលេខ១៧៥ និង១៧៦ របស់លោក នៅក្នុងឯកសារ E319.1.33 លោកបាននិយាយថា "គេប្រាប់លោកថា ផ្នែកខាងក្រៅ គឺការពារក្រៅ ផ្នែកខាងក្នុងគេធ្វើការ"។ តើមានន័យថាម៉េចលោកឃ្លាហ្នឹង?

**ឆ៖** បាទ ឃ្លានេះសូមបញ្ជាក់ថា "ផ្នែកខាងក្រៅការពារខាងក្រៅ ផ្នែកខាងក្នុងការពារខាងក្នុងនេះ" ពេលគេបោសសម្អាត ពេលគេរើមនុស្សចោលតែម្ដងបាទ។ សូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** អរគុណលោក។ អ៊ីចឹងបានន័យថា ពេលដែលគេឲ្យលោកការពារខាងក្រៅ គឺពេលហ្នឹង ហើយដែលគេសម្លាប់មនុស្ស។ មែនទេលោក?

**ធ៖** បាទ។

**ស៖** អរគុណលោក។ ខ្ញុំសូមឆ្លងចូលទៅសំណួរមួយទៀត។ នៅពេលសម្លាប់មនុស្ស តើអ្នកណាជាជនដៃដល់ លោកមានបានដឹងទេ?

**ធ៖** បាទ បក្ខជនគេទាំងប្រាំមួយរូបបាទ។

**ស៖** សូមលោកអាចបញ្ជាក់ឈ្មោះបានទេ អ្នកណាខ្លះ?

**ធ៖** អាន់, ពេញ, ចេង, មឿន, ឈៀង, ឈឿន។

**ស៖** អរគុណលោក។ តើលោកធ្លាប់ដែរឮឈ្មោះ ឃន និងឈ្មោះ រស់ ទេ?

[១១:០៩:៥២]

**ធ៖** កាលពីមុនឆ្នាំ៧៥ហ្នឹង ខ្ញុំទៅដល់ ឮគេនិយាយថាឈ្មោះ ឃន និងរស់ ដែរបាទ។ ប៉ុន្តែខ្ញុំអត់បានជួបមុខទេបាទ។

**ស៖** តើគាត់មានតួនាទីអីដែរ នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹងលោក?

**ធ៖** ខ្ញុំក្តាប់ប្រវត្តិអត់ច្បាស់ទេ ប៉ុន្តែឮឈ្មោះ តាឃន ហ្នឹងថាគាត់មកពីវៀតណាមបាទ។

**ស៖** គាត់ជាអ្នកដៃដល់ក្នុងការសម្លាប់ទេ?

**ធ៖** បាទ ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកនៅមុខសហចៅក្រមស៊ើបអង្កេត តាមឯកសារលេខ 193. 1.33 -- តាមឯកសារលេខ E319.1.33 នៅក្នុងសំណួរទី១៨៣៖ "តាមតែលោកដឹង តើមានតែឈ្មោះ ឃន និង រស់ ទេឬដែលជាអ្នកដៃដល់ក្នុងការសម្លាប់មនុស្សនេះ?" ឆ្លើយ៖ មានមនុស្សប្រាំនាក់ដែលជាបក្ខជនដៃដល់ក្នុងការសម្លាប់មនុស្ស គឺមានឈ្មោះ ឈៀង, ពេញ, មឿន, រស់ និង ឃន ។ ខ្ញុំធ្លាប់ជួបពេញកាលពី១០ឆ្នាំមុន គឺបានស្លាប់ទៅហើយ។ ចំណែកអ្នកផ្សេងទៀត ខ្ញុំពុំបានដឹងទេ។ ចម្លើយ១៩១៖ តើហេតុអ្វីបានជាលោកដឹងថា ឃន និង រស់ ជាជនដៃដល់ក្នុងការសម្លាប់មនុស្ស? ដំបូងខ្ញុំមានឪពុកមារបស់ឪពុកខ្ញុំម្នាក់នៅជាប់គុកក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ ហើយត្រូវបានសម្លាប់នៅទីនោះ។ ដូច្នេះ ឪពុករបស់ខ្ញុំ បានឲ្យខ្ញុំតាមដានស្រាវជ្រាវរកគាត់។ ខ្ញុំបានសួរគេអំពីរឿងនេះ ហើយក្រោយមក គេបានប្រាប់ខ្ញុំថា កុំនិយាយអំពីរឿងនេះតទៅទៀត"។ តើចម្លើយនេះពិតជាចម្លើយរបស់លោកមែនទេ? ហើយតើលោកអាចរំឭកថាតើ ឃន និង រស់ ជាជនដៃដល់ក្នុងការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខក្រាំងតាចាន់ទេ?

[១១:១២:២៦]

**ឆ៖** បាទ ចម្លើយពិតជាត្រឹមត្រូវ ប៉ុន្តែចម្លើយដែលខ្ញុំនិយាយនេះជាមួយ តាចេង ទេបាទ ជាមួយ តាចេង។ បាទខ្ញុំសួរគាត់ គាត់នៅមន្ទីរក្រាំងតាចាន់យូរហើយបាទ។ មិនមែន តាឃន ហើយនិង តារស់ ទេបាទ។

**សៈ** អរគុណលោក។ តើលោកធ្លាប់ដែលបានចូលរួមក្នុងការសួរចម្លើយអ្នកទោសទេ នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់?

**ឆ៖** បាទអត់ទេបាទ។

**សៈ** ដែលបានឃើញ ឬដែលៗបានឮអីទេ ពីការសួរចម្លើយហ្នឹង?

**ឆ៖** បាទ ពេលគេសួរចម្លើយ ខ្ញុំមិនសូវនៅផ្ទះទេបាទ។ គេឲ្យប្រើទៅដាំ ស្រោចទឹកត្រកួន ដាំត្រប់ ដាំស្ពៃ ដាំខ្ទឹមខាងក្រៅបាទ។ ស្រោចតែស្ពៃ ហើយនិងខ្ទឹមទេបាទ មួយថ្ងៃៗបាទ។

**សៈ** លោក វ៉ាន់ សឿន តើក្នុងសមាជិកលោកប្រាំមួយនាក់ដែលជាអ្នកយាមការពារជាមួយលោកហ្នឹង នៅក្រុមជាមួយគ្នា តើលោកធ្លាប់ដែលបានឮគេនិយាយថា ក្នុងការសួរចម្លើយ មានវាយសួរចម្លើយ ហើយវាយនឹងអី លោកដែលមានបានឮពួកហ្នឹងនិយាយទេចាស?

**ឆ៖** ក្នុងនេះ ក្នុងពេលសួរចម្លើយ ពិតជាមានបាទ ពីព្រោះមានដំបងនៅកន្លែងសួរចម្លើយហ្នឹង មានដំបងដូចជាផ្តៅ និង រំពាត់ដៃឫស្សីជាច្រើនបាទ។ ហើយម្យ៉ាងវិញទៀត នែសំខាន់បំផុត គឺគេវាយច្រកថង់ប្លាស្ទិកតែម្តងបាទ។

**សៈ** អរគុណលោក។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមនូវចំណុចមួយចំនួនទៀត។ ជាធម្មតា នៅមុនពេលការសម្លាប់ តើនៅក្នុងមន្ទីរហ្នឹងមានប្រជុំចាត់តាំងកម្លាំង បែងចែកការងារគ្នា ឬយ៉ាងម៉េចដែរលោក?

[១១:១៥:០០]

**ឆ៖** បាទ គ្រាន់តែដល់ពេល គេគ្រាន់តែថា៖ “ពួកអ្នែងទៅយាមខាងក្រៅ ការពារឲ្យល្អិតល្អន់ ដាច់ខាតកុំឲ្យរត់រួច”។ គេគ្រាន់តែប្រាប់តែប៉ុណ្ណឹងបាទ។

**សៈ** លោកមានដែលឮ ដែលដឹងថាគេមានចាត់តាំងឲ្យកម្លាំងទៅជីករណ្តៅ ឬក៏ឲ្យអ្នកទោសដូចគ្នាទៅជីករណ្តៅ ឬក៏ត្រៀមកម្លាំង ត្រៀមពេលម៉ោងដើម្បីរៀបចំការសម្លាប់នោះទេ? ដែលឮ ដែលឃើញទេលោក?

**ធ៖** បាទ ប៉ែកខាងក្នុងខ្ញុំអត់សូវបានដឹងទេបាទ។

**ស៖** អរគុណលោក។ ខ្ញុំឆ្លងទៅប្រធានបទមួយទៀត។ ពីម្សិលមិញ លោកបានបញ្ជាក់បំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះថាលោកជាទ័ពស្រុក។ គេចាត់តាំងលោកឱ្យទៅភូមិត្រពាំងពោធិ៍មួយខែ ដើម្បីចាំចាប់ខ្មាំង សេ.អ៊ី.អា។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ថា មុនដែលលោកទៅទីនោះ តើគេមានបានណែនាំលោកយ៉ាងម៉េចខ្លះ មុននឹងចាប់ខ្មាំងហ្នឹង សេ.អ៊ី.អា ហ្នឹង?

**ធ៖** សូមបញ្ជាក់ថា មុនទៅត្រៀមចាប់ខ្មាំងគេអត់មានបញ្ជាក់អីផង។ ទាល់ទៅដល់កន្លែងហ្នឹងបានគេបញ្ជាក់ថាយើងមកនេះ មកចាប់ សេ.អ៊ី.អា ប៉ុន្តែរយៈពេលជិតមួយខែហ្នឹង អត់មានអីទេ។ ស្ងាត់ឈឹងតែម្តង បាទ។

**ស៖** អរគុណលោក។ ខ្ញុំចង់ឱ្យលោកបញ្ជាក់បន្តិចដែរពីបញ្ហាហ្នឹង។ តើសេ.អ៊ី.អា ហ្នឹងវាយ៉ាងម៉េចទៅលោក? គេកំណត់អត្តសញ្ញាណយ៉ាងម៉េចទៅ សេ.អ៊ី.អា ហ្នឹង? ជាខ្មាំង ឬក៏ជាស្អីលោក សូមឱ្យលោកកំណត់ សូមឱ្យពន្យល់ឱ្យអង្គសវនាការបានដឹងផង តើវាជាសមាសភាពយ៉ាងម៉េចដែលហៅ សេ.អ៊ី.អា ហើយម៉េចដែលហៅខ្មាំង? គេកំណត់អត្តសញ្ញាណបែបណាចាស?

[១១:១៧:៣៧]

**ធ៖** បាទ សេ.អ៊ី.អា គេកំណត់សម្គាល់ថា ជនបង្កប់ខ្លួន បាទ។

**ស៖** ចុះពាក្យថា “ខ្មាំង” នោះលោក យ៉ាងម៉េចដែរ?

**ធ៖** ពាក្យថា “ខ្មាំង” ដែលជនក្បត់ គេថាខ្មាំងតែម្តងបាទ។

**ស៖** ខ្ញុំចង់ឱ្យលោកបំភ្លឺដែលថា តើពាក្យខ្មាំង ហ្នឹងគឺជាសមាសភាពរបស់ប្រជាជនប្រភេទណា? ជាអ្នកថ្មី ជាអ្នកចាស់ ជាអ្នកដែលមាននិន្នាការនយោបាយលទ់ទល់ ឬក៏ជាអ្នក១៧ ឬក៏ជាអ្នក១៨លោក?

**ធ៖** ហ្នឹងសូមបញ្ជាក់ថា ពាក្យថា“ខ្មាំង”នេះ គេកំណត់សម្គាល់ថា ឱ្យនរណាលួចមាន់ ឬលួចដំឡូង ឬមួយធ្វើក្នុងសហករណ៍បាត់បង់ ខូចខាត ឆ្នាំងចាន ឬក៏អ្វីៗទាំងអស់ដែលនៅក្នុងរបបនោះគេចោទថា ខ្មាំងតែម្តងបាទ។

**ស៖** សូមអរគុណលោក។ ពេលដែលលោកនៅជាទ័ពស្រុក តើលោកដែលចុះទៅជួយបង្កបង្កើនផលប្រជាជននៅតាមសហករណ៍ និងការដ្ឋានទេលោក?

**ធ៖** បាទ កាលខ្ញុំនៅស្រុក នៅទ័ព ចុះជួយប្រជាជនដកស្ទូងនៅរដូវវស្សាដូចជាកុនពេលវេលា

រដូវទឹកភ្លៀងធ្លាក់ ដូចជានៅឃុំជាងទង និងឃុំគុស និងឃុំពពេល នៅឃុំត្រពាំងធំខាងជើងដែរបាទ។

[១១:១៩:៣៩]

**ស៖** ក្រៅពីការក្តាប់ចុះជួយប្រជាជនបង្កបង្កើនផលនៅតាមសហករណ៍ និងការដ្ឋាន តើលោកដែរជាទ័ពស្រុក លោកមានក្តាប់ពីបញ្ហាសន្តិសុខ និងសភាពការណ៍ខ្មាំងនៅតាមមូលដ្ឋានទេ?

**ឆ៖** បាទ ចែកដាច់ពីគ្នា។ ទ័ពស្រុកអត់មានការពាក់ព័ន្ធអីជាមួយមូលដ្ឋានទេបាទ។

**ស៖** អរគុណលោក។ ពេលនោះ ទ័ពស្រុករបស់លោកមានចំនួនមនុស្សប៉ុន្មាននាក់?

**ឆ៖** បច្ចុប្បន្នគេហៅកងរយ ឬក៏ប្រធានវរៈ។ ហើយកងរយពី៥០ទៅ៧០នាក់ឡើងទៅ គេហៅកងរយ។ ហើយបច្ចុប្បន្នក្រោយមក បើកងហា គេរាប់ជាង១០នាក់ ១២នាក់ក៏មួយកងហាដែរបាទ។

**ស៖** អរគុណលោក។ ហើយតើអ្នកជាអ្នកក្តាប់លើទ័ពស្រុកហ្នឹង? រដ្ឋបាលស្រុក ឬក៏ខាងបក្ស?

**ឆ៖** កាលនោះ ខ្ញុំស្គាល់តែប្រធានវរៈមួយឈ្មោះ ចន បាទ ក្រោយមកបានស្គាល់ តាភីន មួយទេបាទ។ តាមផ្នែកងនីមួយៗហ្នឹង ខ្ញុំអត់ស្គាល់ទេបាទ។

**ស៖** អរគុណលោក។ ពេលដែលលោកនៅជាទ័ពស្រុក តើលោកចុះទៅ លោកទៅបោះទីតាំងនៅក្នុងស្រុកហ្នឹង ឬក៏នៅតាមៗផ្ទះរបស់ប្រជាជនមូលដ្ឋាន?

**ឆ៖** កាលខ្ញុំនៅទ័ពស្រុកហ្នឹង បោះបណ្តោយជើងភ្នំដំរីរមៀលបាទ។

[១១:២២:០៤]

**ស៖** សូមអរគុណលោក។ ខ្ញុំចង់លោកបញ្ជាក់មួយចំនួនទៀត។ ពីម្សិលមិញលោកបានបញ្ជាក់ថានៅមន្ទីរក្រាំងតាចាន់ដឹកនាំដោយបក្ខជនប្រាំមួយរូប ដែលមានឈ្មោះ អាន់, ពេញ, ចេង, ឈឿង, មឿន, និង ឈឿន។ មានន័យថា អ្នកទាំងប្រាំមួយនាក់ហ្នឹងមានសិទ្ធិសម្រេចគ្រប់កិច្ចការទាំងអស់នៅក្នុងមន្ទីរក្រាំងតាចាន់ មែនទេលោក?

**ឆ៖** បាទ មានសំបុត្រពីថ្នាក់លើមក គេបញ្ជូនមក គេសម្រេចតែម្តងបាទ។

**ស៖** ចុះចំពោះលោកវិញ តើលោកមានតួនាទីអ្វីដែរនៅក្នុងជួរបក្ស? ជាបក្ខជនដែរ ឬក៏ជាសម្ព័ន្ធ?

**ឆ៖** បាទ ខ្លួនខ្ញុំអត់មានអីគេទេ ក្មេងមួយរូបរស់នៅដោយរត់តាមគេទេបាទ។

**ស៖** ចុះអ្នកប្រាំនាក់ទៀត ដែលធ្វើការជាមួយក្រុមលោក ជាសម្ព័ន្ធយុវកក ឬក៏ជាបក្ខជន ឬក៏ជាក្រុមស្នូល? សូមលោកបញ្ជាក់បន្តិចមកបាទ។

**ឆ៖** អ្នកទាំងប្រាំនាក់អត់មាននាទីអីទេបាទ។

[១១:២៣:៣៤]

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកសាក្សី ចំពោះការបំភ្លឺរបស់លោក ដោយពេលវេលាមានកំណត់ ខ្ញុំសូមជូនការសួរសំណួរទៅឲ្យសហភាគាអន្តរជាតិ។ សូមអរគុណ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ សូមអញ្ជើញលោកស្រីមេធាវី សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីអន្តរជាតិ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានតែប្រហែលជាតែពីរសំណួរទេ។ កាលពីព្រឹកមិញនេះលោកឆ្លើយថា កន្លែងសួរចម្លើយនៅក្រាំងតាចាន់គឺចំហ មិនមានបិតបាំងអីជិតទេ ហើយលោកឃើញគេធ្វើទារុណកម្មអ្នកទោស។ ហើយលោកឆ្លើយថាគេប្រើថង់ប្លាស្ទិក ឬក៏គល់ឫស្សីសម្រាប់សួរចម្លើយអ្នកទោស។ អ៊ីចឹងខ្ញុំចង់សួរសំណួរពីរពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិចំពោះអ្នកទោសជាស្ត្រី។ សំណួរទី១ នៅពេលដែលលោកនៅក្រាំងតាចាន់ តើលោកធ្លាប់ឃើញអ្នកទោសស្រីដែលត្រូវគេសម្រាតខោអាវដោយអ្នកយាមដែរឬទេ? ឬក៏ចាប់សម្រាតដោយបុគ្គលិកនៅមន្ទីរក្រាំងតាចាន់?

[១១:២៥:១២]

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង ម្ដាយមីងខ្ញុំគាត់និយាយផ្ទាល់ប្រាប់ខ្ញុំតែម្ដងបាទ ព្រោះម្ដាយមីងខ្ញុំគាត់ជាប់រយៈពេល៣ឆ្នាំបាទ។ ហើយគេដាក់ខ្សែរ៉កកបាទ។ ហើយកាលពីជំនាន់ខ្ញុំទៅនៅហ្នឹង អត់មានទេ។ ដល់កាលគាត់ជាប់ហ្នឹង គេដាក់ខ្សែរ៉កក នៅស្នាមទល់បច្ចុប្បន្នសព្វថ្ងៃបាទ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ដឹងថា នៅពេលដែលគេសួរចម្លើយអ្នកទោសស្ត្រីនោះ តើគេមានធ្វើបាបអ្វីប្លែកខុសពីអ្នកទោសប្រុសទេ? លោកបានឃើញដោយផ្ទាល់ភ្នែកទេ? ហើយលោកថា -- ហើយខ្ញុំ

ចង់ដឹងថា តើមីងរបស់លោកស្រីហ្នឹងត្រូវបានគេសម្រាតខោអាវនៅក្នុងពេលសួរចម្លើយ ឬក៏ក្រោយពេលសួរចម្លើយ?

**ឆ៖** បាទ ក្នុងពេលសួរចម្លើយ គេដាក់ខ្សែរ៉កគាត់តែម្តងបាទ។ ហើយដែលអ្នកទោសក្រោយមក។ ខ្ញុំមិនដែលបានជួបប្រទះទេបាទ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកនិយាយអំពីគល់ឫស្សីនិងថង់ប្លាស្ទិកដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើទារុណកម្មអ្នកទោស។ តើលោកឃើញតង្កៀបទេ គេយកមកគាបអ្នកទោសទេ?

**ឆ៖** បាទ ក្នុងហ្នឹង អត់មានទេបាទ។

[១១:២៧:២៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺ។មានបញ្ហាបកប្រែ ដូច្នេះស្នើសុំឲ្យលោកស្រីធ្វើការសួរសំណួរសាជាថ្មីឡើងវិញ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំសួរឡើងវិញលោកសាក្សី។ អម្បាញ់មិញនេះ លោកឆ្លើយថាមានប្រើគល់ឫស្សី ថង់ប្លាស្ទិកសម្រាប់ធ្វើជាឧបករណ៍ធ្វើទារុណកម្មអ្នកទោស។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើលោកមានធ្លាប់ឃើញគេប្រើតង្កៀប ឬក៏អ្វីផ្សេងទេសម្រាប់សួរចម្លើយអ្នកទោសនោះ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** កន្លែងនោះ ពាក្យថា "តង្កៀប" ដូចគ្នាទេបាទ។

**ស៖** លោកសាក្សី នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយ។ ខ្ញុំចង់ឲ្យលោកឆ្លើយតបទៅនឹងសេចក្តីចង្អុលបង្ហាញរបស់ សយ សែន ដែលគាត់បានមកផ្តល់សក្ខីកម្មកាលពីខែកុម្ភៈកន្លងទៅនេះ។ ខ្ញុំសូមដកស្រង់នូវសក្ខីកម្មរបស់គាត់គឺឯកសារលេខ E1/257.1 នៅថ្ងៃនេះ នៅថ្ងៃនោះគឺថាប្រហែលជាម៉ោង១៩នាទី ៥៤វិនាទី គាត់ឆ្លើយទៅនឹងសំណួរគេសួរថា៖ "តើលោកធ្លាប់ឃើញ ធ្លាប់ឮគេដកក្រចកអ្នកទោសដែរឬទេ នៅពេលសួរចម្លើយនោះ?" គាត់ឆ្លើយថា៖ "ខ្ញុំមិនដឹងអ្វីទេ ខ្ញុំដឹងថាគេប្រើតង្កៀប ឬដង្កាប់ ដើម្បីគាបក្បាលដោះអ្នកទោស។ អ៊ីចឹង ខ្ញុំចង់ដឹងថាតើលោកធ្លាប់ឃើញការធ្វើបាបអ្នកទោសរបៀបនេះទេ គឺនៅពេលដែលគេធ្វើ -- គេសួរចម្លើយអ្នកទោសស្ត្រីហ្នឹង គេយកតង្កៀបមកគាប?

[១១:២៨:១៨]

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង ខ្ញុំអត់បានឃើញទេបាទ។

**ស៖** សំណួរចុងក្រោយ ស្ត្រីដែលត្រូវបានគេឃុំ ឬក៏សួរចម្លើយនៅក្រាំងតាចាន់ហ្នឹង តើទទួលរងនូវការធ្វើបាបខុសពីអ្នកទោសប្រុស ឬក៏ដូចគ្នាដែរ?

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង ខ្ញុំក៏អត់បាននៅផ្ទាល់ដែរបាទ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាស -- សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

[១១:៣០:២៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរខ្លីៗមួយចំនួនដើម្បីឲ្យសូមឲ្យលោកបំភ្លឺ។ លោកបានឆ្លើយថា នៅក្រាំងតាចាន់ មានមនុស្សពីរនាក់ ឈ្មោះ ឌុច ដែលធ្វើការនៅទីនោះ។ គឺ ឌុច មកពីស្រុក និង ឌុច មួយទៀតដែលនៅ ដែលជាកងការពារដូចលោក។ តើលោកដឹងអំពីមុខងាររបស់ ឌុច ដែលមកពីស្រុកទេ? តើនៅស្រុកហ្នឹងគាត់មានតួនាទីអ្វីដែរ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ឌុច មកពីស្រុកហ្នឹង គេប្រធានយុវជនស្រុកបាទ។

**ស៖** អ៊ីចឹងតើមុខងារគាត់ហ្នឹងគាត់ធ្វើយ៉ាងម៉េចដែរ ប្រធានយុវជនហ្នឹងគេធ្វើអ្វីដែរលោក?

**ឆ៖** បាទ ផ្នែកអស់ហ្នឹងខ្ញុំអត់ដឹងទេបាទ។

**ស៖** លោកក៏បាននិយាយកាលពីម្សិលមិញផងដែរថា ឌុចហ្នឹង គេហៅថា សារ៉ាត់។ អ៊ីចឹងខ្ញុំចង់ដឹងថា សារ៉ាត់ ហ្នឹង ជាអ្នកណា -- ជាឌុចមួយណា ជាឌុច មកពីស្រុក ឬក៏ជាឌុចដែលជាអ្នកការពារដូចលោកដែរ អ្នកយាមដូចលោកដែរហ្នឹង សារ៉ាត់ ហ្នឹងមួយណាដែរ? ឌុចមួយណាដែរ?

**ឆ៖** បាទ ឌុច ហៅ សារ៉ាត់ហ្នឹង គឺ ឌុច អ្នកយាមដូចខ្ញុំដែរបាទ។

**ស៖** តើ សារ៉ាត់ ហ្នឹង ជាឈ្មោះរបស់គាត់ឬក៏ឈ្មោះក្រៅទេ? មូលហេតុអ្វីបានជាគាត់ បានជាគេហៅគាត់ថាសារ៉ាត់ហ្នឹង?

**ឆ៖** កាលពីនៅនោះ គេហៅតែ ឌុចៗ ដែរ ប៉ុន្តែខ្ញុំទើបតែឮឥឡូវ គេហៅ សារ៉ាត់។ អត់ដឹងដែរបាទ។

**ស៖** នៅសម័យហ្នឹងគេហៅគាត់ថា ឌុចតូច មែនទេ? លោកធ្លាប់ឮគេហៅអ៊ីចឹងទេ? ឌុចតូចហ្នឹង?

**ឆ៖** បាទ ហៅ ឌុចតូចមួយ, ឌុចធំមួយ គេហៅអ៊ីចឹងបាទ។

[១១:៣៣:៣៥]

**ស៖** លោកបានពន្យល់ថានៅក្នុងកងរបស់លោកមានលោក ហើយមានអ្នកយាមផ្សេងទៀតដូចជា សាំង និង ស៊ីម ជាដើម។ ហើយលោកក៏ប្រាប់ផងដែរថា មុនមកដល់ក្រាំងតាចាន់ លោកនៅភ្នំដំរីរមៀល និងនៅភូមិត្រពាំងលាន ឬត្រពាំងពោធិ៍។ តើសាំង និង ស៊ីម នេះក៏នៅជាមួយលោកដែរនៅពេលនោះមែនទេ? ពេលនៅភ្នំរមៀល ហើយនិងត្រពាំងលាន ត្រពាំងពោធិ៍ហ្នឹង?

**ឆ៖** កាលនោះនៅកងខុសគ្នាទាំងអស់បាទ។ ដល់មកជួបគ្នានៅភូមិត្រពាំងពោធិ៍ហ្នឹងបាទ។

**ស៖** ចុះ ឌុចតូច គាត់នៅជាមួយលោកដែរឬក៏អត់នៅភ្នំដំរីរមៀល ឬនៅត្រពាំងពោធិ៍ហ្នឹង?

**ឆ៖** នៅតែ ឌុចតូចមួយទេ ជួបគ្នាបាទ នៅកងជាមួយគ្នាហ្នឹងបាទ។

**ស៖** ដូច្នេះ ឌុចតូចហ្នឹង គាត់នៅជាមួយលោករហូត តាំងពីតាកែវ រហូតដល់ភ្នំដំរីរមៀល ទៅដល់ភូមិត្រពាំងលាន ត្រពាំងពោធិ៍ និងក្រាំងតាចាន់ទៀត។ អ៊ីចឹងមានន័យថា លោកទៅដល់ក្រាំងតាចាន់ហ្នឹងគឺក្នុងពេលដំណាលគ្នាមែនទេ ជាមួយនឹងគាត់នោះ?

**ឆ៖** បាទ។

**ស៖** កាលពីម្សិលមិញ លោកឆ្លើយថា លោកជាបុគ្គលិកក្រាំងតាចាន់ ហើយលោកទទួលបញ្ជាពីតាអាន់ និងពេញ។ តើលោកមានទទួលបញ្ជាពីអាជ្ញាធរយោធា ឧទាហរណ៍ដូចជា វរៈសេនាធំរបស់លោកទេ ឬក៏លោកទទួលបញ្ជាតែពី តាអាន់ និងតែពី ពេញ ប៉ុណ្ណោះ មិនមានទទួលបញ្ជាពីកងយោធាទាំងអស់នោះ?

**ឆ៖** បាទ ចែកដាច់ពីគ្នា។ ដល់ខ្ញុំមកនៅនេះមានតែ តាអាន់ ទេ។ ដល់កាលនៅនោះមាន តាភីន

បាទ ដល់ខ្ញុំមកផុតមានតែ តាអាន់ ទេបាទ។

[១១:៣៦:៣២]

**ស៖** កាលពីម្សិលមិញ លោកនិយាយថាលោកនៅក្រាំតាចាន់រហូតទៅដល់ឆ្នាំ១៩៧៩ តើលោកនៅរក្សាចម្លើយហ្នឹងទេ?

**ឆ៖** បាទ។

**ស៖** ចុះ ឌុចតូច វិញ គាត់នៅជាមួយលោករហូតដែរ រហូតដល់ឆ្នាំ១៩៧៩ មែនទេ?

**ឆ៖** អត់ទេ ឌុចតូច គេដកចេញ។

**ស៖** ក្រៅពីឌុចតូច តើអ្នកណាខ្លះទៀតជាអ្នកវាយអង្គុលីលេខ?

**ឆ៖** តាអាន់ វាយផ្ទាល់ដោយខ្លួនគាត់។

**ស៖** តើលោកមាននៅចាំទេថា មានគេចាក់ម៉ាញេ ចាក់បាសអីនៅក្រាំងតាចាន់?

**ឆ៖** បាទ ចាំ។

**ស៖** តើគេចាក់មេក្រូហ្នឹងនៅពេលណា? ហេតុអ្វីបានជាគេចាក់ហ្នឹង?

**ឆ៖** គេចាក់ហ្នឹង ពេលគេធ្វើការបោសសម្អាតហ្នឹងតែម្តងបាទ។

**ស៖** អម្បាញ់មិញនេះលោកឆ្លើយថា លោកឮសំឡេងគេវាយអ្នកទោស ប៉ុន្តែលោកអត់ឮសំឡេងអ្នកទោសស្រែកទេ ពីព្រោះថាអ្នកទោសគ្មានកម្លាំងស្រែក។ អ៊ីចឹងលោកមានឮសំឡេងមេក្រូ ដែលគេចាក់ហ្នឹងទេ?

**ឆ៖** បាទ អត់មានមេក្រូទេ មានតែកូនធុងបាសពីរតូចៗ បាទ។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីលក្ខខណ្ឌអនាម័យ។ ហើយលោកបានឆ្លើយថា លោកសង្កេតឃើញថានៅក្នុងអគារឃុំអ្នកទោសមានសង្កើចជាច្រើន ហើយអ្នកទោសខ្លះនោះស្លាប់ដោយសារតែសង្កើចខាំ។ លោកអាចបញ្ជាក់អំពីចំណុចនេះម្តងទៀតបានទេ?

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង ខ្ញុំអត់បានចូលពិនិត្យទេបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអធ្យាស្រ័យលោកប្រធាន។ សូមកាត់សំណួររបស់លោកចៅក្រម។ ខ្ញុំបាទយល់ឃើញ

ថាម៉ោងវាបានលើសច្រើន ហើយសូមឲ្យលោកប្រធានមេត្តាគោរពទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានកំណត់ថាម៉ោងដប់មួយកន្លះត្រូវបិទ ហើយដើម្បីមានឱកាសឲ្យ ជាពិសេសលោក ខៀវ សំផន បានមានពេលសម្រាកគ្រប់គ្រាន់នៅពេលរសៀលនេះបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ទំនងជាមានសំណួរច្រើនទៀតទេ? បើមានសំណួរទៀត បន្តសួរនៅពេលរសៀល។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំត្រូវការប្រហែលជា៣០វិនាទីទៀតទេ។ លោកសាក្សី តើលោកឃើញមនុស្សមកពីមន្ទីរពេទ្យស្រុក មកដើម្បីមកដាក់ថ្នាំកំចាត់សត្វល្អិត ដូចជាសង្កើចហ្នឹងដែរឬទេនៅមន្ទីរក្រាំងតាចាន់ហ្នឹង?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ មានមកម្តងដែរបាទ។

[១១:៤១:៥៣]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។ អរគុណសាក្សី។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ រួមទាំងមេធាវីប្រឹក្សារបស់គាត់ នៅវេលាម៉ោងមួយ និងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:៤៣ នាទី ដល់ម៉ោង១៣:៣០ នាទី)*

[១៣:៣៤:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងពេលផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីទាំងអស់នៃរឿងក្តីនេះបានជ្រាបថា នៅរសៀលនេះ នៅពេលចុងម៉ោងប្រហែលជា ២០នាទី ចុងម៉ោង ពីម៉ោងបីសែសិបនាទីទៅ រហូតដល់ម៉ោងបួន អង្គជំនុំជម្រះនឹងផ្តល់ វេទិកាជូនទៅភាគីពាក់ព័ន្ធ ជាពិសេសគឺក្រុមមេធាវីការពារក្តីលោក នួន ជា លើកឡើងនូវទឡ្ហីករផ្ទាល់មាត់ក្នុងការដែលដាក់សំណើសុំមួយពាក់ព័ន្ធជាមួយនឹងការសំណើសុំឱ្យផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សីមួយចំនួនដោយទុកលទ្ធភាពក្នុងការពិនិត្យឯកសារពាក់ព័ន្ធទៅនឹង -- ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូលពីសំណុំរឿង០០៤ យកមកដាក់នៅក្នុងសំណុំរឿង ដេញដោលសម្រាប់សាក្សីចំពោះមុខ។ នៅក្នុងនោះគឺសង្កត់ធ្ងន់ពីរ គឺពាក់ព័ន្ធជាមួយនឹងសាក្សីដែលមានរហស្សនាម 2-TCW-803 និង 2-TCW-809 ដែលអង្គជំនុំជម្រះមានគម្រោងផែនការកាលវិភាគសម្រាប់ធ្វើសវនាការចាប់ពីរសៀលថ្ងៃស្អែកទៅ ហើយនិងដើមសប្តាហ៍ក្រោយសូមជ្រាបដើម្បីត្រៀមខ្លួន។ ហើយអង្គជំនុំជម្រះចំណាយពេលតែ២០នាទី នៃសវនាការរសៀលនេះ តែប៉ុណ្ណោះសម្រាប់ពិភាក្សាដេញដោលបញ្ហានោះ។

សូមអញ្ជើញចៅក្រម -- សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីបញ្ជាក់កុំឱ្យមានបញ្ហាបកប្រែ គឺថាពេលវេលានៅសល់គឺដើម្បីបង្ហាញពីទឡ្ហីករណ៍នៃញត្តិចុងក្រោយ ព្រោះថាយើងអត់ទាន់មានសារណា ហើយយើងមិនដោះស្រាយនោះទេ។ នៅពេលដែលមានការដាក់សារណាក្រៅពីការថ្លែងនៅក្នុងអ៊ីម៉ែល ទាក់ទងទៅនឹងសាក្សីបន្ទាប់នោះគឺថា សូមធ្វើការលើកទឡ្ហីករណ៍នៅរសៀលនេះ ដើម្បីផ្តោតតែទៅលើសំអាងហេតុថាតើ 803 និង 809 ហ្នឹងថាមាន

ទទ្ធីករណ៍អ្វីដែរ?

[១៣:៣៧:១៤]

**លោក វ៉ិចទ័រ កូប៉េះ**

យើងខ្ញុំរីករាយនឹងថ្លែងនៅពេលនេះ ប៉ុន្តែខ្ញុំនឹងរីករាយនឹងធ្វើនៅពេលរសៀលនេះ។ ប៉ុន្តែខ្ញុំគិតថា យើងបានដាក់ឯកសារជាភាសាមួយទៅហើយ។ ប៉ុន្តែដោយសារតែមិនទាន់មានការបកប្រែទើបយើងមិនទាន់ដាក់នៅឡើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងមិនមែនតវ៉ានោះទេ គ្រាន់តែយើងចង់ឲ្យចៅក្រមជាតិអាចអានឯកសារនេះតែប៉ុណ្ណោះបាន។ ដូច្នេះហើយខ្ញុំគិតថា គួរតែឲ្យចៅក្រមទាំងអស់អាចដឹងអំពីអ្វីដែលលោកបានសរសេរ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំរីករាយនឹងធ្វើទៅតាមនេះ ប៉ុន្តែខ្ញុំគិតថាវាជាការសមស្រប ដែលថាយើងគួរតែរង់ចាំឲ្យមានការបកប្រែជាភាសាខ្មែរឲ្យបានចប់សព្វគ្រប់សិន។ អាចថានៅថ្ងៃស្អែក នៅពេលដែលយើងបញ្ចប់ការសួរដេញដោល គឺយើងអាចនឹងធ្វើការដេញដោលទៅលើទទ្ធីករណ៍ទាំងអស់នេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកគិតថា ពេលណាបកប្រែចប់?

**លោក វ៉ិចទ័រ កូប៉េះ**

ប្រហែលជានៅថ្ងៃស្អែកពេលព្រឹក បើតាមដែលខ្ញុំគិត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងចុះ កាលវិភាគយ៉ាងម៉េចដែរ។ ឥឡូវហ្នឹង សាក្សីហ្នឹងគាត់មកត្រៀមរួចទៅហើយ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំយល់អំពីបញ្ហានេះ។ ប៉ុន្តែយ៉ាងណាក៏ដោយ វាអាស្រ័យទៅលើលោកចៅក្រមថាតើលោកចៅក្រមយល់យ៉ាងម៉េចដែរអំពីទាំងអស់នេះ ថាតើចំពោះភាសាខ្មែរយ៉ាងម៉េចដែរ? ដូច្នេះគឺថាខ្ញុំមិនមានបញ្ហាទេ អាស្រ័យទៅលើចៅក្រមជាអ្នកសម្រេច។

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមកែតម្រូវ ព្រោះខ្ញុំឮថា 803, 843 ក៏ប៉ុន្តែមិនមែនអ៊ីចឹងទេ គឺថា សាក្សីហ្នឹងគឺថា 803 ហើយនិង 809។ ដូច្នេះសំណើពាក់ព័ន្ធហ្នឹង គឺថាវាពាក់ព័ន្ធសាក្សីពីរ។ ហើយយើងនឹងផ្ដល់ពេលវេលា ២០នាទី ទៅឲ្យមេធាវីការពារក្ដី និងភាគីផ្សេងទៀតដើម្បីឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ពេលនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលដំបូងនេះ ផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៣:៤០:០០]

**លោក វ៉ិចទ័រ កូប៉េ**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំសូមចាប់ផ្ដើមសួរលោកនូវសំណួរមួយចំនួន ទាក់ទងទៅនឹងការឃុំខ្លួននៅក្រាំងតាចាន់។ លោកសាក្សី ខ្ញុំសូមចាប់ផ្ដើមអាននូវសម្រង់ខ្លីមួយនៃចម្លើយដែលលោកផ្ដល់ឲ្យសហចៅក្រមស៊ើបអង្កេត គឺ E319.1.33។ សំណួរ៩០ សំណួរបានសួរដូចតទៅនេះ "តើលោកចាំការចាប់ខ្លួនប្រជាជននៅភូមិស្រែគ្រូដែរឬទេ? ឆ្លើយ៖ ដំបូងនៅឆ្នាំ១៩៧៧ គេបានចាប់ខ្លួនមនុស្សពីរគ្រួសារ រួមទាំងប្រពន្ធ និងកូន នៅក្នុងភូមិស្រែគ្រូនេះ ប៉ុន្តែក្រោយមក នៅឆ្នាំ១៩៧៩ គេបានដោះលែងប្រពន្ធ និងកូនឲ្យត្រឡប់មកភូមិស្រែគ្រូវិញ ហើយខ្ញុំជាអ្នកនាំប្រពន្ធ និងកូនរបស់ពួកគេមកវិញ។ មានមនុស្សប្អូនផ្សេងទៀត ក៏ត្រូវបានចាប់បញ្ជូនទៅគុកក្រាំងតាចាន់ផងដែរ។ សំណួរទី៩១៖ តើលោកចាំឈ្មោះអ្នកទាំងនោះដែរឬទេ? ហើយលោកឆ្លើយថា៖ គ្រួសារទី១មានឈ្មោះ គុន ជាប្ដីរបស់ យាយញ៉ ហើយមានកូនឈ្មោះ ខា, វ៉ាត់ និងម្នាក់ទៀត ខ្ញុំមិនចាំឈ្មោះនោះទេ។ ឈ្មោះ គុន ដែលជាប្ដីរបស់យាយញ៉ ជាអ្នកជាប់គុកនៅក្រាំងតាចាន់។ គ្រួសារទី២ មានឈ្មោះ វ៉ាត់ កូនរបស់ឈ្មោះ គុន និង យាយញ៉ មានប្ដីឈ្មោះ ហឿន ជាអ្នកឃុំនៅគុកក្រាំងតាចាន់។ ចំពោះមនុស្សប្អូននាក់ផ្សេងទៀត រួមមានឈ្មោះ សុត, សាន។ ចំណែកមនុស្សពីរនាក់ទៀត ខ្ញុំមិនចាំឈ្មោះនោះទេ។ តាសុត និង តាសាន ជាអ្នកជាប់

ឃុំនៅគុកក្រាំងតាចាន់ ហើយនៅរស់រានក្រោយចប់របបខ្មែរក្រហម ប៉ុន្តែបច្ចុប្បន្ន ខ្ញុំមិនដឹងថានៅរស់ឬក៏អត់នោះទេ។ សុត និង សាន គឺរស់នៅក្នុងភូមិស្រែគ្រួ”។ ហើយសំណួរចុងក្រោយគឺ៩២៖ “តើមាននរណានៅរស់ដែរឬទេនៅសព្វថ្ងៃនេះ?” ហើយលោកឆ្លើយថា៖ “យាយញ៉ សព្វថ្ងៃនេះ រស់នៅភូមិស្រែគ្រួ”។ លោកសាក្សីថាតើអ្វីដែលខ្ញុំអាននេះ ជាចម្លើយត្រឹមត្រូវដែលលោកផ្តល់ទៅឱ្យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

[១៣:៤២:៥៥]

**ស៖** នៅក្នុងចម្លើយរបស់លោក នៅក្នុងឯកសារ D423 ទំព័រទី៤ នៃភាសាអង់គ្លេសមានលេខ 0023210, ខ្មែរមានលេខ 00165354, និងបារាំងមានលេខ 00490909។ លោកសាក្សីនៅក្នុងចម្លើយរបស់លោក លោកបាននិយាយអំពី យាយញ៉ គឺជាមីងរបស់លោក។ តើវាជាការត្រឹមត្រូវដែរឬទេ ដែលថា យាយញ៉ គឺជាមីងរបស់លោក?

**ឆ៖** បាទ យាយញ៉ ហ្នឹងមានពីរ បាទ។ មារបស់ខ្ញុំមួយ មីងញ៉ ហ្នឹងមួយបាទ។ មានពីរ។ ហើយសព្វថ្ងៃ គាត់ប្រពន្ធខាងផ្នែកយោធា នៅកាលពីសម័យសង្គមនិយមនៅអំពិលបីដើមបាទ។ ហើយដល់បច្ចុប្បន្នឥឡូវនេះ អត់ដែលទាន់ជួបគ្នាទេបាទ។

**ស៖** អ៊ីចឹង យាយញ៉ ជាម្តាយរបស់ វ៉ាត់ ហើយនិង ឃន មិនមែនជាមីងរបស់លោក។ តើអ៊ីចឹងមែនទេ? គឺជាម្តាយរបស់ វ៉ាត់ និង ខា ហ្នឹង មិនមែនជាមីងរបស់លោកទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកនៅជាមួយសហចៅក្រមស៊ើបអង្កេត E319.1.33 គឺសំណួរ១៦៧ លោកបាននិយាយ៖ “ថាតើលោកធ្លាប់ធ្វើការទំនាក់ទំនងជាមួយអ្នកទោសដែរឬទេ?” ហើយលោកឆ្លើយថា៖ “ខ្ញុំឧស្សាហ៍ឱ្យអ្នកទោសហូប គឺដូចជាយាយញ៉ រហូតដល់គាត់សរសើរខ្ញុំទល់នឹងសព្វថ្ងៃនេះទៀតផង”។ ដូច្នេះខ្ញុំចង់ដឹងថាតើ យាយញ៉ ហ្នឹងជាមីងរបស់លោក ដែលលោកនិយាយហ្នឹង ឬក៏មិនមែនទេ?

[១៣:៤៥:៣០]

**ឆ៖** បាទលោក យាយញ៉ ហ្នឹងមិនមែនទេ ប៉ុន្តែខ្ញុំចេះលួចឱ្យបាយ។

**ស៖** អរគុណ។ ហើយនៅក្នុងឯកសារ D40/23 នៅក្នុងចំណុច នៅផ្នែកខាងលើនៃទំព័រទី៧ 00223213, ខ្មែរមានលេខ 00165357 និងភាសាបារាំងមានលេខ 00490912។ “សំណួរ៖ ថាតើលោកដឹងថាយាយញ៉ ដែលនៅរស់ហ្នឹងនៅទីណាដែរ?” លោកឆ្លើយថា៖ “ខ្ញុំស្គាល់យាយញ៉ គាត់រស់នៅភូមិស្រែគ្រូ ព្រោះគាត់ឧស្សាហ៍មកជួបខ្ញុំ ហើយនាំកូនចៅរបស់គាត់មកលេងទៀតផង។ ហើយគាត់នៅរស់ដោយសារតែខ្ញុំជួយគាត់”។ អ៊ីចឹងតើយាយញ៉ ហ្នឹងមិនមែនជាម្ដាយរបស់ វ៉ាត់ និង ខា ដែលលោកនិយាយទេ? អ៊ីចឹងតើ យាយញ៉ សំដៅទៅលើអ្នកផ្សេងអ៊ីចឹងមែនទេ?

**ឆ៖** បាទ យាយញ៉ ជាម្ដាយមីងរបស់ខ្ញុំដោយឡែក។

**ស៖** តើលោកធ្លាប់ទាក់ទងជាមួយយាយញ៉ ដែលជាម្ដាយរបស់ វ៉ាត់ និង ខា ហ្នឹងដែរឬទេ?

**ឆ៖** បាទ សព្វថ្ងៃនៅទាក់ទងទៅវិញទៅមក ដោយខ្ញុំបុណ្យទានអី គាត់អញ្ជើញខ្ញុំទៅដែរបាទ។

**ស៖** តើលោកអាចប្រាប់បានទេថា តើគ្រួសារទាំងពីរនេះ នៅក្នុងរយៈពេល៥ទៅ១០ឆ្នាំកន្លងមក តើលោក ហើយនិងគ្រួសារគាត់ហ្នឹងជួបគ្នាបានញឹកញាប់កម្រិតណាដែរ?

**ឆ៖** បាទ ជួបគ្នាក្នុងមួយខែជួនកាលម្ដង ឬពីរដង ខ្ញុំធ្វើដំណើរចេញចូលតាមហ្នឹង ចូលផ្ទះគាត់លេងដែរបាទ។

**ស៖** អ៊ីចឹងឥឡូវលោកនិយាយពីមីងរបស់លោក ប៉ុន្តែខ្ញុំចង់សួរថាតើនៅពេលណាដែលគ្រួសារទាំងពីរបានជួបគ្នានៅក្នុងរយៈពេល៥ ទៅ១០ឆ្នាំកន្លងមកហ្នឹង? តើជួបគ្នាញឹកកម្រិតណា?

**ឆ៖** តាំងពីគាត់ទៅព្រំដែនមក អត់ដែលបានទំនាក់ទំនងគ្នា ដាច់រយៈរហូតសព្វថ្ងៃនេះ។

[១៣:៤៨:៤០]

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកអ៊ីចេះវិញ នៅក្នុងរយៈពេល៥ទៅ១០ឆ្នាំកន្លងមកហ្នឹង ដែលលោកធ្លាប់ជួបជាមួយ មាស សុខា ហើយនិងម្ដាយ ព្រមទាំង សយ សែន ហ្នឹង។ តើលោកជួបញឹកញាប់ប៉ុនណាដែរ?

**ឆ៖** សូមសួរចម្លើយម្ដងទៀត ស្ដាប់អត់ទាន់។

**ស៖** ខ្ញុំចង់សួរថា ការទំនាក់ទំនងរបស់លោកជាមួយគ្រួសារមួយទៀត គឺយាយញ៉ មួយទៀតគឺជាម្ដាយយាយញ៉ របស់ម្ដាយ -- យាយញ៉ ដែលជាម្ដាយរបស់ ខា ហើយនិង វ៉ាត់ នោះ។ តើគាត់ -- តើលោកជួបគាត់ញឹកញាប់ដែរឬទេ? តើលោកអាចបញ្ជាក់បានទេថា តើលោកជួបគាត់ហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំគ្រាន់តែខែ ពីរខែនេះអត់ដែលបានទៅផ្ទះគាត់ទេ។ រាល់ដង ខ្ញុំចូលលេងបាទ។

**ស៖** ចុះ៥ឆ្នាំកន្លងមកហ្នឹង តើលោកជួបញឹកញាប់ប៉ុនណាដែរ? ចុះ១០កន្លងមកហ្នឹង លោកជួបគាត់ញឹកញាប់ប៉ុនណាដែរ?

[១៣:៤៩:៥៩]

**ឆ៖** ការធ្វើបុណ្យធ្វើទានហ្នឹង គាត់ឲ្យកូនទៅប្រាប់ខ្ញុំបាទ។

**ស៖** តើលោកធ្លាប់និយាយជាមួយគ្រួសាររបស់លោក ឬក៏និយាយជាមួយគ្រួសារ យាយញ៉ អំពីហេតុការណ៍ដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម របបកម្ពុជាប្រជាធិបតេយ្យហ្នឹងដែរឬទេ?

**ឆ៖** ការទំនាក់ទំនងជាមួយគ្រួសារលោកយាយញ៉ ក៏ខ្ញុំមិនដែលបាននិយាយរឿងចាស់ដែរ គាត់ថាបំភ្លេចអស់ទៅរឿងហ្នឹង យើងរាប់អានគ្នាទៅ។ គាត់និយាយអ៊ីចឹងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ នៅក្នុងចម្លើយរបស់លោកជាមួយអ្នកស៊ើបអង្កេតគឺ E319/1/33 នៅក្នុងសំណួរ២២៣ លោកបាននិយាយដូចតទៅនេះ “សំណួរ៖ តើលោកអាចរៀបរាប់ឈ្មោះអ្នកដែលនៅរស់រានពីគុកក្រាំងតាចាន់ដែលស្គាល់បានដែរឬទេ? ហើយលោកឆ្លើយថា៖ មានដូចជា យាយញ៉ សព្វថ្ងៃរស់នៅភូមិស្រែគ្រួ ឃុំជាងទង ស្រុកត្រាំកក់។ យាយវ៉ាត់ រស់នៅសហរដ្ឋអាមេរិក សុត និងសាន សព្វថ្ងៃរស់នៅបៀតនឹងយាយញ៉ ដែរ”។ លោកសាក្សី តើលោកធ្វើយ៉ាងណាដើម្បី -- តើលោកដឹងដោយរបៀបណាថា យាយវ៉ាត់ រស់នៅសហរដ្ឋអាមេរិក?

[១៣:៥១:១៣]

**ឆ៖** បាទ ខ្ញុំទៅលេងហ្នឹង យាយញ៉ គាត់ប្រាប់ខ្ញុំ។ មុនដំបូង គាត់ យាយវ៉ាត់ហ្នឹងទៅរៀននៅវៀតណាម ចេញពីវៀតណាមមកនៅភ្នំពេញ នៅភ្នំពេញហើយបានគាត់បានគ្រួសារទៅអាមេរិកបាត់។

**ស៖** តើគាត់មានធ្លាប់ប្រាប់ថា កូនស្រីគាត់ហ្នឹងរស់នៅអាមេរិករយៈពេលប៉ុន្មានឆ្នាំហើយទេ?

**ឆ៖** ពេលរយៈពេលចេញទៅហ្នឹង ខ្ញុំអត់បានដឹងដែរ អត់បានដេញដោលសួររឿងហ្នឹងដែរ។

**ស៖** តើលោកខ្លួនលោកផ្ទាល់ហ្នឹងធ្លាប់បានជួបនិយាយជាមួយ វ៉ាត់ ដែរឬទេ?

**ឆ៖** កាលពីឆ្នាំ៧៩ហ្នឹងបានជួបគ្នាបាទ។

**ស៖** ក្នុងពេលថ្មីៗហ្នឹង លោកធ្លាប់ជួបនិយាយជាមួយ វ៉ាត់ ដែរឬទេ?

**ឆ៖** បាទ តាំងពីទៅសហរដ្ឋអាមេរិកមក អត់ដែលបានជួបគ្នាទេបាទ។

**ស៖** ប្រហែលជាខ្ញុំស្តាប់អត់ទាន់ ប៉ុន្តែខ្ញុំចង់ដឹងថា តើគាត់ទៅអាមេរិកហ្នឹងឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ ប៉ុន្តែ យាយញ៉ ប្រាប់ខ្ញុំក៏ខ្ញុំអត់បានសួរថ្ងៃខែចេញដំណើរដែរបាទ។

**ស៖** តើ យាយញ៉ មានប្រាប់លោកថា តើ វ៉ាត់ ហ្នឹងគាត់រស់នៅទីក្រុងណាដែរទេ?

**ឆ៖** បាទ អត់។

**ស៖** តើលោកដឹងថា សយ សែន ហើយនិងយាយញ៉ ហ្នឹងមានទំនាក់ទំនងយ៉ាងដូចម្ដេចដែរ?

**ឆ៖** សយ សែ! បាទ សយ សែ ហ្នឹង ខ្ញុំអត់ៗស្គាល់ទេ សយ សែហ្នឹង សយ សែន បាទ ស្គាល់តែ សយ សែន។

**ស៖** សូមទោសដែលខ្ញុំអានឈ្មោះមិនច្បាស់ គឺខ្ញុំសំដៅទៅលើ សយ សែន គឺ សយ សែន ដែលយើងនិយាយក្នុងពេលកន្លងមកនោះឯង។ តើលោកដឹងថា សយ សែន ហ្នឹងមានទំនាក់ទំនងសាច់ញាតិ ឬក៏មានទំនាក់ទំនងអីដែរជាមួយ យាយញ៉?

**ឆ៖** បាទ អត់ទេ ដាក់រយៈឆ្ងាយពីគ្នាបាទ គ្រាន់តែអ្នកទោសដូចគ្នាបាទ។

**ស៖** តើ យាយញ៉ ធ្លាប់ដែលទុក សយ សែន ហ្នឹងដូចជាកូនចិញ្ចឹម ឬក៏កូនធម៌អីដែរទេ?

**ឆ៖** បាទខ្ញុំអត់ដឹងទេ នូវការទំនាក់ទំនងគាត់និង សែន ហ្នឹងក៏ខ្ញុំអត់ដឹងដែរបាទ។

**ស៖** តើលោកដឹងថា សយ សែន គាត់មានឈ្មោះផ្សេងមួយទៀត នៅចន្លោះឆ្នាំ៧០ ដល់ ៧៩ ហ្នឹង តើគាត់មានឈ្មោះអីផ្សេងទេ?

**ឆ៖** បាទ អត់ទេ ឮឈ្មោះតែប៉ុណ្ណឹង ឮឈ្មោះតែ សយ សែន ហ្នឹងតែម្ដងបាទ។

**ស៖** តើឈ្មោះ ឃុត សែន ធ្វើឲ្យលោកនឹកឃើញអីដែរទេ ឈ្មោះ ឃុត សែន ហ្នឹង?

**ឆ៖** បាទ អត់ស្គាល់ដែរ ដល់អ៊ីចឹង ខ្ញុំអត់ស្គាល់ដែរបាទ។

[១៣:៥៦:៣៩]

**ស៖** លោកសាក្សី ក្នុងពេលកន្លងមកនេះ យើងនិយាយអំពី វ៉ាត់ ហើយនិងប្ដីរបស់គាត់ឈ្មោះ បឿន – មុំ បឿន។ តើលោកដឹងថា មានមូលហេតុអ្វីបានជា មុំ បឿន ហ្នឹងត្រូវបានគេចាប់យកទៅឃុំខ្លួននៅក្រាំងតាចាន់ដែរទេ?

**ឆ៖** បាទ ក្នុងរឿងនេះខ្ញុំអត់ដឹងទេបាទ ដោយគេបញ្ជូនគាត់ទៅបានដឹង បានឃើញតែម្ដងបាទ។

**ស៖** ទាក់ទងនឹងការបញ្ជូនគាត់ទៅនោះ ខ្ញុំនឹងសួរនៅពេលក្រោយបន្តិចទៀត ប៉ុន្តែឥឡូវនេះខ្ញុំចង់ដឹងថា ចង់ដឹងអំពីហេតុផលនៃការឃុំខ្លួន និងចាប់ខ្លួនម្ដាយ -- ប្ដីយាយញ៉ ឈ្មោះ មាស គុន ហ្នឹង តើលោកដឹងថាមូលហេតុអីទេ?

**ផ៖** បាទ អត់។

**ស៖** នៅពេលដែលខ្ញុំនិយាយថា គាត់មានទំនាស់ជាមួយភូមិឈ្មោះ ណុប តើលោកអាចនឹកឃើញអំពីបញ្ហាហ្នឹងទេ?

**ផ៖** បាទ រឿងប្ដីនេះ ខ្ញុំអត់ដែលបានសាកសួរគាត់ផងបាទ។

**ស៖** តើលោកដឹងអំពីការចោទប្រកាន់ទាក់ជាមួយឈ្មោះ មុំ ហឿន ដែលជាប្ដីរបស់ វ៉ាត់ ដែលគេថាគាត់ហ្នឹងរំលោភឈ្មោះ ខន ដែលជាប្រជាជន១៧ មេសា មកពីភូមិស្វាយចាស់។ តើលោកនឹកឃើញរឿងនេះដែរឬទេ?

**ផ៖** បាទ អត់បាទ។

[១៣:៥៩:០២]

**ស៖** ឥឡូវនេះយើងនិយាយអំពីបញ្ហា មុំ ហឿន ហើយនិង មាស គុន គឺថាពួកគេនៅក្រាំងតាចាន់ហើយ។ តើពួកគេចូលក្រាំងតាចាន់មុនលោកមកដល់ ឬក៏ក្រោយពេលដែលលោកមកដល់? តើលោកផ្ដល់ចម្លើយដូចជាមិនច្បាស់ ដូច្នេះខ្ញុំចង់ដឹងថាតើពួកគាត់ទាំងអស់ហ្នឹងនៅគុកក្រាំងតាចាន់រួចទៅហើយ មុនពេលដែលលោកមកដល់ ឬក៏ពួកគេមកដល់ក្រោយពេលដែលលោកចូលទៅក្រាំងតាំចាន់នោះ?

**ផ៖** បាទ ខ្ញុំនៅមុនៗពួកគាត់ចូលទៅដល់។

**ស៖** តើលោកបានឃើញនៅពេលដែលគេនាំពួកគាត់ចូលក្នុងនាមជាអ្នកទោសទៅទីនោះទេ?

**ផ៖** បាទ ឃើញ។

**ស៖** អ៊ីចឹងលោក គឺជាឆ្មាំគុកម្នាក់ដែលជាអ្នកនាំពួកគាត់ចូលមកក្នុងគុក ឬមួយក៏អ្នកផ្សេងទេជាអ្នកនាំពួកគាត់ចូលទៅក្នុងគុកនោះ?

**ផ៖** គេអ្នកនាំទេ បាទ។

**ស៖** តើលោកចាំថាពួកគេពេលដែលនៅក្នុងគុកហ្នឹង គេមានដាក់ខ្នោះជើងដែរ ឬទេ?

**ផ៖** បាទ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំនៅខាងក្រៅ។

**ស៖** តើលោកធ្លាប់ឃើញគេបណ្ដើរពួកគាត់ពីកន្លែងឃុំខ្លួនទៅកន្លែងសួរចម្លើយទេ?

**ផ៖** បាទ អត់។

**ស៖** អ៊ីចឹង ខ្ញុំអាចនិយាយបានទេថាលោកក៏មិនដែលឃើញគេសួរចម្លើយគាត់ អ៊ីចឹងមែនទេ?

**ផ៖** បាទ។

[១៤:០២:០២]

**ស៖** តើលោកដឹងទេថានៅពេលណាដែលប្រពន្ធរបស់ពួកគាត់ត្រូវបានគេយកមកក្រាំងតាចាន់ដែរ?

**ផ៖** ខ្ញុំមិនបានចាំថ្ងៃខែដែរ ពីព្រោះទាល់តែគាត់ទៅដល់បានឃើញនៅទីនោះដែរ ទាំងប្រពន្ធទាំងកូនបាទ។

**ស៖** ខ្ញុំដឹងថាលោកមិនចាំកាលបរិច្ឆេទទេ ប៉ុន្តែលោកអាចប៉ាន់ប្រមាណបានទេថា តើពេលណាពួកប្រពន្ធរបស់ពួកគេមកដល់ និងពេលវេលាដែលប្តីៗមកដល់ពេលណា ដែលប្រពន្ធមកដល់ ហើយពេលណាដែលប្តីមកដល់ក្រាំងតាចាន់?

**ផ៖** បាទ ប្តីមកមុនបាទ។ រយៈពេលយូរដែរ ប្រហែលជាប៉ាន់ស្មានប្រហែលជាមួយអាទិត្យ ឬពីរអាទិត្យបានប្រពន្ធមកដល់។

**ស៖** តើលោកឃើញពួកគាត់ហ្នឹង គឺថាគេដាក់ខ្នោះជើងដែរ ឬក៏អត់ទេនៅក្នុងបន្ទប់ឃុំឃាំង?

**ផ៖** ក្នុងហ្នឹង ខ្ញុំអត់បានចូលទៅទេបាទ។

**ស៖** ដូច្នេះលោកមិនបានឃើញគេយកពួកគាត់ពីកន្លែងឃុំខ្លួននាំទៅកន្លែងសួរចម្លើយទេ អ៊ីចឹងមែនទេ?

**ផ៖** បាទ។

**ស៖** ខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេងទៀត លោកសាក្សី។ នៅក្នុងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត ចម្លើយ២៦ និង២៧ លោកបានឆ្លើយដូចតទៅ៖ "ក្រោយខែមេសា ១៩៧៥ -- សំណួរសួរ មុនពេលលោកធ្វើការនៅក្រាំងតាចាន់ តើលោកធ្វើអ្វីនៅទីណា? ចម្លើយ២៦របស់លោកថា ក្រោយខែមេសា ឆ្នាំ១៩៧៥ ខ្ញុំធ្វើជាទ័ពនៅដំរីរមៀល មុនពេលដែលខ្ញុំមកធ្វើការនៅក្រាំងតាចាន់។ ពេលនោះគឺខ្ញុំឈរជើងនៅភ្នំដំរីរមៀល។ ពេលលោកឈរជើងនៅភ្នំដំរីរមៀល តើគេឱ្យលោកធ្វើអ្វីខ្លះ? ឆ្លើយ៖ គឺយាមចាំខ្មាំងនៅតាមជើងភ្នំ ប៉ុន្តែអត់មានខ្មាំងនោះទេ"។ សូមលោកជម្រាបជូនអង្គជំនុំជម្រះឱ្យបានលម្អិតបន្តិចមើលថា នៅជើងភ្នំហ្នឹង តើជើងភ្នំហ្នឹង ជើងភ្នំវានៅត្រង់កន្លែងណានៃភ្នំដែរ?

**ផ៖** បាទ ភ្នំដំរីរមៀលគឺវែង ចាប់ពីផ្លូវជាតិលេខ៣ មករហូតទល់គ្នានឹងខ្ពបត្របែក។ អ៊ីចឹងគេចាប់ឈរជើងខាង ជើងខាងក្រោមហ្នឹង ជើងក្រោមផ្លូវ តាមផ្លូវចាស់សពថ្ងៃហ្នឹងបាទ។

[១៤:០៥:៥៨]

**ស៖** បាទត្រឹមត្រូវ គឺនៅទិសខាងលិចគុកក្រាំងតាចាន់ ប៉ុន្តែជួរភ្នំហ្នឹងគឺវាវែង។ នៅពេលដែលលោកនិយាយថានៅជើងភ្នំ។ តើទីតាំងពិតប្រាកដមួយណាដែលលោកនិយាយថាជើងភ្នំហ្នឹង ជើងភ្នំហ្នឹងវានៅចំកន្លែងណាមួយផ្នែកណាមួយនៃភ្នំនេះដែរ?

**ឆ៖** បាទ ខ្ញុំនៅចំណុចភូមិត្រពាំងលាន ឃុំគុស ក្នុងស្រុកត្រាំកក់ហ្នឹងតែម្តងបាទ។

**ស៖** ខ្ញុំសូមសួររបៀបផ្សេងវិញ។ នៅពេលដែលលោកនិយាយថាជើងភ្នំ ខ្ញុំចង់និយាយអំពីទីតាំងពិតប្រាកដ ឧទាហរណ៍កន្លែង -- តើកន្លែងដែលមានទឹកឈូ កន្លែងដែលមានទឹកធ្លាក់ហ្នឹង វានៅឆ្ងាយពីកន្លែងលោកប៉ុនណាដែរ?

**ឆ៖** បាទទឹកឈូ ទឹកធ្លាក់ភ្នំជំរីវមៀលគ្មានទេបាទ មានខ្ញុំឈរជើងហ្នឹងនៅចំណុចភូមិត្រពាំងលាន ឃុំគុស ក្នុងស្រុកត្រាំកក់បាទ។

**ស៖** នៅក្នុងចម្លើយរបស់លោក គឺថាលោកឈរជើងនៅជើងភ្នំ។ ខ្ញុំសុំអានផ្នែកមួយទៀតនៃចម្លើយរបស់លោកគឺ D40/23, អង់គ្លេសERN 00223213, បារាំង 00490912 និង ខ្មែរ00165357 សំណួរសួរ៖ "តើៗលោកដឹងគេយកអ្នកទោសទៅសម្លាប់ឯណាទេ?" លោកឆ្លើយថា៖ "ខ្ញុំៗដឹងថា គេមានជញ្ជាំងនៅកន្លែងនុង។ ថាតើលោកដឹងដោយរបៀបណា? ចម្លើយថា៖ នៅពេលដែលគេកំណត់ពេលប្រជុំ។ ក្រោយមក គេដឹកអ្នកទោសទាំងនោះទៅសំដៅភ្នំ ប៉ុន្តែខ្ញុំមិនដឹងថាគេយកទៅចាក់ចោលនៅឯណានោះទេ គ្រាន់តែដឹងថានៅម្តុំភ្នំ"។ តើភ្នំដែលលោកឆ្លើយនៅក្នុងសំណួរនេះ ជាភ្នំដែលលោកឈរជើងហ្នឹង ឬក៏អត់ទេ?

[១៤:០៨:៤៥]

**ឆ៖** បាទគឺភ្នំជំរីវមៀល។

**ស៖** អ៊ីចឹងកន្លែងនេះ មិនមែនជាកន្លែងដែលលោកឈរជើងនៅក្នុងឆ្នាំ១៩៧៥ទេ មែនទេ?

**ឆ៖** បាទ

**ស៖** ដូច្នេះ ទីកន្លែងនៅឯជើងភ្នំដែលគេយកអ្នកទោសទៅហ្នឹង តើមានទឹកជ្រោះនៅជិតនោះដែរទេ?

**ឆ៖** បាទអត់ដឹងដែរបាទ។

**ស៖** ចុះតើមានទំនប់មួយ ណាមួយនៅក្បែរនោះដែរទេ?

**ឆ៖** បាទ ជើងភ្នំដំរីរមៀលហ្នឹង មានទំនប់ច្រើន មានទំនប់តាអ៊ុម ទំនប់តាម៉ឹង បាទ។

**ស៖** ទីកន្លែងដែលគេថាគេយកអ្នកទោសទៅ តើមានទំនប់នៅជិតនោះទេ ហើយបើមានវិញ តើទំនប់នោះឈ្មោះអីដែរ?

**ឆ៖** ព្រោះទំនប់ច្រើន ប៉ុន្តែមិនដឹងជាគេដឹកទៅទីណា ខ្ញុំអត់ដឹងដែរបាទ។

**ស៖** ខ្ញុំសួររបៀបផ្សេងវិញ។ តើលោកដឹងថា មានកន្លែងមួយដែលគេយកមនុស្សទៅសម្លាប់ចោលនៅឯជើងភ្នំដំរីរមៀលនោះ ដែរឬទេ?

**ឆ៖** ដឹងថាពេលគេដឹកចេញទៅ ប៉ុនខ្ញុំអត់ដែលបានទៅទេ បាទ។ ដឹងតែពេលគេដឹកទៅៗ ប៉ុនមិនដឹងទៅភ្នំណា ខ្ញុំអត់ដឹងដែរបាទ។

[១៤:១១:១០]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺថាលោកដឹងថា គេយកអ្នកទោសចេញពីក្រាំងតាចាន់។ គេដឹកសំដៅទៅភ្នំ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើគេដឹកអ្នកទោសចេញពីគុកក្រាំងតាចាន់យកទៅភ្នំហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំដឹងតែម្តងទេ បាទ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះគឺពេលដែលលោកបានឃើញតែម្តងហ្នឹង ពេលណាជាក់លាក់នោះគឺពេលណា?

**ឆ៖** គេដឹកទៅយប់ ប៉ុនខ្ញុំគ្រាន់តែដឹងថាគេមកដឹកអ្នកទោសចេញទៅ ប៉ុនមិនដឹង -- ចេញទៅយប់តែម្តងបាទ។ ប៉ុនមិនដឹងប៉ុន្មានទៅប៉ុន្មាន ខ្ញុំអត់ដឹងដែរបាទ។

**ស៖** លោកអាចជម្រាបមើល ថាតើលោកដឹងថាគេដឹកអ្នកទោសចេញទៅហ្នឹងសំដៅទៅភ្នំហ្នឹង លោកដឹងដោយរបៀបណា?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណ៎ា។ ឆ្លើយម្តងទៀត។

**លោក វ៉ាន់ សឿន៖**

**ឆ៖** គេឲ្យឈរយាមឡានបាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើមានឡានប៉ុន្មានគ្រឿងដែរលោក?

**ឆ៖** ក្នុងមន្ទីរហ្នឹងគ្មានឡានទេបាទ គេយកឡានខាងក្រៅមក បាទ។ តែឡានមួយទេ។

**ស៖** តើពេលហ្នឹងលោកមានភារកិច្ចពិតប្រាកដធ្វើអ្វីដែរ នៅទីហ្នឹង?

**ឆ៖** បាទ ខ្ញុំយាមខាងក្រៅបាទ។

**ស៖** តើលោកចាំថាលោកបានឃើញអ្វីពិតប្រាកដដែរលោក?

**ឆ៖** បាទ អត់។

**ស៖** លោកបាននិយាយថា លោកបានឃើញឡានមកដឹកអ្នកទោស។ អ៊ីចឹងសូមលោកនិយាយលម្អិតបន្តិចមើលអំពីឡានដែលមកដឹកអ្នកទោសហ្នឹង?

**ឆ៖** បាទ ឡានមកដឹកអ្នកទោសហ្នឹងគេមកយប់។ គេគ្រាន់តែមក គេប្រាប់ថា ឡានចូលមកដល់យប់ហ្នឹងហើយ។ គេគ្រាន់តែប្រាប់ប៉ុណ្ណឹង ខ្ញុំក៏ -- ផ្នែកខ្ញុំផ្សេងក៏ចេញពីហ្នឹងទៅ បាទ។

**ស៖** តើលោកបានឃើញគេៗរុញអ្នកទោសចូលទៅក្នុងឡានទេ?

**ឆ៖** បាទ អត់ឃើញទេ យប់អត់មានបើកភ្លើងទេបាទ។

[១៤:១៥:០០]

**ស៖** លោកសាក្សីនៅត្រង់ទំព័រ៧ នៃឯកសារ D40/23 គឺនៅត្រង់សំណួរចុងក្រោយ ខ្ញុំមិនចាំបាច់ឲ្យ ERN នេះទេ គឺសំណួរចុងក្រោយនៃចម្លើយរបស់លោក។ សំណួរសួរថា "នៅពេលដែលលោកធ្វើការនៅមន្ទីរនោះ តើលោកធ្លាប់បានឃើញថ្នាក់ដឹកនាំជាន់ខ្ពស់ណាមួយទៅពិនិត្យមើលនៅកន្លែងហ្នឹងទេ?" ហើយចម្លើយលោកថា "មានតែ ភី និងឌុច ដែលធ្វើការនៅស្រុកត្រាំកក់ គឺថាគេជិះឡាន និងជិះម៉ូតូញឹកញាប់ទៅទីនោះ"។ ពីខាងដើម គឺក៏យើងមាននិយាយអំពី ភីៗ ដើរពៀចៗនុះ។ តើលោកអាចជម្រាបអង្គជំនុំជម្រះលម្អិតបន្តិចបានទេ អំពី ភី នេះ?

**ឆ៖** បាទ ភី ហ្នឹង ខ្ញុំអត់ស្គាល់ប្រវត្តិគាត់ទេ ប៉ុនថាដឹងថា ភី កំបាក់ គេហៅថា ភី កំបាក់ៗមួយស្រុកត្រាំកក់ ក៏អ្នកណាស្គាល់ដែរ បាទ។

**ស៖** តើលោកស្គាល់ដោយសារគាត់កំបាក់ជើងអ៊ីចឹង ឬក៏ពៀចជើងអ៊ីចឹង ឬក៏ស្គាល់ល្អិតជាងហ្នឹងទៀត?

**ឆ៖** បាទ ព្រោះគេបក្ខជន ខ្ញុំអត់ដែលបានសួរ ហើយក៏អត់ដែលបាននិយាយមករកគាត់ដែរ

ពីព្រោះគេមក គេនិយាយតែគ្នាគេ ឋានៈៗធំដូចគ្នា បាទ។

**សៈ** តើលោកដឹងថា មានអ្វីកើតឡើងចំពោះ ភី ទេ ក្រោយឆ្នាំ១៩៧៥?

**ឆះ** បាទ អត់ដឹងដែរ ខ្ញុំទៅនៅកន្លែងហ្នឹង ឃើញតាភី ហ្នឹងចូលមកញឹកញាប់ ឃើញតែតាភី ហ្នឹង បាទ។

[១៤:១៧:១១]

**សៈ** តើលោកមិនដឹងថា ភី ត្រូវបានគេសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៩ ឬក៏ក្នុងឆ្នាំ១៩៨០ទេ?

**ឆះ** អត់ដឹងដែរ បាទ។

**សៈ** ប្រធានបទមួយផ្សេងទៀត លោកសាក្សី គឺចម្លើយរបស់លោកមួយ ដល់ ១៣០ គឺE -- គឺឯកសារ E319.1.33។ បាទ ចម្លើយ១២៧ ដល់១៣០ លោកទើបតែនិយាយខាងមុនបន្តិចទៀតនេះ គឺលោកធ្វើការនៅគុកត្រាំកក់ហ្នឹង គឺគេមានអ្នកទោសធ្ងន់ និងអ្នកទោសស្រាល។ យើងចង់ដឹងអំពីការញែកចេញពីគ្នារវាង -- ការញែកចេញពីគ្នា ថាតើអ្នកណាចាត់ទុកថាជាអ្នកទោសស្រាល ឬអ្នកណាចាត់ទុកថាជាអ្នកទោសធ្ងន់? ចម្លើយ១២៧៖ "គឺអ្នកទោសស្រាល យើងអាចឧទាហរណ៍ថា អ្នកលួចដកដំឡូង អ្នកចាប់មាន់ទៅធ្វើស៊ី ឬក៏អ្នកចាប់រំលោភកូនរបស់គេ។ អ្នកទោសធ្ងន់ មានដូចជា អ្នកទោសនយោបាយ មនុស្សប្រុសស្រីដែលលួចស្រឡាញ់គ្នា ហើយគេងជាមួយគ្នា និងត្រូវគេដាក់ទណ្ឌកម្មឲ្យរែកដី។ សួរ៖ តើការចាប់រំលោភជាទោសស្រាលមែនទេ? ឆ្លើយ៖ គឺអ្នករងគ្រោះ គឺមានទោសស្រាល ហើយអ្នកដែលចាប់រំលោភ-- តើអ្នករងគ្រោះក៏ត្រូវមានទោសដែរឬទេ? អ្នកទោសក៏ត្រូវគេ -- អ្នកទោសក៏មានទោសដែរ តែត្រូវគេសម្រាលទោសឲ្យរួចខ្លួន។ ចំពោះអ្នកដែលគេបញ្ជូនទៅក្រាំងតាចាន់ តើជាប្រភេទអ្នកទោសដូចម្ដេចដែរ? ឆ្លើយ៖ តាមខ្ញុំដឹង (គឺចម្លើយ១៣០) គឺជាអ្នកទោសធ្ងន់ និងបញ្ជូនមកមន្ទីរសន្តិសុខក្រាំងតាចាន់។ ចំណែកអ្នកទោសស្រាល គេមិនបញ្ជូនទៅទីនោះទេ"។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើលោកដឹងយ៉ាងដូចម្ដេចដែររវាងអ្នកទោសស្រាល និងអ្នកទោសធ្ងន់?

**ឆះ** បាទ ចំណុចហ្នឹងខ្ញុំក៏មិនដឹងជាវិនិច្ឆ័យយ៉ាងម៉េចដែរ ព្រោះខ្ញុំអត់បានចូលប្រជុំជំនុំជាមួយគេ គេវិនិច្ឆ័យ គេតៗគ្នាមក គេថាទោសធ្ងន់ត្រូវបញ្ជូនទៅក្រាំងតាចាន់ បាទ។ ទោសស្រាល នៅក្នុងគុកអង្គរកា។ បាទ គេនិយាយតែប៉ុណ្ណឹង បាទ។

**សៈ** ខ្ញុំដឹងថាលោកមិនដឹងចម្លើយជាក់លាក់ចំពោះអ្នកទោសណាម្នាក់នោះទេ ប៉ុន្តែតាមការដឹងជាទូទៅ តើគេបែងចែកយ៉ាងដូចម្ដេចរវាងអ្នកទោសស្រាល និងអ្នកទោសធ្ងន់? លោកដឹងដោយសារតែ

លោកជាអ្នកយាម ដោយដឹងដោយសារតែលោកឮពីគេ ឬក៏ដោយសារតែលោកជាអ្នកយាយនៅគុកក្រាំងតាចាន់?

**ឆ៖** បាទ ឮពីអ្នកយាមដូចគ្នា គេនិយាយ។

**ស៖** តើអ្នកយាមមួយណាដែលនិយាយប្រាប់លោក?

**ឆ៖** ផ្នែកបក្ខជន តាសៀង ហ្នឹងគាត់ប្រាប់ថាទោសធ្ងន់ត្រូវបញ្ជូនទៅក្រាំងតាចាន់ ទោសស្រាលទៅនៅអង្គរកា។ ប៉ុន្តែគេថាប្រយ័ត្នមែនទែន គ្រាន់តែថាប៉ុណ្ណឹងបាទ។

[១៤:២១:២៣]

**ស៖** តើលោកដឹងថា សៀង ហ្នឹង គាត់បានដឹងដោយរបៀបណាដែរ?

**ឆ៖** សៀង ហ្នឹងគេបក្ខជនបាទ។

**ស៖** ប្រធានបទមួយទៀត លោកបាននិយាយពីប្រធានបទពីខាងដើមរួចមកហើយ គឺសំណួរ E319.1.33 គឺចម្លើយ១៣៣ សហចៅក្រមស៊ើបអង្កេតថា៖ "ក្រោយថ្ងៃ១៧ មេសា ១៩៧៥ នៅពេលដែល លន់ នល់ ចាញ់ខ្មែរក្រហម តើមានអ្វីកើតឡើងចំពោះទាហាន លន់ នល់ និងទាហានកន្សែងស? ចម្លើយ១១៣៖ គឺថាគេបញ្ជូនអ្នកទាំងនោះ។ ហើយសំណួរ១៣៩៖ នៅឯមន្ទីរក្រាំងតាចាន់ តើមានអ្នកទោសដែលជាអតីតទាហាន លន់ នល់ ដែរឬទេ? នៅពេលដែលខ្ញុំធ្វើការនៅមន្ទីរសន្តិសុខក្រាំងតាចាន់ គឺអត់មានទេ។ សំណួរ៖ នៅពេលដែលលោកធ្វើការនៅឯគុកក្រាំងតាចាន់ តើមានអតីតទាហាន លន់ នល់ ទៅទីនោះ គេបញ្ជូនទៅទីនោះដែរឬទេ? ឆ្លើយថា៖ អត់មានទេ។ សួរ៖ ក្រោយថ្ងៃ១៧ មេសា ៧៥ តើលោកមានដឹងអតីតទាហានលន់ នល់ និងគ្រួសារគេយកទៅសម្លាប់ដែរឬទេ? ឆ្លើយ១៤២៖ ខ្ញុំមិនដឹងនោះទេ ព្រោះខ្ញុំនៅជួរក្រោយ។ នៅពេលទីរួមខេត្តតាកែវត្រូវបានវ៉ៃបែក គេបានដកខ្ញុំទៅស្រុកវិញ"។ សំណួរចុងក្រោយ៖ "ក្នុងនាមជាទាហានក្រោយពេលដែលទទួលជ័យជម្នះថ្ងៃ១៧ មេសា ៧៥ តើធ្លាប់លោកទទួលបានការណែនាំអ្វីនៅពេលដែលទៅជួបជាមួយនឹងអតីតទាហាន លន់ នល់ ដែរទេ? ចម្លើយ១៤៣៖ អត់ទេ គេគ្រាន់តែបញ្ជូនទាហានលន់ នល់ ទៅស្រុកវិញប៉ុណ្ណោះ"។ តើនេះពិតជាអ្វីដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតដែរឬទេ?

[១៤:២៣:៤៣]

**ឆ៖** បាទ ពិតត្រឹមត្រូវហើយ។

**ស៖** តើធ្វើម៉េចបានជាលោកដឹងថា ច្បាស់ម្ល៉េះថាអ្នកទោសនៅឯក្រាំងតាចាន់នោះ គឺមិនមាន

អតីត ឬក៏នាយទាហាន លន់ នល់? លោកធ្វើម៉េចបានជាលោកដឹងច្បាស់ម្ល៉េះ?

**ឆ៖** ខ្ញុំដឹងមូលហេតុគេនិយាយតៗគ្នាមកខាងក្រៅបាទ ប៉ុន្តែមិនដឹងមកពីខាងណាៗ ខ្ញុំវាអត់បានដឹងដែរ។

**ស៖** តាមដែលលោកដឹងច្បាស់លាស់នោះ គឺថាមិនមានអតីតទាហានលន់នល់ ឬក៏នាយទាហានត្រូវបានគេឃុំខ្លួននៅឯងគុកក្រាំងតាចាន់ទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំសូមបង្ហាញនូវចម្លើយលោកផ្សេងទៀត ទៅលើប្រធានបទផ្សេងទៀត គឺ D40/23, ERN ជាភាសាអង់គ្លេស គឺត្រង់ទំព័រ៥, ERN ជាភាសាបារាំង 00 -- ខ្មែរ ERN 00165354 ហើយអង់គ្លេស00490909។ "តើលោកធ្លាប់ដែលឃើញអ្នកទោសទាហានលន់នល់ដែរទេ ពេលលោកធ្វើការក្រាំងតាចាន់? ខ្ញុំមិនដែលឃើញទេ។ (ខ្ញុំត្រឡប់ចូលចំណុចនេះ) នៅពេលដែលខ្ញុំធ្វើការនៅទីនោះ ខ្ញុំនៅក្មេង ប្រហែលជាគេខ្លាចបែកការណ៍ អ៊ីចឹងឯងបានជាគេមិនឲ្យខ្ញុំដឹង"។ សំណួររបស់ខ្ញុំគឺ ផ្នែកទី២ ពួកគេតែងតែខ្លាចបែកការណ៍សម្ងាត់។ តើលោកចង់និយាយថាម៉េចដែលពួកលោកនិយាយថាដោយសារតែគេខ្លាចបែកការណ៍សម្ងាត់ហ្នឹង?

**ឆ៖** បាទក្រែងខ្ញុំដើរទៅនេះទៅនោះទេ ជួបប្រជាពលរដ្ឋ ឬប្រជាជនអីទៅនិយាយប្រាប់គាត់បាទ គ្រាន់តែប៉ុណ្ណឹងទេ បានគេមិនឲ្យខ្ញុំដឹងបាទ។

**ស៖** បាទខ្ញុំយល់។ តើលោកចាំទេថាតើលោកបានទទួលការណែនាំ ឬបញ្ជាអ្វីដែរ? តើគេមានបញ្ជា ឬក៏ណែនាំអ្វីជាក់លាក់មិនឲ្យលោកនិយាយជាមួយអ្នកភូមិចំពោះព្រឹត្តការណ៍អ្វីដែលបានកើតឡើងនៅគុកក្រាំងតាចាន់នោះដែរឬទេ?

[១៤:២៦:៥៣]

**ឆ៖** បាទអត់ទេ។ គេគ្រាន់ណែនាំថា "ដាច់ខាតបិទមាត់ឲ្យជិត" គេនិយាយតែប៉ុណ្ណឹង។

**ស៖** ចំណុចនេះវាដូចជាចំណុចបច្ចេកទេសបន្តិច ប៉ុន្តែខ្ញុំចង់ដឹងឲ្យបានច្បាស់ថា ដោយសារតែលោកជាអតីតកងទ័ពនោះ តើវាខុសគ្នាយ៉ាងម៉េចរវាងពាក្យថា "ការណែនាំ និងការបញ្ជា"។ តើគេគ្រាន់តែប្រាប់លោក ឬក៏គេបញ្ជានៅក្នុងសមត្ថភាពជា លោកជាកងទ័ពដែលថាមិនឲ្យនិយាយប្រាប់អ្នកណានោះ?

**ឆ៖** បាទ ក្នុងនោះគេគំរាមតែម្តងបាទ។ គេថាហាមផ្តាច់មាត់ចេញក្រៅ ឮពីអ្នកណាក្បាល

អ្នកហ្នឹង។ គេនិយាយអ៊ីចឹង។

**ស៖** ពេលវេលាវាយូរមកហើយ ប៉ុន្តែលោកចាំពាក្យពេចន៍គេពិតប្រាកដទេ នៅពេលដែលគេគំរាមមិនឱ្យលោកនិយាយទៅខាងក្រៅ ចំពោះអ្វីដែលកើតឡើងនៅក្រាំងតាចាន់?

**ឆ៖** បាទពិតប្រាកដ ពិតមែន។

**ស៖** ពិតប្រាកដហ្នឹង ចង់ដឹងថាពិតប្រាកដហ្នឹង ពាក្យពេចន៍អ្វីដែលគេប្រាប់លោក?

**ឆ៖** ពាក្យគេថា "ឮពាក្យខាងក្រៅ បើយើងមិនចេះ មិនដឹងអ្វីទេ កុំនិយាយឱ្យសោះ។ ប្រយ័ត្នក្បាលធ្លាក់ដល់ដី"។ គេនិយាយតែប៉ុណ្ណឹង។

**ស៖** ប្រហែលជាមានបញ្ហាដោយសារការបកប្រែហើយមើលទៅ។ តើគេមានណែនាំលោកជាក់លាក់មិនឱ្យនិយាយទៅខាងក្រៅ ដូចជានិយាយជាមួយអ្នកភូមិ ចំពោះអ្វីដែលកើតឡើងនៅឯគុកក្រាំងតាចាន់នោះដែរឬទេ នៅពេលលោកធ្វើការនៅទីនោះ?

**ឆ៖** បាទប្រជាជនជុំវិញហ្នឹង គេអត់ឱ្យយើងទៅទំនាក់ទំនងលេងសើចពីនេះពីនោះ អត់ទេ។ គេឱ្យដាច់ខាតនៅតែក្នុងរបង នៅក្រៅរបង។ របងពីរជាន់ បាទ។

[១៤:២៩:៤៣]

**ស៖** ខ្ញុំយល់នូវអ្វីដែលលោកនិយាយ តែយើងបានស្តាប់សក្ខីកម្ម ចម្លើយរបស់សាក្សីមួយផ្សេងទៀតដែល គឺ សយ សែន គាត់បានជម្រាបជូនអង្គជំនុំជម្រះថា គាត់ត្រូវបានគេអនុញ្ញាតឱ្យចេញពីបរិវេណគុកហ្នឹងឱ្យទៅឃ្វាលគោ តើគេមានណែនាំមិនឱ្យ សយ សែន ហ្នឹងនិយាយជាមួយអ្នកភូមិអ្វីដែរឬទេចំពោះអ្វីដែលកើតឡើងនៅក្រាំងតាចាន់?

**ឆ៖** បាទ ចំពោះខ្ញុំអត់ដែលបាននិយាយជាមួយ សយ សែន ហ្នឹងដែរ ក្រែងលោផ្នែកប្រធានគេនិយាយក៏មិនដឹងដែរ ខ្ញុំអត់បាននិយាយ។

**ស៖** ខ្ញុំចាំមិនច្រឡំទេ ចម្លើយរបស់ សយ សែន និង មាស សុខា គឺអ្នកទាំងពីរត្រូវបានគេអនុញ្ញាតឱ្យឃ្វាលគោ ឱ្យដើរជុំវិញហ្នឹង។ តើលោកមានដឹងថាគេមានហាមមិនឱ្យ មាស សុខា ហ្នឹងនិយាយទៅខាងក្រៅអីដែរទេ?

**ឆ៖** បាទ ពីរនាក់ហ្នឹងឃ្វាលគោមែន ប៉ុន្តែគ្រាន់គេហាម គេនិយាយអី ខ្ញុំអត់ដឹងទេបាទ។

**ស៖** ការណែនាំ ឬការបញ្ជាមិនឱ្យនិយាយទៅកាន់នរណាម្នាក់នូវអ្វីដែលបានកើតឡើងនៅក្រាំងតាចាន់។ តើការហាមប្រាមនេះ គេអនុវត្តចំពោះអ្នកយាមនៅក្នុងក្រុមរបស់លោកដែរ គេបាន

ទទួលការណែនាំ ឬបញ្ជាដូចលោកនេះដែរឬទេ?

**ឆ៖** គេណែនាំតែខ្ញុំ ព្រោះខ្ញុំក្មេងជាងគេបាទ។

[១៤:៣១:៥៣]

**ស៖** សំណួររបស់ខ្ញុំ គឺសួរថាតើអ្នកធ្វើការនៅកងរបស់លោកនោះ ទទួលបានការណែនាំដូចគ្នានេះដែរឬទេ លោកមានដឹងទេ?

**ឆ៖** បាទ ខ្ញុំជួបតែគេម្នាក់ គេប្រាប់ថា កុំនិយាយអីឲ្យសោះ ហើយនិងការណែនាំទូទៅ ខ្ញុំអត់បានជួបជុំគ្នាដែរបាទ។

**ស៖** សូមទោសលោកសាក្សី ប្រហែលជាខ្ញុំសួរមិនច្បាស់។ សំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងសមាជិកនៅក្នុងក្រុមរបស់លោក លោកនៅក្នុងកងឈ្លប កងទ័ព ហើយខ្ញុំគិតថាលោកទទួលបញ្ជា។ តើលោកដឹងដែរឬទេ ថាតើកងទ័ពនៅក្នុងកងរបស់លោក ឧទាហរណ៍ដូចជា ឌុច ជាដើមហ្នឹង ឬក៏សែន ជាដើម ថាតើពួកគាត់ហ្នឹងមានទទួលបញ្ជាហាមឃាត់មិនឲ្យនិយាយប្រាប់អ្នកដទៃអំពីអ្វីដែលកើតឡើងនៅក្រាំងតាចាន់ដែរឬទេ?

**ឆ៖** បាទ ចំណុចហ្នឹងមួយ ខ្ញុំក៏អត់បានដឹងដែរបាទ ព្រោះគេនិយាយប្រាប់តែខ្ញុំប៉ុណ្ណឹង។ ត្រង់សែន, ត្រង់ ឌុច ហ្នឹងក៏គេនិយាយប្រាប់យ៉ាងម៉េច ខ្ញុំអត់ដឹងដែរបាទ។

**ស៖** លោកសាក្សី ខ្ញុំមិនដែលធ្លាប់ធ្វើជាយោធាទេ ប៉ុន្តែក្នុងកងទ័ពបដិវត្តន៍ គឺមានការបង្គាប់ទៅដល់កង ក៏ដូចជាអ្នកប្រយុទ្ធ ថាតើគេមានប្រាប់ទៅតាមកង ឬប្រាប់ទៅតាមសមរភូមិអ្វីដែរឬទេ? តើខ្ញុំនិយាយអ៊ីចឹងខុស ឬក៏ត្រូវ?

**ឆ៖** ទ័ព បើផ្នែកទ័ព គេបញ្ជាទ័ព។ ដោយឡែកតែខ្ញុំមកនៅមន្ទីរក្រាំងតាចាន់ ដាច់ពីទ័ពបាទ។ គ្រាន់តែផ្នែកការពារប៉ុណ្ណោះបាទ។ បើផ្នែកទ័ព គេប្រជុំដាក់ផែនការ វ៉ៃសមរភូមិណាមួយ គេប្រជុំ។ គេហៅប្រជុំទាំង កងពល ទាំងក្រុម ទាំងកងវរយទាំងអស់បាទ។ ដល់តែផ្នែកនៅផ្នែកនគរបាលហ្នឹង គេចែកសាខាបាទ។

**ស៖** អ៊ីចឹងលោកចង់និយាយថា ក្នុងកងរបស់លោកដែលមានមូលដ្ឋាននៅក្រាំងតាចាន់ហ្នឹង គេអត់អនុវត្តបែបហ្នឹងទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ

[១៤:៣៥:១៦]

**ស៖** សំណួរបន្ទាប់របស់ខ្ញុំ គឺទាក់ទងទៅនឹងសំណួរ១៦៣, E319.1.33, "តើ តាអាន់ ធ្លាប់ណែនាំ ឬក៏ឱ្យលោកប្រើប្រាស់អាកប្បកិរិយាបែបណាជាមួយអ្នកទោសដែរឬទេ?" ហើយលោកឆ្លើយថា៖ "គាត់ណែនាំឱ្យទន់ភ្លន់ជាមួយអ្នកទោស ប៉ុន្តែត្រូវម៉ឺងម៉ាត់"។ ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីការដែលគេណែនាំឱ្យទន់ភ្លន់ ប៉ុន្តែត្រូវម៉ឺងម៉ាត់។ តើលោកចាំថាធ្លាប់មានការណែនាំ ហើយតើគាត់មានន័យយ៉ាងដូចម្ដេចដែរ នៅពេលដែលគាត់ប្រាប់ថា "ឱ្យទន់ភ្លន់តែ ត្រូវម៉ឺងម៉ាត់" នោះ?

**ឆ៖** បាទ ពាក្យនិយាយ "ផ្អែមល្ហែម ទន់ភ្លន់ ម៉ឺងម៉ាត់"នេះ គេនិយាយចំពាក្យដែលសម័យនោះគេប្រើថា "ផ្អែមល្ហែម ប៉ុន្តែម៉ឺងម៉ាត់ ដាច់ខាតចំពោះខ្មាំង"។ បាទ គេនិយាយអ៊ីចឹង។

**ស៖** ខ្ញុំយល់សំណួររបស់លោក ប៉ុន្តែនៅក្នុងពេលកន្លងមក លោកបានបញ្ជាក់ថាអ្នកទោសប្រហែលជាត្រូវបានគេធ្វើទារុណកម្ម ហើយសម្លាប់។ តើលោកគិតថានៅពេលនុំងវាជាការបញ្ជាណែនាំចម្លែក ឬមួយក៏ជាការបញ្ជាដែលឱ្យធ្វើជាមួយគ្នាដូចគ្នាជាមួយអ្នកទោស ដែលថា ទន់ភ្លន់ តែម៉ឺងម៉ាត់ហ្នឹង?។ តើលោកយល់យ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ ចំណុចហ្នឹងមួយខ្ញុំអត់យល់ដែរបាទ។ ដឹងគេវិនិច្ឆ័យយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ។

**ស៖** ប៉ុន្តែលោកចាំច្បាស់អំពីការបញ្ជាដែលគេថា ឱ្យទន់ភ្លន់ ប៉ុន្តែត្រូវម៉ឺងម៉ាត់។ តើអ៊ីចឹងមែនទេ?

[១៤:៣៧:២៧]

**ឆ៖** បាទ

**ស៖** តើលោកចាំបានដែរឬទេ ថានៅក្នុងឆ្នាំណាដែលគេបញ្ជាហ្នឹង? តើគេបញ្ជាតាំងពី -- តើគេបញ្ជាហ្នឹងរយៈពេលយូរ ឬមួយក៏ឆាប់ ហើយយ៉ាងម៉េចដែរ?

**ឆ៖** បាទ តែគេប្រជុំ គេលើកឡើងកន្លែងហ្នឹងសំខាន់ៗហ្នឹងបាទ។

**ស៖** អ៊ីចឹងមានន័យថា គេធ្លាប់ប្រាប់លោកច្រើនដង។ អ៊ីចឹងមែនទេ គេប្រាប់ទៅក្នុងក្រុមរបស់លោកច្រើនដង? អ៊ីចឹងមែនទេ?

**ឆ៖** បាទ

**ស៖** ហើយនៅក្នុងការប្រជុំនុំង អ៊ីចឹងខ្ញុំយល់ថាតើខ្ញុំយល់ត្រឹមត្រូវដែរទេ ដែលថាក្រុមរបស់លោក និងមិត្តនៅក្នុងក្រុមរបស់លោកនោះ បានចូលរួមក្នុងការប្រជុំនុំងដែរ? អ៊ីចឹងមែនទេ?

**ឆ៖** បាទ ប្រជុំមានពីរផ្នែក។ ផ្នែកបក្ខជនមានដោយឡែក ផ្នែកកងការពារមានដោយឡែកបាទ។

**ស៖** ខ្ញុំចង់សួរលោកអំពីសំណួរដែលសមាជិកក្នុងក្រុមលោកបានចូលរួម។ តើនៅពេលនុ៎ង គេប្រាប់រួម បានន័យថាគេប្រាប់នៅក្នុងក្រុមជារួម ហើយប្រាប់ច្រើនដង ដែលថាឲ្យលោកត្រូវទន់ភ្លន់ជាមួយអ្នកទោស ប៉ុន្តែត្រូវម៉ឺងម៉ាត់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ

**ស៖** ឥឡូវនេះ ខ្ញុំសុំបកទៅខាងមុខបន្តិច។ ការប្រជុំជាក្រុមហ្នឹង គឺថាការប្រជុំដែលគេណែនាំលោកហ្នឹង តើគេមានណែនាំអីផ្សេងទៀត ក្រៅពីការណែនាំលោកថា ទន់ភ្លន់ ម៉ឺងម៉ាត់ហ្នឹងទេ?

[១៤:៣៩:៥៧]

**ឆ៖** គេអត់មានណែនាំអីច្រើនទេ បាទ។ គេនិយាយតែមួយម៉ាត់ពីរៗ ហ្នឹងបាទ។

**ស៖** តើលោកចាំទេថា តើគេពិភាក្សាអំពីចំណុចអ្វីបន្ថែមទៀត ឬក៏តើមានការបញ្ជាការ ណែនាំអ្វីផ្សេងទៀតដែលគេប្រាប់លោកដែរទេ?

**ឆ៖** បាទ គេប្រជុំតែគ្នាគេ អ្នកធំៗយើងនៅខាងក្រៅ គេអត់បានកោះហៅប្រជុំប៉ុន្មានទេ។ ជួនកាលមួយខែម្ដងអ៊ីចឹងទៅ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

ហើយឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំចង់ពិភាក្សាទៅលើប្រធានបទបន្ទាប់ជាមួយលោក។ ខ្ញុំចង់ឲ្យលោកពិនិត្យទៅលើចម្លើយ D40/23, ភាសាអង់គ្លេសមានទំព័រទី៥ ភាសាអង់គ្លេសមានលេខ 00223211, បារាំងមានលេខ 00190909, ខ្មែរមានលេខ 00165354។ គេសួរលោកថា គឺគេសួរលោកដោយចំជាក់លាក់តែម្តង សំណួរគឺដូចតទៅនេះ៖ “តើលោកធ្លាប់ឃើញគេសម្លាប់អ្នកទោសនៅពេលដែលលោកនៅក្រាំងតាចាន់ដែរឬទេ?” លោកឆ្លើយថាលោកមិនដែលឃើញទេ។ តើលោកចាំថា តើលោកពិតជាឆ្លើយជាមួយអ្នកស៊ើបអង្កេតថាលោកមិនដែលឃើញ អ៊ីចឹងមែនទេ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ។

**ស៖** អ៊ីចឹង បានន័យថា លោកមិនដែលបានឃើញដោយផ្ទាល់ភ្នែក មិនដែលឃើញមនុស្សស្លាប់នៅចំពោះមុខរបស់លោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[១៥:០៤:២០]

**ស៖** សាក្សី មាស សុខា និង សយ សែន បានផ្តល់សក្ខីកម្មថា -- គឺកាលពីដើមខែកន្លងមកនេះគឺមកផ្តល់សក្ខីកម្មនៅទីនេះ ហើយពួកគាត់ទាំងពីរបានផ្តល់នូវព័ត៌មាន ឬក៏សក្ខីកម្មដែលលម្អិតទាក់ទងទៅនឹងការសម្លាប់ដែលពួកគាត់បានឃើញផ្ទាល់នៅក្រាំងតាចាន់។ តើលោកអាចពន្យល់បានដែរឬទេ តើហេតុអ្វីបានលោកមិនដែលឃើញអ្វីទាល់សោះ? ចំណែកសាក្សីពីរនាក់ទៀតនោះ គាត់បានឃើញរឿងរ៉ាវគ្រប់បែបយ៉ាងពីការសម្លាប់នៅក្រាំងតាចាន់។ តើលោកអាចពន្យល់បានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

បាទ សូមអញ្ជើញលោកសហមេធាវី -- អ៎! សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយសារតែគាត់សួរឲ្យសាក្សីនិយាយស្មាន គាត់សួរថា ហេតុអ្វីបានជាអ្នកផ្សេងទៀតបានឃើញអ៊ីចឹង។ ដូច្នេះ គាត់សួរឲ្យសាក្សីនិយាយស្មានអំពីមូលហេតុដែលអ្នកផ្សេងបានឃើញការសម្លាប់មនុស្សហើយ។ ដូច្នេះខ្ញុំគិតថាគាត់គួរតែរៀបចំសំណួរឡើងវិញ លោកប្រធាន។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាព្រះរាជអាជ្ញាគួរតែជាមនុស្សចុងក្រោយគេនៅទីនេះ ដែលនិយាយថាខ្ញុំទាយស្មាន។ ការពិត ខ្ញុំគ្រាន់តែចង់ប្រមូលផ្តុំ ឬក៏ចង់សម្របសម្រួលអំពីលទ្ធភាពដែលសាក្សីពីររូបគាត់ផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ៗសាក្សីទាំងពីរនាក់ហ្នឹងក៏បានឃើញនូវអំពើហិង្សាព្រៃផ្សៃគ្រប់បែបយ៉ាង។ ចំណែកសាក្សីនេះ គាត់ថាគាត់អត់ដែលឃើញអ្វីទាល់តែសោះ។ ដូច្នេះហើយយើងដឹងច្បាស់ថាពួកគាត់ទាំងបីនាក់ហ្នឹង នៅក្រាំងតាចាន់។ នៅពេលនេះ ដូច្នេះខ្ញុំមិនមែនស្នើសុំឲ្យគាត់ទាយស្មាន ឬក៏អ្វីទេ គ្រាន់តែចង់ឲ្យគាត់ប្រាប់មូលហេតុ តើហេតុអ្វីបានគាត់មិនដែលឃើញអ្វីទាំងអស់? វាគ្រាន់តែជាលទ្ធភាពប៉ុណ្ណោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៧:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ បង្គាប់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចលើសេចក្តីជំទាស់លើសំណួរនេះ ហើយនិងជម្រាបដាស់តឿន ទៅលោកមេធាវី ការពារក្តីលោក នួន ជា ផង។

បាទ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដំបូងបំផុត គឺថាខ្ញុំមិនចង់ឲ្យមេធាវីការពារក្តីជៀលត្អះ ទៅលើសហព្រះរាជអាជ្ញានោះឡើយ។ ទី២ គឺថា ការជំទាស់ គឺយើងអនុញ្ញាតឲ្យមានការជំទាស់ទៅលើសំណួរនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកអាចពន្យល់បានដែរឬទេ ថាហេតុអ្វីៗបាន មាស សុខា និង សយ សែន អាចមើលឃើញនូវការសម្លាប់យ៉ាងព្រៃផ្សៃនៅក្នុងបរិវេណក្រាំងតាចាន់ ចំណែកលោកវិញលោកមិនដែលឃើញការសម្លាប់អ្វីទាល់តែសោះ? តើហេតុអ្វី?

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ មូលហេតុនេះមកពីក្នុងហ្នឹងព្រៃច្រើនបាទ។ របងពីរជាន់ ខ្ញុំនៅខាងក្រៅបាទ ហើយព្រៃចេកជិតឈឹង បាទ។

**ស៖** ខ្ញុំសូមបន្តបន្តិច ហើយមាស សុខា និង សយ សែន ក៏បានផ្តល់សក្ខីកម្មថាគាត់ចាកចេញពីបរិវេណគុកទៅមើលគោក្របីនៅខាងក្រៅ។ ដូច្នេះហើយគេថាពួកគាត់ក៏ស្ថិតនៅក្រៅបរិវេណគុកដែរ។ ដូច្នេះ ខ្ញុំចង់សួរម្តងទៀតថាតើៗលោកដឹងថាហេតុអ្វីបានជាគេឃើញហេតុការណ៍គ្រប់បែបយ៉ាងចំណែកលោកអត់ឃើញអ្វីទាល់តែសោះបែបនេះ?

**ឆ៖** បាទ ខ្ញុំ--

[១៥:០៩:១៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

មេធាវីការពារក្តីព្យាយាមបញ្ជាក់ថា សយ សុខា ហើយនិង សយ សែន ហ្នឹង គាត់ ឃ្វាលតែគោ។ អ៊ីចឹងការនិយាយនេះគឺខុសហើយ គាត់និយាយច្បាស់ហើយអំពីតួនាទីរបស់គាត់។ គាត់មានតួនាទីច្រើននៅពេលនោះ គឺគាត់អាចដើរនៅក្នុងបរិវេណបានមិនមែនតែខាងក្រៅទេ ខាងក្នុងក៏គាត់អាចដើរបានដែរ។ អ៊ីចឹងការសួរនេះ សួរមិនត្រឹមត្រូវទេ ហើយធ្វើឲ្យសាក្សីហ្នឹងភ័ន្តច្រឡំហើយនៅពេលដែលសួរបែបនេះនោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរឡើងវិញលោកសាក្សី។ លោកយាមនៅខាងក្រៅ តើនៅពេលដែលលោកចាំវេនយាមហ្នឹង តើលោកសម្រាក លោកគេងនៅកន្លែងណាដែរ?

**លោក វ៉ាន់ សឿន៖**

**ឆ៖** គេងនៅៗភ្ជាប់នឹងរបងតែម្តងបាទ។

**ស៖** អ៊ីចឹង លោកចង់និយាយថា លោកមិនសម្រាកនៅក្នុងបរិវេណគុកទេ លោកសម្រាកខាងក្រៅ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ចុះ ឌុច វិញ តើ ឌុច គាត់នៅក្នុងបរិវេណ គាត់នៅខាងក្នុងញ៉ឹកញ៉ាប់ ឬក៏យ៉ាងម៉េចដែរ ហើយតើ ឌុច គាត់សម្រាកនៅខាងក្រៅបរិវេណ ឬក៏នៅខាងក្នុងបរិវេណ?

**ឆ៖** បាទ ឌុច មានពីរ។ មិនដឹងចង់ -- អស់លោកចង់សួរ ឌុច ណាមួយបាទ?

**ស៖** បាទ ខ្ញុំចង់សួរអំពី ឌុច នៅក្នុងកងរបស់លោក។ តើ ឌុច នៅក្នុងកងរបស់លោកហ្នឹង គាត់គេងនៅខាងក្រៅបរិវេណគុកដែរឬមួយក៏ម៉េច?

**ឆ៖** គេងបន្ទប់ជាប់របងដូចគ្នាបាទ បន្ទប់ខុសគ្នា។

[១៥:១១:៥៣]

**ស៖** ខ្ញុំនឹងសួរសំណួរនេះនៅពេលក្រោយបន្តទៀត ប៉ុន្តែឥឡូវនេះ ខ្ញុំទៅសំណួរផ្សេង។ ដូចគ្នានឹង សយ សែន ដែលយើងទើបតែនិយាយហើយហ្នឹង សយ សែន ក៏បានផ្តល់សក្ខីកម្មប៉ុន្មានសប្តាហ៍កន្លងមកនៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយគាត់បានផ្តល់សក្ខីកម្មថា គឺគាត់និយាយអំពីអាកប្បកិរិយាដ៏អាក្រក់របស់កងរបស់លោក។ គាត់ផ្តល់ចម្លើយថា កម្មាភិបាលបួនប្រាំនាក់នៅក្នុងកងរបស់លោកនោះ បានចូលរួមនៅក្នុងការរំលោភអ្នកទោសស្ត្រី។ តើលោកដឹងអំពីការរំលោភអ្នកទោសៗស្រីហ្នឹងដែរឬទេ?

**ឆ៖** បាទ មិនពិតទេបាទ។

**ស៖** អ៊ីចឹង តើលោកចង់ឆ្លើយថាសមាជិកនៅក្នុងកងរបស់លោកហ្នឹង អត់ដែលរំលោភអ្នកទោសស្ត្រីទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ ខ្ញុំចង់អានន្ទូវសក្ខីកម្មរបស់ សយ សែន នៅចំពោះមុខអង្គជំនុំជម្រះនេះ។ លោកប្រធាន គឺឯកសារ E3/217 គឺថ្ងៃ០៥ កុម្ភៈ ២០១៥ នៅពេលព្រឹក ហើយសំណួររបស់ខ្ញុំគឺសួរ សយ សែន ដូចតទៅនេះ។ ខ្ញុំសូមអានឲ្យលោកស្តាប់៖ "លោក សយ សែន ខ្ញុំចង់ឲ្យមានព័ត៌មានលម្អិតអ្វីដែលលោកបាននិយាយពីម្សិលមិញ លោកនិយាយថាទាហាន ឬក៏អ្នកយាមបានរំលោភស្ត្រីពីរ

នាក់មកពីកងចល័ត។ ហើយបានស៊ិកនូវក្បាលគ្រាប់ទៅក្នុងប្រដាប់ភេទរបស់គាត់។ តើលោកអាចប្រាប់ពីទាហាននោះដែរទេ? សយ សែន ក៏ឆ្លើយថា៖ បាទ គឺ ឌុច ឬក៏ឌុចតូច ហើយនិង សែន ដែលពួកគាត់ពីរនាក់គឺជាអ្នកធ្វើ”។ ដូច្នេះ ខ្ញុំចង់សួរថា លោកយល់យ៉ាងណាចំពោះសក្ខីកម្មរបស់ សយ សែន អំពីអាកប្បកិរិយារបស់បុគ្គលពីរនាក់នៅក្នុងៗកងរបស់លោក? តើ សយ សែន គាត់ផ្តល់សក្ខីកម្មហ្នឹងត្រូវឬក៏ខុស?

**ឆ៖** បាទ មិនពិតទេបាទ។

**ស៖** អ៊ីចឹង លោកសាក្សី ខ្ញុំចង់សួរសំណួរប្រហែលគ្នាដែរទាក់ទងទៅនឹងការសម្លាប់។ តើលោកដឹងថាតើវាជាការពិត ឬក៏មិនពិត ហើយហេតុអ្វីបានជា សយ សែន ផ្តល់សក្ខីកម្មបែបនេះអំពីកងរបស់លោក?

**ឆ៖** បាទ ជារឿងសម្លាប់ពិតមែន តែដោយរំលោភដូចគ្មានទេបាទ។

**ស៖** លោកនិយាយថាលោកមិនគិតថា ដូច្នេះខ្ញុំចង់ឲ្យច្បាស់ ថាតើលោកដឹងអំពីការរំលោភផ្លូវភេទ ដែលមនុស្សនៅក្នុងកងរបស់លោកបានធ្វើ។ តើវាជារឿងពិត ឬក៏មិនពិត?

[១៥:១៥:៥៨]

**ឆ៖** បាទ ការងារនិយាយនេះអត់ពិតបាទ។

**ស៖** អ៊ីចឹងលោកចង់និយាយថា សយ សែន និយាយកុហកនៅចំពោះមុខអង្គជំនុំជម្រះ។ តើលោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ប៉ុន្តែ សយ សែន មិនត្រឹមតែនិយាយពីរឿងរំលោភប៉ុណ្ណោះទេ គាត់និយាយរឿងច្រើនទៅទៀត។ លោកប្រធាន គឺនៅក្នុងឯកសារដដែល នៅថ្ងៃដដែល គឺសំណួរដែលសួរទៅ សយ សែន គឺខ្ញុំគឺជាអ្នកសួរ៖ “កាលពីម្សិលមិញលោកបាននិយាយអំពីការសម្លាប់ទៅលើស្ត្រីវ័យក្មេងពីរនាក់។ លោកនិយាយថាស្ត្រីដែលមានវ័យចំណាស់បន្តិចត្រូវបានគេបោកផ្ទប់នឹងគល់ឈើ ចំណែកម្នាក់ទៀតបានបាក់កតើលោកអាចប្រាប់ឈ្មោះសន្តិសុខដែលសម្លាប់មនុស្សនោះទេ? សយ សែន គាត់ឆ្លើយថា បាទ ខ្ញុំអាចប្រាប់គឺ ស៊ីម, ម៉ុន, សាំង, ឌុច ឬក៏ ឌុចតូចនោះ”។ ដូច្នេះលោកសាក្សី គឺហាក់ដូចជាថា សយ សែន ហ្នឹងគាត់ផ្តល់សក្ខីកម្មចោទប្រកាន់ទៅលើសមាជិកនៃកងរបស់លោក ដែលបានសម្លាប់ក្មេងៗ។ តើលោកយល់យ៉ាងដូចម្តេច ចំពោះការនិយាយបែបនេះ?

**ឆ៖** ហ្នឹង ផ្នែកខ្ញុំខាងក្រៅមិនដឹងដែរ ប៉ុន្តែចម្លើយថាឲ្យចាប់រំលោភស្ត្រីក្នុងមានទោសនោះ ដូចថាគ្មាន។ បើមាន ខ្ញុំអាចដឹង អាចឮខ្លះ។ ក្រែងខ្ញុំចេញមកវាល គេរំលោភយ៉ាងម៉េច ខ្ញុំអត់បានដឹងកន្លែងហ្នឹង ចំណុចហ្នឹងមួយ។ អាហ្នឹងបើរបាយការណ៍ហ្នឹងយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ។ បើអ៊ីចឹងខ្ញុំនៅកន្លែងហ្នឹងដែរ អាចដឹងខ្លះបាទ។

[១៥:១៨:០០]

**ស៖** លោកសាក្សី ខ្ញុំមិននិយាយអំពីការរំលោភទេនៅមុននេះ ប៉ុន្តែខ្ញុំចង់និយាយអំពីការសម្លាប់កុមារ។ តើសមាជិកនៅក្នុងកងរបស់លោក ក៏គាត់ធ្លាប់សម្លាប់ក្មេងៗតូចៗ ដូចដែលខ្ញុំរៀបរាប់មុននេះបានដែរឬទេ? តើពួកគាត់ធ្លាប់សម្លាប់ក្មេងដូចដែលខ្ញុំអាននេះទេ? តើពួកគាត់ហ្នឹងពិតជាបានសម្លាប់ក្មេងៗនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរបាទ។

**ស៖** លោកនៅជាមួយកងរបស់លោកអស់រយៈពេលរាប់ឆ្នាំ។ តើពួកលោកទាំងអស់គ្នាជាមិត្តភ័ក្តិហ្នឹងគ្នាដែរឬទេ?

**ឆ៖** បាទ គ្រាន់តែនៅជាមួយគ្នាមែន ដូចថាដាច់ណា សាគុណពីគ្នាបាទ ដោយឡែកៗពីគ្នាតែម្តង។ រាងដូចមិនសូវត្រូវរ៉ូវគ្នា។

**ស៖** ខ្ញុំចង់សួរលោកថា លោកអាចពន្យល់បានទេថា ហេតុអ្វីបានជា សយ សែន គាត់និយាយអំពីរឿងរ៉ាវទាំងអស់អំពីសមាជិកនៅក្នុងកងរបស់លោក។ បានន័យថា សយ សែន គាត់និយាយអំពីរឿងទាំងអស់នេះ តែលោកបាននិយាយថាលោកអត់ដឹង។ ថាហេតុអ្វី?

**ឆ៖** បានជាខ្ញុំថាអត់ដឹងពីមូលហេតុថា សយ សែន ហ្នឹងជាអ្នកទោស បាទ ហើយនៅក្នុងគុក ហើយបើគាត់ស្តាប់រឿងហ្នឹងដឹង ក៏ខ្ញុំមិនដឹងដែរ ពីព្រោះខ្ញុំអត់ដឹងពិតមែនបាទ ព្រោះខ្ញុំនៅខាងក្រៅបាទ។

[១៥:២០:១២]

**ស៖** នៅក្នុងពេលកន្លងមក លោកផ្តល់ៗចម្លើយដល់អង្គជំនុំជម្រះថា អាចមានលទ្ធភាពដែលកម្ម -- ដែលមានការចោទប្រកាន់ចំពោះកម្មាភិបាលថា ស៊ីថ្លើម ប្រមាត់អ្នកទោសនោះ។ ហើយលោកនិយាយថាលោកមិនដែលឮ ហើយឬក៏លោកមិនបានដឹងអំពីការស៊ីថ្លើម ប្រមាត់នោះ។ ដូច្នេះ តើលោកអាចពន្យល់បានដែរឬទេថា ហេតុអ្វីបានគេផ្តល់សក្ខីកម្មបែបនេះ? ចំណែកលោក លោកបែរជាមិនដឹងឬក៏លោកមិនបានឮ អំពីការដែលគេវះយកថ្លើម ប្រមាត់ ពីខ្លួនអ្នកទោសហ្នឹង។ ហេតុអ្វី?

**ឆ៖** បាទ ចំណុចត្រង់ថា ស៊ីថ្លើម ប្រមាត់ នេះ ខ្ញុំអត់បានដឹងទេបាទ។

**ស៖** លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនដល់សាក្សី នូវសម្រង់តូចមួយចេញពីខ្សែវីដេអូ គឺវីដេអូដែលមាន ERN -- គឺ E3 ដែលខ្ញុំបានបង្ហាញរួចទៅហើយ។ ជូនចំពោះនេះ គឺ E3/3116R រវាង ២២:២០នាទី ដល់២៤:១២ -- ២២នាទី ២០វិនាទី ដល់២៤នាទី ១១វិនាទី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:២២:០៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ យើងបានមើលវីដេអូហ្នឹងហើយ ហើយយើងមើលតាមម៉ោងដែលបានផ្តល់ជូន គឺវាមានការពាក់ព័ន្ធទៅនឹងប្រមាត់ ថ្លើម ដែលគេដក ដែលគេវះយកចេញពីពោះ។ សាក្សីគាត់និយាយថា គាត់អត់ដឹងអំពីរឿងហ្នឹងទេ។ អ៊ីចឹង ខ្ញុំដឹង -- ខ្ញុំចង់ឲ្យគាត់ខាងមេធាវីការពារក្តីពន្យល់ថា វាមានប្រយោជន៍អីក្នុងការបញ្ចាំងវីដេអូហ្នឹង? ពីព្រោះថា គាត់បាននិយាយហើយថា គាត់មិនដឹងអំពីការវះយកថ្លើម ប្រមាត់ អីហ្នឹងទេ ហើយយកចាក់វីដេអូ ពាក់ព័ន្ធនឹងរឿងថ្លើមហ្នឹង ដូចជាខ្ញុំមើលទៅ វាអត់មានប្រយោជន៍ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយ ប៉ុន្តែខ្ញុំគិតថាៗ រូបភាពវាមានរូបភាពសាហាវព្រៃផ្សៃ ប៉ុន្តែវាជាការដ៏សំខាន់ ហើយជាៗធាតុផ្សំដ៏សំខាន់នៃសក្ខីកម្មរបស់ សយ សែន ។ ដូច្នេះ ចេតនារបស់ខ្ញុំ គឺចង់បង្ហាញខ្សែវីដេអូនេះ ទៅដល់សាក្សី។ ហើយចង់ឲ្យសាក្សីគាត់គិតថា តើរូបភាពដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ អាចធ្វើឲ្យគាត់នឹងឃើញដែលថា គេវះយកថ្លើម ប្រមាត់ ពីអ្នកទោសដែរឬក៏អត់នោះ?

[១៥:២៣:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៤:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះបានពិនិត្យទៅលើសំណើបង្ហាញវីដេអូទៅដល់សាក្សីនៅពេលនេះ ដោយសារតែសាក្សីបានផ្តល់ចម្លើយកន្លងមកគឺថា ភាពពាក់ព័ន្ធដូចជាមិនបានបង្ហាញដោយមេធាវីការពារក្តីនៅឡើយ ព្រោះថាភស្តុតាងនេះវាមានភាពសាហាវធ្ងន់ធ្ងរ។ ដូច្នេះ ភស្តុតាងនេះគឺវាគ្រប់គ្រាន់។ ដូច្នេះវាមិន ដូចជាការបង្ហាញភស្តុតាង ឬក៏ការលើកបង្ហាញភស្តុតាងវាបានបង្ហាញរួចទៅហើយ។ ដូច្នេះវា គិតថាដូចជាមិនសូវជាមានភាពពាក់ព័ន្ធប៉ុន្មានទេចំពោះសាក្សីនៅពេលនេះ។ អ៊ីចឹងខ្ញុំមានសំណើបន្ថែមមួយទៀតគឺថា ខ្ញុំគិតថា គាត់បានឃើញ ឬក៏គាត់បានឮអំពីការអនុវត្តប្រហាក់ប្រហែលគ្នានៅពេលដែលគាត់ធ្វើការប្រយុទ្ធ ឬក៏វាយប្រហារនៅក្នុងសង្គ្រាមស៊ីវិលជាមួយពួកទាហានលន់នល់ ថាគាត់ដឹងអំពីបញ្ហានេះ។ ដូច្នេះ ខ្ញុំចង់សួរត្រឡប់ទៅវិញទាក់ទងទៅនឹងរយៈពេលមុនឆ្នាំ៧៥។ ហេតុផលដែលខ្ញុំចាប់អារម្មណ៍ខ្លាំងក្នុងការបង្ហាញវីដេអូនេះ គឺថាមិនមែនត្រឹមតែគោលការណ៍ទូទៅ ដែលថាប្រជាជនជាសាធារណៈគួរតែដឹង ព្រោះថាពេលខ្លះគាត់គួរតែពិនិត្យមើលរូបភាពដែលមានលក្ខណៈសាហាវ ប៉ុន្តែក្នុងពេលកន្លងមកថ្មីៗនេះ គឺប្រហែលជាពីរសប្តាហ៍កន្លងមកនេះ គឺលោកទូត សេហ្វើ បានប្រើប្រាស់នូវសក្ខីកម្មរបស់សយ សែន ដែលនិយាយអំពីការវះថ្លើម ប្រមាត់ ដែលនិយាយអំពីអំពើហិង្សាឃោរឃៅនៅក្រាំងតាចាន់។ ដូច្នេះ ខ្ញុំចង់កំណត់ថាតើពិតជាមានការធ្វើឡើងដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាវាជាការពិត ឬក៏អត់ ឬក៏វាជាការអនុវត្តមួយដែលធ្វើឡើងតាំងពីយូរមកហើយ ដែលជាសកម្មភាពធ្វើឡើងដោយកងទ័ពលន់នល់នោះ។

[១៥:២៧:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើទឡ្ហីករណ៍បន្ថែមរបស់មេធាវីការពារក្តី -- ដូច្នេះទោះបីថាគាត់មានទឡ្ហីករណ៍បន្ថែមក៏យើងមិនជឿជាក់ទៅលើនេះដែរ។ ដូច្នេះការសម្រេចនៅដដែល។

**លោក វិចទ័រ កូប៉េ៖**

លោកសាក្សី ខ្ញុំឥឡូវនេះចង់លើកប្រធានបទបន្ទាប់។ ហើយខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើអ្វីដែលលោកបាននិយាយក្នុងពេលកន្លងមកជាមួយសហចៅក្រមស៊ើបអង្កេត។ នៅទំព័រ៤ នៃភាសា

អង់គ្លេស គឺអង់គ្លេសមានលេខ 00223210, បារាំងមានលេខ 00490909 និងខ្មែរមានលេខ 0016 5354។ សំណួរនៅចុងទំព័រ "នៅពេលដែលគេវ៉ៃអ្នកត្រូវគេសួរហ្នឹង តើគេប្រើអ្វី?" ហើយលោកឆ្លើយថាគេវាយនឹងដំបងរំពាត់ផ្ដៅ។ កាលពីខ្ញុំធ្វើ គឺគេមានទាំងក្ដួរ ទាក់កក្ដួរឡើងលើដោយខ្សែរូតទៀតផង។ តើលោកពិតជាបានផ្ដល់ចម្លើយបែបនេះជាមួយនឹងសហចៅក្រមស៊ើបអង្កេតដែរឬទេ? ឬមួយ ក៏លោកចង់ផ្ដល់អ្វីបន្ថែមទៀត? ហើយលោកបាននិយាយថា៖ "ខ្ញុំដឹងរឿងនេះច្បាស់នៅពេលដែល ម្ដាយមីងខ្ញុំធ្លាប់ជាប់នៅទីនេះ ព្រមទាំងមាររបស់ខ្ញុំពីររូបទៀត។ ប៉ុន្តែមីងរបស់ខ្ញុំទេ ដែលនិយាយប្រាប់ពីរឿងទាក់កនេះ។ ហើយនៅដឹងថាមានស្នាមបន្សល់ទុករហូតដល់បច្ចុប្បន្ននេះ"។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកពិតជាបានឃើញដោយផ្ទាល់ភ្នែកអំពីអ្វីដែលបានកើតឡើងនៅពេលសួរចម្លើយអ្នកទោសនោះដែរឬទេ?

[១៥:២៩:៥០]

**ឆៈ** បាទ ខ្ញុំអត់ដែលបានឃើញផ្ទាល់ទេ បាទ។ ខ្ញុំនៅខាងក្រៅ បាទ។

**សៈ** ខ្ញុំយល់ពីអ្វីដែលលោកចង់ឆ្លើយ ប៉ុន្តែតើនៅពេលដែលលោកឈរជើងនៅក្រាំងតាចាន់ ហើយនៅខាងក្រៅ តើលោកអាចមើលការសួរចម្លើយដែរឬទេ? តើគេអនុញ្ញាតឲ្យលោកឈរមើលការសួរចម្លើយដែរឬទេ?

**ឆៈ** បាទ ពេលសួរចម្លើយ គេឲ្យខ្ញុំចេញក្រៅអស់ ចេញក្រៅបរិវេណរបង។

**សៈ** អ៊ីចឹង តើលោកចង់ផ្ដល់សក្ខីកម្មថា នៅក្នុងរយៈពេលជាងបីឆ្នាំ ឬក៏ពីរឆ្នាំ ដែលលោកនៅក្រាំងតាចាន់នុំង លោកមិនអាចមើលការសួរចម្លើយបានទេ។ អ៊ីចឹងមែនទេ? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទ។

**សៈ** តើលោកធ្លាប់និយាយ ឬក៏ពិភាក្សាជាមួយសមាជិកនៅក្នុងកងរបស់លោកអំពីការសួរចម្លើយដែរឬទេ?

[១៥:៣១:៣០]

**ឆៈ** បាទ ក្នុងចំណុចនេះគ្មាននាទីរបស់យើង អត់បាននិយាយគ្នាបានទេ បាទ។

**សៈ** លោក មាស សុខា ដែលលោកខ្ញុំនិយាយកន្លងមកហ្នឹង គាត់មិនត្រឹមតែផ្ដល់សក្ខីកម្មពីការសម្លាប់ប៉ុណ្ណោះទេ តែគាត់ក៏ផ្ដល់សក្ខីកម្មអំពីការធ្វើទារុណកម្មផងដែរ។ តើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាគាត់ឃើញការធ្វើទារុណកម្ម? ចំណែកលោកមិនអាចឃើញការធ្វើទារុណកម្មនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចហ្នឹង ខ្ញុំថាខ្ញុំមិនដែលបាននៅក្នុងទេ ពីព្រោះគេធ្វើជាបេក្ខជននៅខាងក្នុងបាទ។ តែពេលគេចាប់ធ្វើការ គេបញ្ជូនខ្ញុំទៅយាមខាងក្រៅ បាទ។

**ស៖** សក្ខីកម្មរបស់លោកចង់និយាយថា មានតែមនុស្សប្រាំនាក់ដែលអនុញ្ញាតឱ្យចូលទៅក្នុង។ អ៊ីចឹងតើលោកអាចប្រាប់បានដែរឬទេ ហេតុអ្វី មាស សុខា ហើយនិង សយ សែន អាចមើលឃើញការធ្វើទារុណកម្មនោះបាន?

**ឆ៖** បាទ ក្នុងចំណុចហ្នឹង ដឹងគេមើលឃើញគេដោយរបៀបណា។ ខ្ញុំមិនបានដឹងដែរបាទ។

**ស៖** ខ្ញុំចង់និយាយបន្ថែមទៀត អំពីបរិវេណនៃក្រាំងតាចាន់។ សមាជិកក្នុងកងរបស់លោក គឺ ឌុច បានផ្តល់សក្ខីកម្មកាលពីសប្តាហ៍មុន នៅចំពោះមុខអង្គជំនុំជម្រះនេះថា គឺថាមិនមានឧគ្គោសនសព្ទនៅក្នុងបរិវេណានោះទេ។ ប៉ុន្តែក្នុងពេលកន្លងមក នៅពេលដែលចុងនេះ គឺថាលោកថាមានធុងបាសមានផ្កាត្រកួន។ តើអ្នកណាដែលនិយាយត្រឹមត្រូវ គាត់ ឬក៏លោក?

[១៥:៣៤:០៤]

**ឆ៖** បាទ មានកូនម៉ាញេមួយតូចប៉ុណ្ណោះទេបាទ។ ក្នុងហ្នឹងកូនម៉ាញេហ្នឹង គាត់អុបល័រដោះបាទ។ អាកូនម៉ាញ៉េហ្នឹងវាប៉ុណ្ណេះៗ ហើយអាអុបល័រដោះពីរហ្នឹង បាទមានតែប៉ុណ្ណឹងទេ ក្នុងហ្នឹង។ ហើយវ៉ាដ្យូមានតែមួយគត់ក្នុងហ្នឹង បាទ។

**ស៖** តើលោកមានចង់មានន័យថាម៉េចដែរ នៅពេលដែលលោកថាមានវ៉ាដ្យូ មានវិទ្យុនោះ?

**ឆ៖** ដែលខ្ញុំនិយាយថា កូនធុងបាសហ្នឹង អាម៉ាញេប៉ុណ្ណឹង ដោះ អុបល័រដោះបាន។ មានតែមួយហ្នឹង ហើយវ៉ាដ្យូមួយប៉ុនកដៃមួយ ក្នុងមន្ទីរហ្នឹងមានតែប៉ុណ្ណឹងទេ បាទ។

**ស៖** តើធុងបាស ហើយនិងវ៉ាដ្យូហ្នឹងគេប្រើដើម្បីធ្វើអ្វីដែរ ដើម្បីស្តាប់វិទ្យុកម្ពុជា ឬមួយក៏យ៉ាងម៉េច តើលោកចង់និយាយហ្នឹងមានន័យម៉េចដែរ?

**ឆ៖** បាទ កូនវ៉ាដ្យូហ្នឹងស្តាប់ព័ត៌មានផ្សេងៗក្នុងប្រទេស បាទ។

**ស៖** អ៊ីចឹងធុងបាសហ្នឹង គេប្រើដើម្បីតែគោលដៅតែមួយហ្នឹងទេ ឬមួយក៏មានប្រើដើម្បីអ្វីផ្សេងទៀត?

**ឆ៖** ដែលចំណុចធុងបាស ហ្នឹងគ្មានទេបាទ មានតែវ៉ាដ្យូៗដោះហ្នឹង សូមបញ្ជាក់បាទ។ កូនវ៉ាដ្យូតូចមួយតែប៉ុណ្ណឹងទេ។

**ស៖** តើលោកអាចប្រើប្រាស់ -- តើលោកអាចបង្ហាញទំហំហ្នឹង យកដៃៗលោកហ្នឹងបង្ហាញ

ទំហំថាតើម៉ាញេ ឬក៏ធុងបាសហ្នឹង វាមានទំហំប៉ុនណា អីប៉ុនណាអាចធ្វើដៃបានទេលោក?

**ឆ៖** ម៉ាញេហ្នឹងប៉ុននេះ។ ចន្លោះកណ្ដាលអំភ្លីវា សងខាងអុបល័រដោះហូតចេញ បាទ។

**ស៖** តើ--

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថាការដែលយើងធ្វើដៃហ្នឹង វាអត់អាចជួយអ្វីបានដល់ប្រតិចារឹកនោះឡើយ ព្រោះថាប្រតិចារឹកមិនអាចបង្ហាញដៃដែលលោកធ្វើទេ។ ដូច្នេះតើលោកអាចបង្ហាញទំហំ ឬក៏អាចបង្ហាញជាខ្នាតនៃធុងបាស ឬក៏ស្ពីដែលលោករៀបរាប់នោះ? ព្រោះធ្វើដៃនេះ យើងកត់ចូលប្រតិចារិកវាមិនកើត។

**លោក វ៉ាន់ សឿន៖**

**ឆ៖** បាទ ម៉ាញេនោះប្រហែលជា ប្រវែងជាមិនបានបួនតឹកទេ។ ប៉ុន្តែអុបល័រដោះសងខាងប្រហែលជាមួយតឹកម្ខាង បាទ។

[១៥:៣៧:៣៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំដឹងថាវាកន្លងមកយូរមកហើយ ប៉ុន្តែតើលោកអាចប្រាប់បានទេ ថាតើធុងបាសតូចៗពីរដោះបានហ្នឹង ថាតើវាអាចឮបានប្រហែលប៉ុន្មានម៉ែត្រដែរ? ខ្ញុំចង់និយាយថាតើយើងត្រូវឈរប៉ុន្មានម៉ែត្រទើបអាចស្ដាប់ឮហ្នឹង ឬក៏ប៉ុន្មានម៉ែត្រឆ្ងាយពីធុងបាសនោះ ទើបស្ដាប់លែងឮនោះ។ លោកប្រាប់បានទេ?

**ឆ៖** បាទ កូនម៉ាញេនោះប្រហែលជាចម្ងាយនោះប្រហែល១៥ ម៉ែត្រដែរបាទ។

**ស៖** ហើយនៅពេលដែលលោកនៅឆ្ងាយប្រហែលជា២០-៣០ម៉ែត្រ អ៊ីចឹងលោកស្ដាប់លែងឮហើយអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ហេតុផលដែលខ្ញុំសួរគឺថា លោក សយ សែន បានផ្ដល់សក្ខីកម្មដល់អង្គជំនុំជម្រះថា ធុងបាសហ្នឹងត្រូវបានគេប្រើដើម្បីកុំឱ្យអ្នកទោសឮសូរការស្រែកឈឺចាប់នៅពេលគេសម្លាប់ ហើយក៏ថាសំឡេងហ្នឹងវាខ្លាំង ហើយអ្នកទោសគាត់ស្ដាប់អត់ឮថាមានអ្វីកើតឡើងនោះទេ។ ទាំងនៅពេលសួរ

ចម្លើយ ក៏ដូចជានៅក្រោយការសួរចម្លើយ។ តើលោកយល់យ៉ាងណាដែរចំពោះសក្ខីកម្មនេះ?

**ឆៈ** បាទ ត្រង់ហ្នឹង ខ្ញុំមិនដឹងថាយ៉ាងម៉េចដែរ ដល់តែគេនិយាយអ៊ីចឹងហើយខ្ញុំមិនដឹងថាយ៉ាងម៉េចដែរ ពីព្រោះក្នុងហ្នឹងអត់មានធុងបាសមីក្រូទេបាទ។

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំគិតថាខ្ញុំមានប្រធានបទបន្តទៅទៀត ប៉ុន្តែឥឡូវនេះខ្ញុំឃើញម៉ោងបីសែសិបហើយ។ តើយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំៈ**

អរគុណលោកមេធាវី ហើយអរគុណលោក វ៉ាន់ សឿន។ ហើយដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅរសៀលនេះ អង្គជំនុំជម្រះផ្អាកត្រឹមនេះសិន។ ហើយដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីហ្នឹងមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយពេលនេះលោកអាចសម្រាក និងអាចវិលត្រឡប់ទៅកន្លែងដែលលោកស្នាក់នៅវិញបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក វ៉ាន់ សឿន វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ។ ហើយនិងឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។ ហើយអង្គជំនុំជម្រះក៏សូមកោះអញ្ជើញលោក ម៉ម រិទ្ធា ជាមេធាវីប្រឹក្សាសាក្សីមកបន្តចូលរួមនៅក្នុងកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មសាក្សីរូបនេះបន្តទៀតដែរនៅព្រឹកថ្ងៃស្អែក។

អញ្ជើញទៅចុះ!

*(សាក្សីនិងមេធាវីប្រឹក្សាចាកចេញពីបន្ទប់សវនាការ)*

[១៥:៤១:២៦]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះលើបញ្ហានៃសំណើសុំរបស់លោកក្រុមមេធាវីការពារក្ដីលោក នួន ជា លើសំណើសុំមួយ ដែលបានដាក់មកអង្គជំនុំជម្រះនូវឯកសារចម្លងជូនជ្រាប។ ហើយសំណើនេះមិនទាន់បានបកប្រែជាភាសាខ្មែរនៅឡើយទេ។ ហើយទោះបីជាយ៉ាងនេះក៏ដោយ គឺសំណើសុំនេះគឺលោកមេធាវីបានលើកឡើងពាក់ព័ន្ធជាមួយនឹងសំណើសុំឲ្យមានការផ្អាកស្ដាប់សក្ខីកម្មសាក្សី ដែលអង្គជំនុំជម្រះបានកំណត់ការបរិច្ឆេទដែលធ្វើសវនាការបន្ទាប់ពីសាក្សីរូបនេះ ហើយនិងដើមសប្ដាហ៍ក្រោយ ដោយសារបញ្ហានេះ គឺខាងមេធាវីអះអាងថាមានការពាក់ព័ន្ធជិតស្និទ្ធទៅនឹងឯកសារ ដែលសហព្រះរាជ

អាជ្ញាបានស្នើសុំពីសំណុំរឿង០០៤ យកមកដាក់បញ្ចូល ដោយសុំពេលវេលាសម្រាប់ពិនិត្យសិក្សាឯកសារនោះ។ ហើយឥឡូវនេះ អង្គជំនុំជម្រះដើម្បីមានមូលដ្ឋានក្នុងការពិចារណាសម្រេចលើបញ្ហានេះ។ ហើយបញ្ហានោះគឺមានច្រើន ប៉ុន្តែដោយសារស្ថានភាពពេលវេលានេះបន្ទាន់ ដែលអង្គជំនុំជម្រះត្រូវការស្តាប់តែសារណាផ្ទាល់មាត់របស់មេធាវីការពារក្តីលើសំណើសុំពាក់ព័ន្ធជាមួយនឹងការស្តាប់សក្ខីកម្មសាក្សីនៅចំពោះមុខ គឺសាក្សីដែលមានរហស្សនាម 2-TCW-803 ហើយនិង TCW-809 ប៉ុណ្ណោះ។ ចំណែកឯសាក្សីផ្សេងទៀតដែលមានការភាពពាក់ព័ន្ធនោះ គឺអង្គជំនុំជម្រះនឹងទទួលការ -- សារណាជាលាយលក្ខណ៍អក្សរ។ ហើយអង្គជំនុំជម្រះផ្តល់វេទិកាទៅលោកមេធាវីការពារក្តីលោក នួន ជា មានពេលវេលាដប់នាទីក្នុងការឡើងបង្ហាញអំពីសារណាពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយភាគីសហព្រះរាជអាជ្ញា ហើយនិងភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏មានពេលវេលា១០នាទីដែរ ក្នុងការឆ្លើយតបទៅនឹងសារណាផ្ទាល់មាត់ ពាក់ព័ន្ធនឹងករណីនេះ។

សូមអញ្ជើញលោកមេធាវី!

[១៥:៤៣:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ វាមិនមែនជាការងាយស្រួលដែលផ្តោតតែទៅលើសាក្សីបន្ទាប់នេះទេ។ អ្វីៗទាំងអស់វាមានចំណងទាក់ទងជាមួយនឹងគ្នា។ ការនិយាយតែពីរបីឃ្លា យើងខ្ញុំមានអារម្មណ៍ថា ដោយសារតែភស្តុតាងថ្មីដែលត្រូវយកមកប្រើប្រាស់នោះ។ ដូច្នេះ យើងមិនអាចបន្តទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី ឬក៏ភូមិភាគពាយ័ព្យនោះទេ។ ឥឡូវនេះ ខ្ញុំសូមយោងទៅអនុស្សរណៈដែលយើងបានព្រាង ហើយផ្ញើជូនអង្គជំនុំជម្រះ កាល -- តាមរយៈអ៊ីម៉ែលកាលពីព្រឹកមិញនេះ បើសិនពាក់ព័ន្ធទៅនឹងសំណើសុំជាបន្ទាន់ទាក់ទងទៅនឹងសាក្សីបន្ទាប់នេះ ជំហររបស់ក្រុមយើងខ្ញុំគឺថាត្រូវផ្អាកទាំងស្រុង។ យើងខ្ញុំមិនមានបំណងអ្វីធ្វើឲ្យមានការយឺតយ៉ាវដល់ដំណើរការនីតិវិធីនោះទេ។

ដូច្នេះយើងខ្ញុំក៏រៀបចំដាក់ចេញនូវជម្រើស ដែលជាគេគោលការណ៍ យើងថាយើងអាចបន្តជាមួយសាក្សីដែលផ្តល់សក្ខីកម្មនូវអ្វីដែលកើតឡើងនៅក្រាំងតាចាន់។ អង្គជំនុំជម្រះក៏បានកំណត់សួរសក្ខីកម្មទៅលើអ្នកយាមនៅក្រាំងតាចាន់បន្ថែមទៀតដែរ។ ចំពោះសាក្សីដែលអាចផ្តល់សក្ខីកម្មនូវអ្វីដែលកើតនៅមូលដ្ឋាន ដែលកើតនៅទីន្លែងនោះផ្ទាល់ យើងក៏មានសាក្សីបែបនេះពីខាងដើមមុនដែរ ក៏ប៉ុន្តែនៅពេលនោះ គឺយើងនិយាយសំដៅទៅលើសាក្សីដែលត្រូវមកនៅថ្ងៃស្អែក ឬសាក្សីបន្ទាប់នេះ។

ដោយសារវាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធមិនមែនតែស្រុក១០៥ទេ ក៏ដូចជាតំបន់១៣ និងភូមិភាគនិរតីទាំងមូលតែម្តង។

នៅក្នុងការបង្ហាញអំពីចម្លើយ គឺថាយើងមានចម្លើយជាង៣០០០ទំព័រ យើងធ្វើការស្រាវជ្រាវចំណុចមួយដើម្បីផ្តល់ជូនអង្គជំនុំជម្រះ។ នៅក្នុងក្រុណ្ឌឯកសារសម្រាប់សំណុំរឿង០០៣ និង០០៤ ពាក្យថា តំបន់១៣ គឺត្រូវបាននិយាយ៦៩ដង។ “ស្រុក១០៥” និយាយប្រាំបីដង, មន្ទីរ២៤ គឺនិយាយ៣៥ដង, ស្រុកត្រាំកក់ និយាយ២១២ដង។ សំណុំរឿង០០៤ និយាយអំពីព្រឹត្តិការណ៍ដែលកើតឡើងនៅភូមិភាគនិរតីជាទូទៅតែម្តង។

[១៥:៤៦:៤៦]

ប៉ុន្តែនៅក្នុងស្រុក១០៥ និងតំបន់១៣ ក៏មាននិយាយនៅក្នុងស្រុក និងតំបន់១៣ នៃភូមិភាគនេះដែរ។ ខ្ញុំមិនដឹងថាតើយើងត្រូវប្រើប្រាស់វិធីសាស្ត្របែបណានោះទេ ក៏ប៉ុន្តែលោកប្រធាន ចម្លើយមួយក្នុងចំណោមចម្លើយជាច្រើនពាក់ព័ន្ធទៅនឹងសាក្សីនៅថ្ងៃស្អែក ដែលផ្តល់ជូនសហចៅក្រមស៊ើបអង្កេតនោះ គឺឯកសារ D119/82 នៅត្រង់ទំព័រ១០ សាក្សីរូបនេះគឺថាបានប្រឈមមុខ សួរតទល់ទៅនឹងសក្ខីកម្មរបស់បុគ្គលម្នាក់ទៀត។ បុគ្គលម្នាក់នេះត្រូវបានសហចៅក្រមស៊ើបអង្កេតចោទប្រកាន់កំបាំងមុខកាលពីម្សិលមិញ។ ទោះបីជាសាក្សីនិយាយអំពីបុគ្គលរូបនេះយ៉ាងណាក៏ដោយ គឺវាពាក់ព័ន្ធទៅនឹងសំណុំរឿងរបស់យើង។ សាក្សីសម្រាប់ថ្ងៃស្អែកនេះ គឺនិយាយអំពីរចនាសម្ព័ន្ធទំនាក់ទំនង បណ្តាញទំនាក់ទំនងរវាងស្រុក តំបន់ ទៅភូមិភាគ។ ខ្ញុំមិននិយាយអំពីការអនុវត្តជាក់ស្តែងពាក់ព័ន្ធទៅនឹងភស្តុតាងដ៏ច្រើនបែបនេះនោះទេ។ បើសិនណាយើងអាចបាន ធ្វើទៅបាន គឺយើងគួរមិនត្រូវទៅនិយាយអំពីទីតាំងឧក្រិដ្ឋកម្មដទៃទៀតនៅភូមិភាគនិរតីទេ។

ខ្ញុំគិតថា ទំនប់១មករា វាជាផ្នែកមួយដែលវាអាចយកមកនិយាយបាន។ ខ្ញុំមិនមានបំណងពន្យារកិច្ចដំណើរការនីតិវិធីទេ។ យើងបានទទួលបាននូវជម្រើសផ្សេងៗដើម្បីបន្តសួរចម្លើយឆ្មាំគុក ក៏ដូចជាអ្នកដទៃទៀតនៅគុកក្រាំងតាចាន់។ ហើយការផ្តល់នូវជម្រើសទាំងនេះ ខ្ញុំគិតឃើញថាមិនមានព្យសនកម្មអ្វី មិនមានការប៉ះពាល់អ្វីធំដុំនោះទេ ដោយសារវាពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅទីនោះ។ ដូច្នេះយើងខ្ញុំស្នើសុំនូវលទ្ធភាព ដើម្បីពិភាក្សាឲ្យបានស៊ីជម្រៅទៅលើបញ្ហាទាំងអស់នេះ។ យើងមិននិយាយសំដៅតែទៅលើសាក្សីនៅថ្ងៃស្អែកនោះទេ។ យើងអាចជួបប្រទះនូវបញ្ហាដ៏សំខាន់ៗ និងការពិភាក្សាគ្នាដ៏សំខាន់ៗ។ តើយើងត្រូវធ្វើយ៉ាងដូចម្តេចចំពោះសំណុំរឿង០០៣ និង០០៤ ដែលត្រូវយកមកប្រើប្រាស់

ក្នុងសំណុំរឿង០០២។

[១៥:៤៩:៤០]

ដូច្នេះ គួរតែមានការរៀបចំកិច្ចប្រជុំរៀបចំសវនាការឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន ថាតើយើងត្រូវដោះស្រាយយ៉ាងដូចម្ដេចនោះ? ក៏ប៉ុន្តែសម្រាប់ថ្ងៃស្អែកនេះ ខ្ញុំយល់ឃើញថា យើងមិនគួរស្ដាប់សក្ខីកម្មរូបនេះទេ ហើយក៏ដូចជាសាក្សីម្នាក់ទៀតដែរ ដែលស្ថិតនៅក្នុងថ្នាក់ ដែលយើងត្រូវសួរពាក់ព័ន្ធទៅនឹងតំបន់ ព្រឹត្តិការណ៍កើតឡើងនៅក្នុងភូមិភាគនោះ។ នេះគឺជាប្រធានបទដែលកំពុងធ្វើការស៊ើបអង្កេតនៅឡើយ។ ប្រហែលជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏កំពុងតែស៊ើបនៅក្នុងករណីនេះដែរ។ ដូច្នេះ ការគ្រាន់តែយកមកពិនិត្យតែរឿងសាក្សីថ្ងៃស្អែក គឺខ្ញុំយល់ឃើញថាមិនគួរណាកោះហៅសាក្សីថ្ងៃស្អែកនោះទេ គួរតែប្រើប្រាស់ជម្រើសណាមួយផ្សេង គួរតែកោះហៅសាក្សីដទៃទៀតដែលនៅសេសសល់ គឺកម្មាភិបាលធ្វើការនៅគុកក្រាំងតាចាន់ ដែលមិនទាន់សាកសួរនៅឡើយ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអញ្ជើញ លោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំបាទមានការកត់សម្គាល់លើពីរចំណុច ទាក់ទងទៅនឹងបញ្ហាដែលត្រូវលើកនៅពេលនេះ។

ទី១ ខ្ញុំចង់លើកអំពីការចាត់ឲ្យមានការពិភាក្សាឡើងនូវលើបញ្ហានេះ ដោយផ្អែកទៅលើរយៈពេលដ៏ខ្លី ដែលលោកប្រធានបានបញ្ជាក់អំពីភាពចាំបាច់ ភាពបន្ទាន់នេះហើយ ក៏ប៉ុន្តែចំណុចមួយដែលអង្គជំនុំជម្រះគួរពិចារណាផងនោះ គឺថាខាងក្រុមយើងធ្វើការជាភាសាបារាំង។ ហើយឯកសារដែលបានដាក់ជូននេះជាភាសាអង់គ្លេស ដែលជាបញ្ហាដែលមានការលំបាកសម្រាប់យើងដែរ។ តែទោះយ៉ាងណាក៏ដោយ ខ្ញុំសូមជាសំណូមពរសម្រាប់ការចាត់នីតិវិធីលើកក្រោយថា អាចឲ្យផ្ដល់ពេលវេលាឲ្យយើងគ្រប់គ្រាន់សម្រាប់ការពិភាក្សាទៅលើប្រធានបទ ហើយក៏យ៉ាងហោចណាស់ ក៏អាចផ្ដល់ឯកសារជាភាសាបារាំងដែលយើងប្រើ ឬឲ្យភាសាខ្មែរ ដែលអាចឲ្យយើងអាចធ្វើការបាន។ នេះសម្រាប់ការចាត់ការលើពិភាក្សាលើកក្រោយ។

ដោយឡែកចំពោះសំណើនេះ ជាខ្លឹមសារ យើងមានការលំបាកច្រើនណាស់សម្រាប់ក្រុមយើង

ដោយសារថ្ងៃត្រង់នេះ យើងទើបនឹងទទួលការផ្តល់ថែមនូវឯកសារចំនួនពីរក្រឡុធំទៀត ពីសហព្រះរាជអាជ្ញាដែលទើបតែធ្វើការបកប្រែហើយ។ ដូច្នេះ ឯកសារដែលមានកន្លងមកនេះ វាមានភាពលំបាកសម្រាប់យើង ដូចគ្នានឹងបញ្ហាបកប្រែភាសានេះដែរ ដោយសារយើងប្រើជាភាសាបារាំង ជាភាសាពិភាក្សាធំ ច្រើន។

[១៥:៥២:៣១]

បាទ ដូច្នេះ បញ្ហាភាសានេះវាជាចំណោទមួយសម្រាប់យើងហើយ ទៅលើឯកសារដែលដកចេញពីសំណុំរឿង០០៣ ឬ០០៤ ដែលតាមការស្នើសុំរបស់សហព្រះរាជអាជ្ញា។ ហើយបញ្ហាមួយទៀត យើងមើលឃើញ អំពីការលំបាករបស់យើងដែលយើងមិនមានលទ្ធភាពក្នុងការចូលទៅលើឯកសារនុងទាំងស្រុង ឧទាហរណ៍--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី យើងពេលនេះ យើងមានចំណាយពេលតែ២០នាទីទេ។ យើងចង់ដឹងអំពីបញ្ហាប្រឈមទាំងឡាយរបស់ភាគី ពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មសាក្សី 803 និង 809 ដែលអង្គជំនុំជម្រះបានកំណត់កាលវិភាគសម្រាប់ធ្វើសវនាការច្បាស់លាស់ហើយ។ ស្រាប់តែថ្ងៃនេះ អង្គជំនុំជម្រះ បានទទួលនូវសំណើសុំពីមេធាវី នួន ជា សុំឲ្យផ្អាកសវនាការ។ ការផ្អាកសវនាការ វាមិនមែនជាការងាយស្រួលទេ។ អាចងាយស្រួលចំពោះភាគី ប៉ុន្តែវាមិនមែនងាយស្រួលចំពោះអង្គជំនុំជម្រះ ពីព្រោះអង្គជំនុំជម្រះត្រូវប្រឈមជាមួយនឹងសាធារណជន។ ហេតុអីបានជាការគម្រោងរៀបចំផែនការសកម្មភាព ក្នុងការកំណត់សវនាការមិនធ្វើ ហើយមកធ្វើជារបៀបចៃដន្យ មកដល់ហើយលើកដូច្នេះ! យើងធ្លាប់លើកម្តងហើយម្តងទៀត ដោយសារមូលហេតុបញ្ហាការដាក់ឯកសារថ្មីដែលភាគីសង្ខាងមិនមានឱកាស។ យើងលៃពេលឲ្យមានឱកាស។ ឥឡូវហ្នឹង លៃពេលឲ្យមានឱកាសហើយ។ ហើយការដាក់ឯកសារដែលដាក់មកវាំងស្នើសុំឲ្យមិនឲ្យធ្វើសវនាការ ឲ្យលើកសវនាការថ្ងៃស្អែកនេះ គឺទើបនឹងដាក់ថ្ងៃនេះ ហើយជាភាសាអង់គ្លេសនៅឡើយទេ។ យើងបានប្រាប់ហើយអំមិញ សូម្បីតែភាសាខ្មែរក៏មិនមានផង យើងទៅពឹងផ្អែកអ្នកបកប្រែភាសាទេ។ យើងចង់ដឹងពិតប្រាកដថា ពីហេតុផលធ្ងន់ធ្ងរយ៉ាងម៉េចដែលនាំឲ្យស្នើសុំនេះ។ តើអង្គជំនុំជម្រះគួរទទួល ឬមិនទទួលលើការលើកសវនាការសម្រាប់សាក្សី 803 និង 809។ ចំពោះបញ្ហាដទៃទៀត យើងទុកពេលវេលាឲ្យមេធាវីការពារក្តី នួន ជា ដាក់សារណាជាលាយលក្ខណ៍អក្សរ ហើយដើម្បីឲ្យភាគីហ្នឹងមានការឆ្លើយឆ្លងគ្នា ព្រោះយើងដោះស្រាយបានពេលវេលាចំពោះមុខ

នេះ។ អ៊ីចឹងបើឥឡូវនេះ យើងកំណត់ពេលវេលាថា បញ្ហាដែលយើងនៅសួរស្តាប់សក្ខីកម្មសាក្សីពីស្រែកល្ងាច និងនៅដើមសប្តាហ៍ក្រោយនេះ ចំពោះសាក្សីពីររូបហ្នឹង មានមតិយោបល់យ៉ាងម៉េច?

[១៥:៥៤:៥៦]

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំកំពុងជម្រាបពីបញ្ហាលំបាកនេះហើយ ដោយសារឯកសារទាំងអស់ដែលដាក់ចូលនេះ វាជាប់ពាក់ព័ន្ធទៅនឹងក្រាំងតាចាន់។ ហើយបើសិនជាសាក្សីដែលជាកម្មាភិបាលនៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹងគាត់មកឆ្លើយ ហើយយើងមិនបានពិនិត្យទៅលើឯកសារដែលទាក់ទងទៅនឹងអង្គហេតុដែលនៅជុំវិញនេះបានគ្រប់គ្រាន់ អាហ្នឹងវាធ្វើឲ្យមានការលំបាកដល់យើង។ ដូចខ្ញុំបានជម្រាបជូនអម្បាញ់មិញហើយ សូម្បីតែឯកសារដែលបានផ្តល់ឲ្យយើងគឺទើបតែបានទទួលនូវរសៀលពេលថ្ងៃត្រង់នេះទេ។ ដូច្នេះវាមានការលំបាកហើយសម្រាប់យើង។ ហើយជារួម គឺថាយើងសម្រាប់ក្រុមយើងគាំទ្រការស្នើឲ្យផ្អាកសវនាការនេះ ហើយសុំឲ្យអង្គជំនុំជម្រះពិនិត្យទៅលើការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យទៅលើឯកសារនេះផង ពីព្រោះថាឯកសារដែលមានទំហំរាប់ពាន់ទំព័រ វាត្រូវការពេលវេលាសមស្របដើម្បីធ្វើការពិនិត្យ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅ -- ហ្សង់ម៉ាក?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន ខ្ញុំនិយាយដោយខ្លីទេ។ ខ្ញុំសូមឲ្យមេធាវីការពារក្តីកាត់ផ្តាច់ខ្ញុំ បើសិន បើខ្ញុំនិយាយមិនត្រឹមត្រូវ។ ប្រសិនបើយើងផ្តោតទៅលើសាក្សី 803 ហើយនិង 809 ចម្លើយដែលពាក់ព័ន្ធរបស់ពួកគាត់ដែលមកពីសំណុំរឿង០០៣ និង ០០៤ ត្រូវបានប្រគល់ជូនតាំងពីថ្ងៃទី១៦ តុលាឆ្នាំមុនឯណោះ។ ហើយបន្ទាប់មកគាត់ប្រកែកមិនទទួល ហើយក្រោយមកនៅថ្ងៃ០៤ វិច្ឆិកា គាត់យល់ព្រមទទួល ខាងនួន ជា។ ហើយខាង ខៀវ សំផន ទទួលនៅថ្ងៃទី២២ ធ្នូ។ ដូច្នេះ មេធាវីការពារក្តីលោក នួន ជា បានបញ្ជាក់នៅក្នុងសវនាការកាលពីខែកុម្ភៈ រួចមកហើយថាខ្លួនមានឱកាស និងមានលទ្ធភាពក្នុងការអានឯកសារទាំងអស់ដែលបានផ្តល់ជូននៅពេលនោះ។ គឺនៅសវនាការថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១៥។

[១៥:៥៧:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម គឺលោកត្រឹមត្រូវហើយ យើងសហព្រះរាជអាជ្ញាក៏អាចជួយបញ្ជាក់ផងដែរ សូម្បីតែព្រឹកមិញនេះ ចម្លើយថ្មី គឺយើងបានទទួលនូវសំណុំឯកសារប្រាំ ប្រាមួយក្រូណូ។ ហើយយើងបានស្នើសុំឲ្យផ្អាកសវនាការ ពីរថ្ងៃកន្លះ ដើម្បីឲ្យក្រុមយើងអាននូវចម្លើយថ្មីៗនេះ។ នេះមិនមែនតែជាភស្តុតាងនោះទេ។ ប៉ុន្តែនិយាយឲ្យចំទៅគឺថា ឯកសារនេះមានជិត៣០០ទំព័រ ទើបតែទទួលបានពីរសប្តាហ៍មុននេះទេ។ ជាង៣០០០ទំព័រ ទទួលបានពីរសប្តាហ៍។ ដូច្នេះមិនអាចមានពេលអានបានទេ។ ហើយឯកសារទាំងអស់នេះ វាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍សំខាន់ៗកើតនៅភូមិភាគនិរតី ទាក់ទងទៅនឹងអ្វីដែលយើងកំពុងតែពិភាក្សាគ្នានេះ។ ដូច្នេះមិនមែនជាយើងបាន -- ទើបតែ -- រឿងទើបកើតក្នុងរយៈពេលប៉ុន្មាននាទីនេះទេ គឺថាបានស្នើសុំតាំងពីមុនមកម្ល៉េះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមលើកឡើងសង្ខេបទេ។ ខ្ញុំយល់ស្របថាគួរមានការពិភាក្សាគ្នាទៅលើបញ្ហាដ៏ទូលំទូលាយបែបនេះបន្តទៅទៀត។ ប៉ុន្តែពាក់ព័ន្ធទៅនឹងសាក្សីដែលកំណត់សម្រាប់ថ្ងៃស្អែក គឺសាក្សីពីរនាក់ គឺ 803 -- 809 គឺយើងបានកំណត់រួចមកហើយ។ ប៉ុន្តែក៏ត្រូវផ្អាកដល់ជិតដំណាច់ខែនេះឯណោះ។ ហើយមិនមានការបង្ហាញណាមួយពីសំណាក់ក្រុមមេធាវីការពារក្តីនូវមូលហេតុដែលនាំឲ្យផ្អាកនូវការសួរចម្លើយសាក្សីនេះទេ។ មិនមែនគ្រាន់តែមកនិយាយថា អូ៎! មានចម្លើយថ្មីៗច្រើនសន្ធឹកសន្ធាប់បែបនេះនោះទេ។ តាមពិតទៅ ក្នុងចម្លើយថ្មីៗ យើងរៀបចំជា២០ចម្លើយ គឺការពាក់ព័ន្ធទៅនឹងត្រាំកក់ -- ស្រុកត្រាំកក់ និងគុកក្រាំងតាចាន់។ ខ្ញុំមើលមួយពាក្យម្តងៗហើយ ក្នុងកិច្ចសម្ភាសន៍ ១០នោះមានតែមួយទេ ដែលបាននិយាយពាក់ព័ន្ធទៅនឹងសាក្សីដែលត្រូវមកស្អែកនេះ គឺមានតែកំណត់ហេតុមួយទេ។ គឺនិយាយពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ ដែលថាគឺជាលេខាស្រុកនៅឆ្នាំ៧៨ ហើយក៏បានធ្វើអធិបតីភាពនៅពេលដែលមានកិច្ចប្រជុំជាមួយមេឃុំទាំងអស់។ នៅក្នុងចំណោមភស្តុតាងទាំងអស់ដែលពាក់ព័ន្ធទៅនឹងសាក្សីដែលត្រូវចូលខ្លួនមកនេះ។ ព័ត៌មានហ្នឹង ខ្ញុំ -- អ្នកណាក៏ដឹងដែរ។ គឺថាមានសាក្សីជាច្រើនបាននិយាយពាក់ព័ន្ធទៅដល់សាក្សីរូបនេះហើយតើ។ ដូច្នេះ ជំហររបស់យើងខ្ញុំ លោកប្រធាន គឺបញ្ហានេះ ត្រូវសម្រេចទៅលើការបង្ហាញឲ្យ -- នូវព័ត៌មានជាក់លាក់ឲ្យច្បាស់លាស់ មិនមានហេតុផល

អ្វីដែលត្រូវផ្អាកការសួរយកសក្ខីកម្មសាក្សីរូបនេះនោះទេ ហើយគ្មានមូលហេតុអ្វីដែលត្រូវផ្អាកសាក្សីដែលមកពីត្រាំកក់នោះទេ។ ហើយក៏មិនមានភស្តុតាងដែលត្រូវថាពន្យារទៅដល់ការសួរសក្ខីកម្មពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់នោះដែរ។

[១៦:០១:០៣]

ដូច្នេះ វាច្បាស់ហើយថា ចម្លើយដែលបានផ្ដល់នៅតុលាការនោះមិនមែនជាចម្លើយថ្មីទេ។ នេះជាការបកប្រែនូវថ្មី នូវអ្វី ដោយសារមេធាវីការពារក្ដីមិនមានលទ្ធភាពចូលមើលឯកសារអេឡិចត្រូនិកនៅពេលដែលការបកប្រែថ្មីៗនៃកិច្ចសម្ភាសន៍នេះ ត្រូវបានយកមកដាក់បង្ហាញ គឺថាពេលនោះក្រុមគាត់នឹងមានលទ្ធភាពចូលមើលទៅឯកសារទាំងអស់ហ្នឹងដែរ។ អ្វីដែលគាត់ទទួលបាននៅថ្ងៃនេះ គឺគ្រាន់តែការបកប្រែថ្មីនៃកិច្ចសម្ភាសន៍ចាស់តែប៉ុណ្ណោះ។ ចំណុចចុងក្រោយ ទឡ្ហីករណ៍ភាពច្រើន គឺវាពាក់ព័ន្ធទៅនឹងចម្លើយដ៏ច្រើន គឺថាមានចម្លើយដ៏ច្រើន។ ខ្ញុំសូមនិយាយបែបនេះ សំណុំរឿង០២ ពាក់ព័ន្ធឯកសារជាងម្ភៃពាន់ –២០.០០០ឯកសារ– ជាសំណុំរឿងដែលមានឯកសារដ៏ច្រើន។ មេធាវីការពារក្ដីក្រុម នួន ជា នេះកាលពីសប្ដាហ៍មុន នៅពេលដែលគេរៀបចំជាបញ្ជីសាក្សី គឺថាពួកគាត់បានប្រើថា នឹងប្រើពេលកន្លះថ្ងៃ ហើយដាក់បញ្ចូលឯកសារដ៏ច្រើន ច្រើនជាងកិច្ចសម្ភាសន៍ដែលយើងកំពុងនិយាយគ្នាទៅទៀត។

[១៦:០២:២៧]

អង្គជំនុំជម្រះបានផ្ដល់ពេលវេលាជាច្រើនថ្ងៃ ថាមិនគ្រប់ទេ ប៉ុណ្ណឹងហើយនៅមិនគ្រប់ថ្ងៃ ខ្ញុំមិនចាំប៉ុន្មាននោះទេ ប៉ុន្តែអ្វីដែលខ្ញុំអាចនិយាយបាន គឺត្រូវតែចែកកំណត់ហេតុស្ដាប់ចម្លើយហ្នឹងជាក្រុមៗទៅ ហើយការិយាល័យសហព្រះរាជអាជ្ញាមិនមានកាតព្វកិច្ចតែអានតែកំណត់ហេតុស្ដាប់ចម្លើយនោះទេ។ នៅក្នុងសវនាការ យើងអានគ្រប់កិច្ចសម្ភាសន៍ទាំងអស់ ដែលបានដាក់ចូលមកសំណុំរឿង០៣ និង០៤។ ហើយបន្ទាប់មក យើងក៏យើងកំណត់ថា តើបញ្ហាអ្វីខ្លះដែលមានការពាក់ព័ន្ធគ្នា ហើយបន្ទាប់មកយើងក៏ដាក់សំណើសុំដើម្បីមានចំណាត់ការនេះ។ ហើយនៅក្នុងពេលជាមួយគ្នានេះ ដែលអ្វីដែលយើងកំពុងតែធ្វើនេះ គឺជាការឆ្លើយតបរបស់យើងហើយ។ យើងខ្ញុំយល់ថា ភាគីទាំងអស់ដែលនៅទីនេះ គឺយើងចង់ទាមទារឲ្យមានការជំនុំជម្រះនៅក្នុងរឿងក្ដីនេះ។ ប៉ុន្តែមិនមានមូលហេតុអ្វីដែលត្រូវពន្យារកិច្ចដំណើរការនីតិវិធីសម្រាប់សួរសក្ខីកម្មសាក្សីបន្ទាប់នេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញភាគីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៦:០៣:៤៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីទេ។ ខ្ញុំសូមបញ្ជាក់ថាខាងយើង យើងត្រៀមខ្លួនរួចហើយ ក្នុងការស្ដាប់ចម្លើយរបស់សាក្សី 803។ ដូច្នេះ គឺអង្គជំនុំជម្រះជាអ្នកសម្រេចទៅពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្ដី ក៏ប៉ុន្តែយើង ខាងយើងក៏មានការលំបាកជាក់ស្ដែងដែរ ហើយយើងនឹងត្រៀមខ្លួនក្នុងការពិភាក្សាទៅលើបញ្ហាទាំងអស់នេះ ជាផ្ទាល់មាត់ នៅក្នុងកិច្ចប្រជុំសវនាការ ឬក៏ជាលាយលក្ខណ៍អក្សរដើម្បីឆ្លើយតបទៅនឹងសំណើរបស់លោក នួន ជា។ ការលំបាកជាក់ស្ដែងដែលយើងកំពុងជួបតែប្រទះនោះ គឺវាពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតឹងរ៉ឹងពេកក្នុងការប្រើប្រាស់ឯកសារដែលធ្វើឲ្យការងាររបស់យើងនោះ មិនអាចធ្វើឲ្យបានត្រឹមត្រូវបានក្នុងការសិក្សាទៅលើឯកសារហ្នឹង។ យើងអត់អាចធ្វើហ្វូតូ -- ទៅថតចម្លង យើងអត់អាចយកទៅតាមខ្លួននៅចុងសប្ដាហ៍ដើម្បីមើល ហើយកម្មសិក្សាការី ក៏អត់អាចពិនិត្យមើលបាន។ អ៊ីចឹងវាពិបាកណាស់ លក្ខខណ្ឌរឹតត្បិតបែបនេះនោះ។

ចំពោះយើង គឺយើងសុំឲ្យមានការពិភាក្សាអំពីលក្ខខណ្ឌនៃការប្រើប្រាស់ឯកសារនេះ ដើម្បីឲ្យយើងអាចសិក្សាទៅលើឯកសារហ្នឹងបាន។ ចំពោះមេធាវីការពារក្ដី ក៏ដូចជាភាគីខាងយើងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញលោកមេធាវី លោក វ៉ិចទ័រ កូប៉េ!

[១៦:០៥:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ពាក់ព័ន្ធទៅនឹងការកត់សម្គាល់របស់សហព្រះរាជអាជ្ញា យើងខ្ញុំពិនិត្យមើលទិដ្ឋភាពរួមតែម្ដង ការៗកត់សម្គាល់របស់គាត់ គឺមិនបង្ហាញនូវទិដ្ឋភាពទូទៅនោះទេ។ យើងមិនមានលទ្ធភាពធ្វើបានទេ លោកប្រធាន សូមជម្រាបយ៉ាងដូច្នេះ គឺយើងមិនមានលទ្ធភាពពាក់ព័ន្ធទៅនឹងសាក្សីបន្ទាប់នោះទេ ដោយសារសហព្រះរាជអាជ្ញាមាន សហព្រះរាជអាជ្ញារងប្រាំមួយរូបដែលត្រូវមើលទៅផ្នែកផ្សេងៗ។ ជាជម្រើសនោះ យើងខ្ញុំសូមផ្ដល់ឲ្យមានការពិភាក្សាគ្នាឲ្យបានទូលំទូលាយដោយមិនសួរសក្ខីកម្មសាក្សីនៅថ្ងៃស្អែកទេ នេះជម្រើសទី១។ ហើយក្នុងរយៈពេលពីរឆ្នាំចុងក្រោយ យើងខ្ញុំមិនដែលនិយាយថាខ្ញុំមិនអាចមានលទ្ធភាពធ្វើអ្វីបាននោះទេ។ នេះទើបតែលើកទី១ទេ ដែលនិយាយថាមិនមានលទ្ធភាពដែល

ត្រូវសួរសក្ខីកម្មសាក្សីស្អែកនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវមតិយោបល់របស់គូភាគី ដែលពាក់ព័ន្ធនឹងបញ្ហាដែលអង្គជំនុំជម្រះបានដាក់ដើម្បីពិភាក្សានៅពេលនេះដើម្បីដោះស្រាយ ហើយបញ្ហានេះអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចចំពោះបញ្ហានេះនៅក្នុងអំឡុងពេលឆាប់ៗខាងមុខនេះឲ្យបានមុនកាលបរិច្ឆេទ នៃការស្តាប់សក្ខីកម្មសាក្សី TCW-803 និង 809 ហ្នឹង ចូលមកដល់។

បាទ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី វ៉ាន់ សឿន។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៨ នាទី)*